គង់ សុខហេង

# សំណួរ_ចំលើយ

ស្របតាមមេរៀន

# ភាសាខ្មែរ

# ១០

មាន :

- ចម្លើយគ្រប់មេរៀន
- វេយ្យាករណ៍
- បំណិន
- សំណេរ



ស្របតាមកម្មវិធីសិក្សាថ្មី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

---

# សំណួរ-ចម្លើយ

# ភាសាខ្មែរ

## ថ្នាក់ទី ១០

មានៈ _ចម្លើយគ្រប់មេរៀន

_វេយ្យាករណ៍

_បំណិន

_ការស្តាប់

សម្រាប់ជាជំនួយដល់ប្អូនៗ!

ស្របតាមកម្មវិធីថ្មីរបស់ក្រសួងអប់រំយុវជន និងកីឡា

២០១០

# អារម្ភកថា

ស្ងួស្តីប្អូនៗសិស្សានុសិស្សថ្នាក់ទី១០ជាទីស្រឡាញ់! សៀវភៅកំណែភាសាខ្មែរថ្នាក់ទី១០ថ្មីនេះ ខ្ញុំរៀបចំឡើងដើម្បីបំពេញសេចក្តីត្រូវការ និងជួយសម្រួលដល់ការសិក្សារបស់ប្អូនៗ ។

ចំពោះរាល់ការឆ្លើយសំណួរ ក៏ដូចជាការបកស្រាយទៅលើខ្លឹមសារនៅក្នុងមេរៀននីមួយៗ ប្រាកដជានៅមានចំណុចខ្វះខាតជាច្រើនដែលពុំទាន់អស់សេចក្តី ដូច្នេះសូមប្អូនៗយកទៅអានដោយការពិចារណាបន្ថែមទៀត ទើបការសិក្សារបស់ប្អូនៗទទួលបានជោគជ័យ ។

ចូរប្អូនចងចាំថា សៀវភៅ គឺសម្រាប់អាន មិនមែនសម្រាប់បើកចម្លងនៅពេលប្រឡងទេ!

ថ្ងៃទី ០៩ ខែ សីហា ២០១០

អ្នករៀបរៀង

គ.ស.ហ

មេរៀនទី ១

# មោទនភាពជាតិ

## កាលអាកាស

*កាលអាកាស គឺជាពេលវេលា និងទីកន្លែងដែលដំណើររឿងប្រព្រឹត្តទៅ។ ពេលវេលា និងទីកន្លែងនៃរឿង ជួនកាលអ្នកនិពន្ធលើកឡើងតាមស្ថានភាពពិតជាក់ស្តែង ជួនកាលប្រឌិតឡើងតាមមនោគតិរបស់ខ្លួន។*

ឧទាហរណ៍

+កាល (ពេលវេលា) : សម័យមួយ មួយខែក្រោយមក កាលពីឆ្នាំ២០០០ នាសម័យពុទ្ធកាល...។

+អាកាស (ទីកន្លែង) : រាជវាំងឧដុង្គ ភ្នំពេញ ឋានកុជង្គនាគ ទន្លេមេគង្គ នគរពារាណសី...។

**<u>ចម្លើយលំហាត់</u>**

១. កាលអាកាសក្នុងរឿងវត្តវិហារសួគ៌ :

ក) កាល : បន្ទាប់ពីនេះ សព្វថ្ងៃនេះ លុះព្រឹកឡើង វេលា

យប់...

ខ) អាកាស : ភូមិរលួស ស្រុកសូទ្រនិគម ខេត្តសៀមរាប ក្នុងព្រៃ ទួលគហេ រកាកោង ស្រុកមុខកំពូល ខេត្តកណ្ដាល មាត់ទន្លេ ល្វាទេ ស្រុកស្រីសន្ធរ...។

២. កាលអាកាសក្នុងរឿងវត្តសំពៅប្រាំ :

ក) កាល : ក្នុងកាលកន្លងយូរមកហើយ ពេលព្រលឹម ស្វាងឡើង សព្វថ្ងៃនេះ...។

ខ) អាកាសៈ ឆ្នេរខ្សាច់ សមុទ្រ ឋាននាគ ឋានមនុស្ស រាជនិវេសន៍ (រាជវាំង)...។



# រឿង ភ្នំបាយ៉ង់កោរ នៅខេត្តតាកែវ

សំណួរ

១. ហេតុអ្វីបានជាព្រះបាទបាយ៉ង់រត់ភៀសខ្លួនពីព្រះរាជដំណាក់នៅភ្នំដងរែក? មុននឹងភៀសខ្លួន តើព្រះអង្គបានបន់ស្រន់ទេវតាអារក្សទឹកដូចម្តេចខ្លះ?

២. នៅពេលភៀសខ្លួន តើព្រះនាងសក់ក្រអូបបានបន់ស្រន់អារក្សទឹក អារក្សគោក និងអ្នកតាព្រៃភ្នំដូចម្តេចខ្លះ? តើការបន់ស្រន់មានប្រសិទ្ធភាពដូចម្តេចដែរ?

៣. ហេតុអ្វីបានជាព្រះរាជាប្តូរព្រះនាមទៅជាព្រះបាទបាយ៉ង់កោរ?

៤. ចូរបង្ហាញកាលអាកាសរបស់រឿងនេះ។

៥. ចូររៀបរាប់ឈ្មោះភូមិស្រុក ឬទីកន្លែងដែលជាប់ឈ្មោះក្នុងរឿងនេះ។

៦. តាមរយៈឈ្មោះភូមិ ស្រុក ឬទីកន្លែងពិតប្រាកដក្នុងដំណើររឿងនេះ តើអ្នកមានយោបល់យ៉ាងណាចំពោះប្រវត្តិទឹកដីខ្មែរយើង?

### ចម្លើយ

១. បានជាព្រះបាទបាយ៉ង់រត់ភៀសខ្លួនពីព្រះរាជដំណាក់នៅភ្នំដងរែក ព្រោះដើម្បីនាំព្រះនាងសក់ក្រអូប ជាមហេសី រត់គេចពីការតាមចាប់របស់ពួកសៀម ។

មុននឹងភៀសខ្លួន ព្រះអង្គបានបន់ស្រន់ទេវតា អារក្សទឹក ថាសូមឱ្យបានសម្រេចសេចក្តីប្រាថ្នាបីប្រការគឺ ៖

-សូមឱ្យបានសេចក្តីសុខក្នុងដំណើរផ្លូវសាគរ

-សូមកុំឱ្យពួកសៀមតាមទាន់

-សូមឱ្យជួបប្រទះកន្លែងជាទីគាប់ចិត្ត

២. នៅពេលភៀសខ្លួន ព្រះនាងសក់ក្រអូបបានបន់ស្រន់អារក្សទឹក អារក្សគោក និងអ្នកតាព្រៃភ្នំថាសូមឱ្យបានជួបនឹងទីសុខប្រសើរ សូមឱ្យចោរសៀមចិត្តអប្រិយបរាជ័យវិនាសក្នុងសាគរ ។

ការបន់មានប្រសិទ្ធភាពដូចបំណងមែន គឺសំពៅស្តេចសៀម ដែលបានបញ្ជូនពលចំនួនមួយសែននាក់ឱ្យចេញទៅតាមស្ទាត់រកព្រះនាងនោះ ជ្រួសផ្លូវគ្នា ហើយត្រូវខ្យល់ព្យុះបក់បោកសំពៅសៀម ខ្ទេចខ្ទីលិចលង់ងាប់អស់ពួកពលនៅក្នុងមហាសាគរ ។

៣. បានជាព្រះរាជាប្តូរព្រះនាមទៅជាព្រះបាទបាយ៉ង់កោរ ព្រោះព្រះអង្គបានសន្យាថានឹងកោរសក់ថ្វាយ នៅពេលដែលព្រះអង្គបន់ស្រន់ទេវតា អារក្សទឹកមុននឹងចេញដំណើរភៀសព្រះកាយ ។ លុះបានសម្រេច ផុតពីទុក្ខភ័យហើយ ព្រះអង្គក៏កោរព្រះកេសាថ្វាយដើម្បីលាបំណន់ ហើយក៏ជាប់ព្រះនាមថា ស្តេចបាយ៉ង់កោររហូតមក ។

៤. កាលអាកាសរបស់រឿង

**+កាល** : សម័យព្រេងនាយ, ខណៈនោះ, គ្រានោះ, បន្ទាប់ពីនោះ, ទាំងវេលាយប់, សព្វថ្ងៃ, ក្រោយពី, វេលានោះ...

**+អាកាស** : ភ្នំដងរែក, ស្រុកត្រាំកក់ ខេត្តតាកែវ, មហាសាគរ, ក្នុងព្រៃច្រកបព្វតា, កន្លែងចតសំពៅនានា...

៥. ឈ្មោះភូមិស្រុក ឬទីកន្លែងដែលជាប់ឈ្មោះក្នុងរឿងនេះមាន ៖ ភូមិបាក់កូត( បាក់ចង្កូត), ភូមិចត (កន្លែងចត), ភូមិសែនបន់, ភូមិសំពៅធ្លាយ, ភូមិព្រៃកស្បូវ, ភូមិអន្លង់ទៀន, ភូមិសន្លុង (សែនលង់), ភ្នំរន្ទះ, ភ្នំបាយ៉ង់កោរ... ។

៦. តាមរយៈឈ្មោះភូមិ ស្រុក ឬទីកន្លែងពិតប្រាកដក្នុងដំណើររឿងនេះ ខ្ញុំយល់ថាប្រវត្តិទឹកដីខ្មែរយើងសម្បូរដោយរឿងរ៉ាវជា

ច្រើន ហើយឈ្មោះភូមិ ឃុំ ស្រុកនីមួយៗក្នុងប្រទេសយើងភាគច្រើនសុទ្ធតែទាក់ទងនឹងប្រវត្តិរឿងព្រេងទាំងនោះ ដែលឈ្មោះខ្លះក៏រក្សានៅដដែល ឯឈ្មោះខ្លះទៀតក៏យាក្លាយឃ្លាតពីឈ្មោះដើមខ្លះៗ។ ម្យ៉ាងវិញទៀតយើងអាចសន្និដ្ឋានថាបុព្វបុរសខ្មែរយើងមានទេពកោសល្យខ្ពស់ក្នុងការប្រឌិតរឿងព្រេងឱ្យទាក់ទងទៅនឹងស្ថានភាពភូមិសាស្ត្រទឹកដីខ្មែរ ទុកគ្រាន់កូនចៅជំនាន់ក្រោយអានកំសាន្តបំបាត់ការអផ្សុក ។

# នាម

១– *នាមគឺជាថ្នាក់ពាក្យមួយប្រភេទសម្រាប់សំដែងឈ្មោះមនុស្ស សត្វ វត្ថុ ទីកន្លែង រុក្ខជាតិ ធម្មជាតិអ្វីមួយ ។*

នាមចែកជា ៖

១. សាធារណនាម ឬ នាមសាធារណ៍ : ជានាមដែលសំដែងឈ្មោះទូទៅ មិនចំពោះ ។

ឧទាហរណ៍ : ដីស្រែ សាលារៀន សៀវភៅ...

២. អសាធារណនាម ឬ នាមអសាធារណ៍ : ជានាមដែលសំដែងឈ្មោះមិនទូទៅ ចំពោះប្រាកដច្បាស់លាស់ ។

ឧទាហរណ៍ : កម្ពុជា ភ្នំពេញ ពូសំ ខេត្តសៀមរាប...

៣. ករណនាម ឬ នាមករណ៍ : ជានាមសម្រាប់សំដែងសភាព ឬលក្ខណៈអ្វីមួយ ។ វាមានកំណើតមកពីកិរិយា ឬគុណនាម ។

ឧទាហរណ៍ : ទង្វើ កំណើត កំហូច សេចក្ដីសុខ...

៤. ការកនាម ឬ នាមការក៏ : ជានាមសំដែងអ្នកធ្វើអំពើ ឬអ្នកមានសភាពលក្ខណៈបែបណាមួយ ។ វានាមកំណើត

មកពីកិរិយា គុណនាម និងនាម ។

ឧទាហរណ៍ : អ្នកដើរ ឈ្មួញ អ្នកស្រែ អ្នកមាន ឆ្មាំ...

## លំហាត់

១. ក្នុងចំណោមពាក្យខាងក្រោម តើពាក្យណាខ្លះជាសាធារណនាម? ហើយពាក្យណាខ្លះជាអសាធារណនាម?

| |
|---|
| សាលារៀន កម្មករ បុណ្យភ្ជុំបិណ្ឌ ប្រាសាទតាព្រហ្ម ពិធីបុណ្យ ព្រះអង្គ ភូមិសែនបន់ សៀវភៅ អ្នកនិពន្ធ រមណីយដ្ឋានទន្លេបាទី ប្រាសាទបាយ័ន្តកោរ |

២. តើពាក្យណាខ្លះជាករណនាម? ហើយពាក្យណាខ្លះជាករកនាម?

| |
|---|
| សំដី ខ្មៅដៃ ការសង្កេត អ្នកក្លាហាន អ្នកស្រុក ទំហំ ខ្មាន់កាំភ្លើង ជំនួញ សេចក្តីចម្រើន ការអត់ធ្មត់ ការសន្ទត |

៣. ចូរតែងល្បះដោយប្រើនាមមួយបែប១ឱ្យបានបួនល្បះ ។

## ចម្លើយ

១. ក) សាធារណនាម មាន : សាលារៀន កម្មករ ពិធីបុណ្យ ព្រះអង្គ សៀវភៅ អ្នកនិពន្ធ

ខ) អសាធារណនាម មាន : បុណ្យភ្ជុំបិណ្ឌ ប្រាសាទតាព្រហ្ម ភូមិសែនបន់ រមណីយដ្ឋានទន្លេបាទី ប្រាសាទបាយ័ន្តកោរ

២. ក) ករណនាម មាន : សំដី ខ្មើយ ការសង្កេត ជំនួញ សេចក្ដី-ចម្រើន ការអត់ធ្មត់ ការសន្ទត ទំហំ

ខ) ករកនាម មាន : អ្នកក្លាហាន អ្នកស្រុក ខ្មាន់កាំភ្លើង

៣. តែងល្បះ

ក) សាធារណនាម

-ពុកខ្ញុំទៅ *ស្រែ* ។

-ពួកគេនាំគ្នាទៅ *វត្ត* ។

-*រថយន្ត* នេះថ្មីស្រឡាង ។

-ខ្ញុំចង់បាន *កង់* មួយគ្រឿង ។

ខ) អសាធារណនាម

-*ភ្នំពេញ* ឥឡូវសប្បាយណាស់ ។

-ស្អែកពួកយើងចេញដំណើរទៅ *ខេត្តសៀមរាប* ។

-*ទន្លេសាប* ជាជង្រុកត្រីនៃប្រទេស *កម្ពុជា* យើង ។

-សត្វផ្សោតមាននៅក្នុង *ខេត្តក្រចេះ* ។

គ) ករណនាម

-នារីមាន *ដំណើរ* ញៀងញ៉ង ។

-សុកទទួលស្គាល់ *កំហុស* ។

-ខ្ញុំមាន *សេចក្ដីសុខ* ណាស់ ។

-មនុស្សលោកចង់រស់នៅក្នុង ***ភាពសុខសាន្ត*** ។

ឃ) ករកនាម

-***អ្នកស្រែ*** មមាញឹកនឹងការងារបង្កបង្កើនផល ។

-***ព្រាន*** ព្រៃចាប់បានសត្វទន្សាយមួយ ។

-នៅតាមផ្លូវគេឃើញ ***អ្នកដំណើរ*** យ៉ាងច្រើនកុះករ ។

-***អ្នកមាន*** សម័យឥឡូវរំាយឫកណាស់ ។

# លក្ខណៈតថៈនៅក្នុងរឿង

*១– លក្ខណៈតថៈនៅក្នុងរឿង គឺជារឿងរ៉ាវ ហេតុការណ៍ ព្រឹត្តិការណ៍ ឈ្មោះទីកន្លែង សកម្មភាព...ដែលមានពិតនៅក្នុងសង្គមជាក់ស្តែង ហើយត្រូវបានអ្នកនិពន្ធបញ្ចូល ឬផ្សារភ្ជាប់ទៅនឹងដំណើររឿងដោយផ្សំនឹងមនោគតិរបស់ខ្លួន ។*

**លំហាត់**

ចូររកលក្ខណៈតថៈនៅក្នុងអត្ថបទដកស្រង់រឿង:

១. **រឿងកុលាបប៉ៃលិន**

ចំ. តាមរយៈដំណើររឿងនៅក្នុងអត្ថបទដកស្រង់ អ្នកនិពន្ធបានភ្ជាប់ដំណើររឿងទៅនឹងឈ្មោះទីកន្លែងពិតប្រាកដនៅក្នុងប្រទេសកម្ពុជាយើង គឺ ខេត្តបាត់ដំបង ខេត្តប៉ៃលិន និងទេសភាពនៅតាមជើងភ្នំ ដែលរថភ្លើងបរកាត់ ។

២. **រឿងព្រេងទាក់ទងនឹងបុណ្យភ្ជុំបិណ្ឌ-បណ្តែតផ្ទូនតា**

ចំ. តាមរយៈដំណើររឿងនៅក្នុងអត្ថបទដកស្រង់ អ្នកនិពន្ធបានភ្ជាប់ដំណើររឿងទៅនឹងទំនៀមទម្លាប់របស់ខ្មែរយើង ដែលតែងតែប្រារព្ធជារៀងរាល់ឆ្នាំ គឺទំនៀមទម្លាប់បណ្តែត

ជូនតា ដែលគេធ្វើឡើងថ្ងៃបុណ្យភ្ជុំបិណ្ឌជារៀងរាល់ឆ្នាំ ដើម្បីជូនដំណើរជូនតាត្រឡប់ទៅស្រុកវិញ ដោយនាំទាំងគ្រឿងឧបភោគ បរិភោគជាច្រើនទៅជាមួយផង ។





# រឿងប្រាសាទអង្គរវត្ត

សំណួរ

១. ហេតុអ្វីបានជានាងទិព្វសុតាចន្ទ ចុះមករស់នៅជាមួយនឹងតាលឹមសេង ឯឋានមនុស្សលោក?

២. តើនាងទិព្វសុតាចន្ទទូលព្រះឥន្ទ្រដូចម្ដេចខ្លះអំពីព្រះពិស្ណុការ? តើព្រះពិស្ណុការបានរៀនវិជ្ជាអ្វីខ្លះនៅទីនោះ?

៣. តាមដំណើររឿង តើអតីតជាតិរបស់ព្រះឥន្ទ្រគឺនរណា? ហេតុអ្វីបានជាព្រះអង្គបានកើតជាព្រះឥន្ទ្រ?

៤. ចូរបង្ហាញពីបច្ចេកទេសត្រួសៗក្នុងការកសាងប្រាសាទរបស់ព្រះពិស្ណុការ ។

៥. ចូរបង្ហាញកាលអាកាសរបស់រឿង ។

៦. ចូររកប្រធានរឿង និងមូលបញ្ហារបស់រឿង ។

៧. តាមពិត តើព្រះពិស្ណុការតំណាងឱ្យនរណា? ហេតុអ្វី?

៨. ចូរស្រង់ពាក្យដែលជានាមទៅតាមប្រភេទនីមួយៗឱ្យបានយ៉ាងតិចពីរពាក្យ ។

ចម្លើយ

១. បានជានាងទិព្វសុតាចន្ទចុះមករស់នៅជាមួយនឹងតាលីមសេងឯឋានមនុស្សលោក ព្រោះនាងបានលួចបេះផ្ការរបស់តាលីមសេងចំនួន៦ទង ក៏ត្រូវព្រះឥន្ទ្រជាព្រះបិតាផ្តន្ទាទោសឱ្យនាងចុះមកនៅឋានមនុស្សរយៈពេល៦ឆ្នាំ និងត្រូវធ្វើជាប្រពន្ធតាលីមសេងទៀតផង។

២. នាងទិព្វសុតាចន្ទទូលព្រះឥន្ទ្រអំពីព្រះពិស្ណុការថា "បុត្រខ្ញុំម្ចាស់មានការប៉ិនប្រសប់ណាស់ គឺចេះគូរ ចេះឆ្លាក់ នាំឱ្យមនុស្សលោកមានសេចក្តីកោតសរសើរស្ញប់ស្ញែងក្រៃលែង ប៉ុន្តែទាស់តែកូនខ្ញុំម្ចាស់ចេះចំណេះទាំងនេះដោយឥតបានរៀនពីគ្រូណាសោះគឺវាចេះដោយសារគំនិតវាតែម្តង"។

នៅឋានព្រះឥន្ទ្រ ព្រះពិស្ណុការបានរៀនវិជ្ជាជាច្រើន ពិសេសបច្ចេកទេសខាងសិល្បៈ និងសំណង់យ៉ាងស្ទាត់ជំនាញ។

៣. តាមដំណើររឿង អតីតជាតិរបស់ព្រះឥន្ទ្រគឺជាមាណព។ បានជាព្រះអង្គបានកើតជាព្រះឥន្ទ្រ ព្រោះកាលនៅជាមនុស្ស ព្រះអង្គបានស្ថាបនាផ្លូវថ្នល់ ស្ថាបនាទំនប់ទឹក សង់សាលា សង់ស្ពាន និងបានធ្វើបុណ្យដល់អ្នកក្រីក្រលំបាក។

៤. បច្ចេកទេសក្នុងការកសាងប្រាសាទរបស់ព្រះពិស្ណុការ៖

-ពិស្ណុការបង្គាប់ឱ្យជីកស្នាមភ្លោះយកអាចម៍ដីចាក់គរលើគ្នា

យ៉ាងខ្ពស់ រួចទើបពិស្ណុការយករូបចម្លាក់ផ្សេងៗ ទៅផ្ដិតលើដីនោះ គ្រប់ទិសទាំងអស់ ។

-ការសាងសង់ប្រាសាទ ព្រះពិស្ណុការឥតចាំបាច់ចងរន្ទា ដាំសសរម្ដងមួយៗដូចយើងទេគឺលោកយកដីមកគរសង់ជាប្រាសាទប្រាំជាន់តែម្ដងទើបយកទឹកថ្នាំលាយទៅលាបពីលើតួប្រាសាទដីទាំងមូល ។ ប្រាសាទក៏ក្លាយទៅជាថ្ម ។

៥. កាលអាកាសរបស់រឿង ៖

+កាល : ថ្ងៃមួយ ប្រមាណជា១ឆ្នាំក្រោយមក រយៈពេល៦ឆ្នាំគំរប់ ៧ថ្ងៃ...

+អាកាស : ឋានកណ្ដាល ឋានព្រះឥន្ទ្រ ខ្ទមតាលីមសេងក្នុងព្រៃ លើភ្នំ ប្រទេសកម្ពុជា...

៦. ប្រធានរឿង និងមូលបញ្ហារបស់រឿង

**+ប្រធានរឿង** : រឿងនេះនិយាយពីប្រភពកំណើតនៃប្រាសាទអង្គរវត្ត ។

**+មូលបញ្ហារឿង** : បញ្ហាសំខាន់ៗនៅក្នុងរឿងនេះមាន ៖

-កំណើតព្រះពិស្ណុការ

-ព្រះពិស្ណុការទៅរៀនវិជ្ជាបច្ចេកទេសខាងសិល្បៈ និងសំណង់នៅឋានព្រះឥន្ទ្រ

-ព្រះកេតុមាលាជាអតីតបុត្រព្រះឥន្ទ្រដើរលេងទស្សនាសព្វទីកន្លែងនៅឋានព្រះឥន្ទ្រ

-ព្រះឥន្ទ្របញ្ជាឱ្យព្រះពិស្ណុការមកសាងប្រាសាទមួយរាងដូចក្រោលគោព្រះឥន្ទ្រថ្វាយព្រះកេតុមាលា គឺប្រាសាទអង្គរវត្ត ។

៧. តាមពិត ព្រះពិស្ណុការតំណាងឱ្យអ្នកសាងសង់ប្រាសាទ (បុព្វបុរសខ្មែរ) ព្រោះគ្មានទេវតាឯណាមកសាងសង់ប្រាសាទ ឬជួបប្រាសាទបានឡើយ គឺវាត្រូវការកម្លាំងមនុស្សពិតៗ ការសហការពេលវេលា ការតស៊ូ អត់ធ្មត់ និងការច្នៃប្រឌិតដោយបច្ចេកទេសខ្ពស់ ។

៨. ពាក្យដែលជានាមនៅក្នុងអត្ថបទ :

+នាមសាធារណ៍ : ផ្កា សួនច្បារ ប្រាសាទ ព្រះរាជរថ...

+នាមអសាធារណ៍ : ឋានព្រះឥន្ទ្រ តាលីមសេង ព្រះពិស្ណុការ ព្រះកេតុមាលា នាងទិព្វសុតាចន្ទ...

+នាមករណ៍ : សេចក្តីលំបាកវេទនា កំណត់ ការផ្គួនាំតំណាល សេចក្តីនឹករលឹក សេចក្តីកោតសរសើរ ការស្លាបនា...

+នាមការក៍ : អ្នកមាន អ្នកបច្ចេកទេស អ្នកយាមស្លាបនិក ជាងឈើ...

# ការសង្ខេប

*១– ការសង្ខេប គឺជាការនិយាយ ឬសរសេរបំព្រួញឱ្យខ្លី តែមានន័យគ្រប់គ្រាន់ ដោយច្បិចយកតែចំណុច គំនិត ព្រឹត្តិការណ៍ ឬខ្លឹមសារសំខាន់ៗ ដោយរក្សាន័យខ្លឹមសារដើម ។*

**សំណួរ**

១. តើរឿងខាងលើនិយាយពីបញ្ហាអ្វី?

២. តើរឿងទាំងមូលខាងលើមានព្រឹត្តិការណ៍សំខាន់ៗអ្វីខ្លះ?

៣. តើរឿងទាំងមូល និងអត្ថបទសង្ខេបមានលក្ខណៈដូចគ្នា និងខុសគ្នាត្រង់ណាខ្លះ?

**ចម្លើយ**

១. រឿងខាងលើនិយាយពីជំនឿបង់ប្រាក់ ឬមាសក្នុងមាត់បុគ្គលដែលស្លាប់ទៅ។

២. រឿងទាំងមូលខាងលើមានព្រឹត្តិការណ៍សំខាន់ៗដូចតទៅ ៖

-គ្រួសារតាយាយក្រីក្រ មានមាសតែមួយបាទ

-តាស្លាប់ យាយយកមាសមួយបាទទៅដាក់ក្នុងមាត់តា

-មាសឆេះសល់តែពាស្លឹង

-ស្ដេចបញ្ជាឱ្យរែអង្គាសយកមាសពីប្រជារាស្ត្រមួយគ្រួសារ

មួយបាទ

-យាយរៀបរាប់អង្វរព្រះមហាក្សត្រ

-ព្រះមហាក្សត្រលើកលែងការរំរអង្គាស

៣. រឿងទាំងមូល និងអត្ថបទសង្ខេបមានលក្ខណៈដូចគ្នាត្រង់ មានខ្លឹមសារ អត្ថន័យ ដំណើររឿងដូចគ្នា។ ប៉ុន្តែមានលក្ខណៈខុសគ្នាត្រង់ រឿងទាំងមូលមានទំហំរឿងវែងអន្លាយ មានកាលអាកាសច្រើន មានការសន្ទនារវាងតួអង្គ និងតួអង្គ មានការរៀបរាប់លំអិតព្រឹត្តិការណ៍តូចៗជាច្រើន...ចំណែកអត្ថបទសង្ខេប មានទំហំរឿងខ្លី គ្មានកាលអាកាសសាំញ៉ាំ គ្មានការសន្ទនា ហើយគេរៀបរាប់តែព្រឹត្តិការណ៍ធំសំខាន់ៗប៉ុណ្ណោះ...។

**លំហាត់**

ចូរសង្ខេបរឿងក្នុងអំណានទី១ និងទី២ឡើងវិញ។

**ចម្លើយ**

### ១. សង្ខេបរឿងភ្នំបាយ៉ង់កោរ នៅខេត្តតាកែវ

កាលពីព្រេងនាយ នៅប្រទេសខ្មែរមានស្តេចមួយអង្គព្រះនាមព្រះបាទបាយ៉ង់ មានព្រះរាជដំណាក់នៅភ្នំដងរែក មានមហេសីព្រះនាមនាងសក់ក្រអូប។ ព្រះនាងមានរូបឆោមល្អ ល្បីរន្ទឺដល់ព្រះចៅសៀម។ ព្រះចៅសៀមក៏ចាត់មនុស្សឱ្យតាមចាប់ព្រះនាងយក

ទៅស្រុកវា ដើម្បីទុកជាព្រះកិត្តិយស ។

ព្រះបាទបាយ៉ង់ នាំមហេសីភៀសព្រះកាយតាមសំពៅមួយ តែមុននឹងចេញដំណើរព្រះអង្គបានបន់ស្រន់ទេវតា អារក្សទឹកឱ្យរួចផុតពីការតាមចាប់របស់ពួកសៀម ដោយសន្យាថានឹងកោរព្រះកេសាថ្វាយលាបំណន់ ។

ចំណែកនៅតាមមហាសាគរដែលព្រះបាទបាយ៉ង់ធ្វើដំណើរនោះ ព្រះនាងសក់ក្រអូបក៏បានបួងសួងដល់ទេវតា អារក្សទឹក អារក្សគោក ឱ្យផ្ដន្ទាពួកចោរសៀមឱ្យវិនាសក្នុងមហាសាគរ ក៏បានសម្រេចដូចបំណង ។

នៅតាមផ្លូវធ្វើដំណើររបស់ព្រះបាទបាយ៉ង់ មានព្រឹត្តិការណ៍ជាច្រើនទាក់ទងនឹងព្រះអង្គ ហើយព្រឹត្តិការណ៍ទាំងនោះក៏ក្លាយជាឈ្មោះភូមិស្រុក ភ្នំ ដែលមាននៅក្នុងប្រទេសកម្ពុជារហូតដល់សព្វថ្ងៃ ។

បន្ទាប់ពីរួចផុតពីទុក្ខភ័យហើយព្រះបាទបាយ៉ង់ក៏កោរព្រះកេសាលាបំណន់ ហើយក៏ជាប់ព្រះនាមថា ព្រះបាទបាយ៉ង់កោរ ចំណែកទីទួលខ្ពស់ដែលទ្រង់ធ្វើព្រះពន្លានោះ ក៏ជាប់ឈ្មោះថា ភ្នំបាយ៉ង់កោររហូតដល់សព្វថ្ងៃ ។

## ២. សង្ខេបរឿងប្រាសាទអង្គរវត្ត

ថ្ងៃមួយនាងទិព្វសុគាចន្ទ និងទេពធិតាទាំងអស់៥អង្គបាននាំគ្នាចុះចាកឋានព្រះឥន្ទ្រ មកលេងក្នុងសួនច្បាររបស់តាលីមសេង ។

នាងទិព្វសុតាចន្ទ បានកាច់ផ្ការបស់តាលីមសេងទ៦ទង ក៏មានកម្មពៀរត្រូវមករស់ជាប្រពន្ធរបស់តាលីមសេងរយៈពេល៦ឆ្នាំ។

នាងជួយឱ្យតាលីមសេងមានជីវភាពធូរធារ។ នាងប្រសូតបានកូនប្រុសម្នាក់ ដែលទារកនេះរពិសពន់ពេក ហើយវាតែងគូររូបលេងសព្វបែបយ៉ាងមិនចេះខ្ជិល។ នាងទិព្វសុតាចន្ទក៏ដាក់ឈ្មោះកូនថាព្រះពិស្ណុការ។

លុះគម្រប់៦ឆ្នាំ នាងទិព្វសុតាចន្ទ ក៏ត្រូវវិលទៅឋានព្រះឥន្ទ្រវិញ ដោយបន្សល់ទុកកូនប្រុសម្នាក់អាយុ៥ឆ្នាំឱ្យតាលីមសេង។

ព្រះពិស្ណុការដើររកម្ដាយគ្រប់ទិសទី ហើយក៏បានជួបម្ដាយនៅក្នុងព្រៃ។ នាងទិព្វសុតាចន្ទក៏នាំបុត្រឡើងទៅឋានព្រះឥន្ទ្រ រួចទូលព្រះឥន្ទ្រតាមដំណើររឿងដែលនាងនៅឋានកណ្ដាល និងទូលថ្វាយពីភាពវៃឆ្លាតរបស់ព្រះពិស្ណុការ។ ព្រះឥន្ទ្រក៏ឱ្យព្រះពិស្ណុការរៀនវិជ្ជាជាមួយទេវបុត្រ បានចេះចាំស្ទាត់ជំនាញខាងបច្ចេកទេសសិល្បៈ និងសំណង់។

ព្រះឥន្ទ្ររលឹកដល់បុត្ររបស់ព្រះអង្គពេក ក៏ហោះចុះមកឋានកណ្ដាលនាំព្រះកេតុមាលាទៅលេងឋានព្រះឥន្ទ្រ រួចឱ្យទេវបុត្រនាំព្រះកេតុមាលាដើរមើលសព្វទីកន្លែង ព្រមទាំងប្រទានឱ្យមានអាយុវែង។ ដល់ពេលត្រឡប់មកឋានកណ្ដាលវិញព្រះឥន្ទ្រក៏បញ្ជាឱ្យព្រះពិស្ណុការសាងសង់ប្រាសាទដែលព្រះកេតុមាលាពេញចិត្តថ្វាយ និង

គ្រប់គ្រងប្រទេសកម្ពុជា ។

ព្រះពិស្ណុការក៏រៀបចំសាងសង់ប្រាសាទ ហើយមានលម្អយ៉ាងត្រចះត្រចង់ គឺល្អដូចជាក្រោលគោព្រះឥន្ទ្រ ថ្វាយព្រះកេតុមាលា និងប្រាសាទដទៃជាច្រើនទៀត ។

## អ្នកនិពន្ធ កាលកំណត់តែង និងសង្គម បរិយាកាសនៃរឿង

១– *អ្នកនិពន្ធ គឺជាអ្នកសរសេរ ឬតាក់តែងរឿង ។*

១– *កាលកំណត់តែង គឺជាពេលវេលា ថ្ងៃខែឆ្នាំ ដែលអ្នកនិពន្ធបាន សរសេរចប់សព្វគ្រប់ ហើយបានបញ្ជាក់នៅក្នុងស្នាដៃរបស់ខ្លួន យ៉ាងពិតប្រាកដ ។*

១– *សង្គមបរិយាកាស គឺជាដំណើររឿងដែលអ្នកនិពន្ធលើកមក បង្ហាញ ស្ថិតក្នុងសម័យកាលណាមួយ ហើយមានព្រឹត្តិការណ៍សង្គម អ្វីខ្លះនៅក្នុងរឿងដែលត្រូវឱ្យកត់សម្គាល់ក្នុងស្នាដៃរបស់ខ្លួន ។*

**លំហាត់**

ចូរអ្នកប្រាប់ពីឈ្មោះអ្នកនិពន្ធ កាលកំណត់តែង និងសង្គមបរិយាកាស នៃរឿងណាមួយដែលប្អូនធ្លាប់បានសិក្សានៅថ្នាក់មុនៗ និងរឿងដែល អ្នកធ្លាប់បានអាន ៖

១. រឿងកុលាបប៉ៃលិន
២. រឿងមាលាដួងចិត្ត
៣. រឿងផ្កាស្រពោន
៤. រឿងទុំទាវ

**ចម្លើយ**

១. រឿងកុលាបប៉ៃលិន

-អ្នកនិពន្ធ : ញ៉ុក ថែម

-កាលកំណត់តែង : ១៩៣៦ ឬ ១៩៤៣

-សង្គមបរិយាកាស : ដំណើររឿងប្រព្រឹត្តទៅនៅក្នុងសម័យអាណានិគមបារាំង។ រឿងនេះឆ្លុះបញ្ចាំងពីជីវិតកម្មករជីកត្បូងនៅស្រុកប៉ៃលិន។ ផ្នត់គំនិតនៃរឿងគឺការប្រកាន់ខ្ជាប់នូវបណ្ដាំ "អត្តា ហិ អត្តនោ នាថោ" ឬ "ខ្លួនទីពឹងខ្លួន" ។ ព្រឹត្តិការណ៍ធំ គឺការតស៊ូព្យាយាម ជំនះរាល់ការលំបាកចំពោះមុខ និងភាពជាកូនកតញ្ញូ ទីបំផុតធ្វើឱ្យជីវិតមានសុភមង្គល។

២. រឿងមាលាដួងចិត្ត

-អ្នកនិពន្ធ : នូ ហាច

-កាលកំណត់តែង : ១៩៧២

-សង្គមបរិយាកាស : ដំណើររឿងប្រព្រឹត្តទៅក្នុងសម័យ

អាណានិគមបារាំង គឺនៅពេលដែលខេត្តខ្មែរដែលបាត់បង់ទៅ ត្រូវបានមកវិញ។ សម័យនោះពោរពេញទៅដោយអំពើពុករលួយស៊ីសំណូកសូកប៉ាន់អ្នកមានលុយជាអ្នកឈ្នះ អ្នកក្រជាអ្នកចាញ់។

៣. រឿងផ្កាស្រពោន

-អ្នកនិពន្ធ : នូ ហាច

-កាលកំណត់តែង : ១៩៤៩

-សង្គមបរិយាកាស : ដំណើររឿងប្រព្រឹត្តទៅក្នុងសម័យអាណានិគមបារាំង។ រឿងនេះកើតឡើងក្នុងសម័យដែលប្រទេសកម្ពុជាត្រូវបែងអាណាខេត្តខាងលិច ទៅនៅក្រោមអំណាចប្រទេសជិតខាង។ ផ្ទត់គំនិតសង្គមនាសម័យនោះ គឺការប្រកាន់ខ្ជាប់នូវជំនឿទំនៀមទម្លាប់ ប្រពៃណីជាធំ។ ព្រឹត្តិការណ៍សំខាន់ៗនៃរឿង គឺការប្រកាន់វណ្ណៈអ្នកមាន អ្នកក្រ និងភាពជាកូនកតញ្ញូ មិនហ៊ានជំទាស់នឹងបំណាងម្ដាយ។ ទីបំផុតតួអង្គឯកនារីត្រូវស្លាប់ បន្សល់ទុកនូវវិប្បដិសារី ដល់អ្នកនៅរស់។

៤. រឿងទុំទាវ

-អ្នកនិពន្ធ : ព្រះបទុមត្ថេរ ងួន សោម (ភិក្ខុសោម)

-កាលកំណត់តែង : ១៩១៥

-សង្គមបរិយាកាស : តាមរយៈការរៀបរាប់នេះយើងអាច

សន្និដ្ឋានថា ដំណើររឿងទុំទាវប្រព្រឹត្តក្រោមរបបសក្តិភូមិ នាសម័យលង្វែក (១៤៣១-១៦១៨)។ ផ្នត់គំនិតរបស់ខ្មែរ សម័យនោះ គឺធំមិនធំជាងនាឡិគឺកូនស្រីត្រូវយកប្តីតាមការទុកដាក់របស់ឪពុកម្តាយ។ ប្រជាជនខ្មែរគោរពព្រះពុទ្ធសាសនា កូនប្រុសត្រូវបួសរៀននៅក្នុងវត្តនិងជឿលើការទស្សន៍ទាយ គោរពប្រពៃណី (ចូលម្លប់ ចៃធ្វូវ មង្គលការ)។ ស្តេចមានអំណាចលើសអ្វីៗទាំងអស់ អ្នកប្រឆាំងនឹងស្តេចនឹងត្រូវស្លាប់។ ព្រឹត្តិការណ៍ធំនៅក្នុងរឿងគឺ សេចក្តីស្នេហាដ៏ស្មោះស្ម័គ្ររបស់តួអង្គឯក ហ៊ានប្រឆាំងនឹងការកៀបសង្កត់ពីសំណាក់អ្នកមានអំណាច តែត្រូវស្លាប់យ៉ាងអណោចអធម។

## ចំណុចទី២ វិធីតែងនិពន្ធ

*១- វិធីតែងនិពន្ធ គឺជាររបៀបតាក់តែងរឿងដែលមានច្រើនប្រភេទ ដូចជាការតែងរឿងបុរាណ រឿងទំនើប ហើយប្រភេទរឿងនីមួយៗ មានលក្ខណៈពិសេសដោយឡែកៗពីគ្នា តាំងពីចំណុចផ្ដើមរឿង តួរឿង និង បញ្ចប់រឿង ។*

**លំហាត់**

ចូរប្អូនអានអត្ថបទដកស្រង់រឿងផ្កាស្រពោន រួចបង្ហាញពីវិធីតែងនិពន្ធតាមវគ្គនីមួយៗខាងក្រោមនេះឱ្យបានត្រឹមត្រូវ ។

**ចម្លើយ**

អត្ថបទដកស្រង់រឿង ផ្កាស្រពោន វគ្គទី៩

ក) **ផ្ដើមរឿង** : អ្នកនិពន្ធរៀបរាប់ពីទេសភាពនៃទីក្រុងសៀមរាប រួចទើបភ្ជាប់ទៅនឹងដំណើររឿង។ (សៀមរាបជាកូនក្រុងមួយស្អាតញញឹមលំអដោយថ្មល់ដែលមានរុក្ខជាតិចោលម្លប់ទៅលើ.....) ។

ខ) **តួរឿង** : អ្នកនិពន្ធប្រើវិធី ៖

-ពណ៌នាវិធី : អ្នកនិពន្ធរៀបរាប់ដំណើររឿង (នៅសាយណ្ហកាល រថយន្តបើកចូល......)

-វចនវិធី ៖ អ្នកនិពន្ធប្រើពាក្យរាយ សាមញ្ញ ងាយយល់ តែក៏មានលាយពាក្យកម្ចីបាលីសំស្ក្រឹត និងកម្ចីបរទេសខ្លះដែរ (ខ្ញុំ ថៃ អារី វ៉ាលី សាយណ្ហកាល ព្រហ្មចារីយ៍...)

-រចនាវិធី ៖ ឃ្លាប្រយោគងាយយល់ ងាយស្ដាប់

ឧទា-ថៃ ! ឯណាអីវ៉ាន់ថៃខ្លះ?

-យីអារី ឯងសំពះសួរមា។

-សំវាទវិធី ៖ ការសន្ទនារវាង យាយទួន និងបេងជុន...

-ឧបមានវិធី ៖ អ្នកនិពន្ធធ្វើការប្រៀបធៀបដោយប្រើ សំនួន "ដូច"។

ឧទា-....រូបនាងក៏នៅស្រស់ចំប្រប់ដូចព្រហ្មចារីយ៍សុទ្ធវិស័យ។



# ជំនឿ

**សំណួរ**

១. ចូរប្រាប់ឈ្មោះអ្នកនិពន្ធ និងកាលកំណត់តែងរបស់រឿងផ្កាស្រពោន ។

២. ចូរបង្ហាញពីស្ថានភាពសង្គមខ្មែរ តាមរយៈអត្ថបទដកស្រង់នេះ ថា តើមានលក្ខណៈដូចម្ដេចខ្លះ?

៣. ចូររកាលអាកាសនៃអត្ថបទដកស្រង់ ។

៤. តើវគ្គដកស្រង់នេះ មានចំណុចណាខ្លះដែលបញ្ជាក់ពីបញ្ហា ជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់ខ្មែរដែលជាអត្តសញ្ញាណជាតិខ្មែរ?

៥. តើវគ្គដកស្រង់នេះមានតម្លៃអប់រំដូចម្ដេច?

៦. ចូរអ្នកអានរឿងផ្កាស្រពោន រួចប្រាប់ពីវិធីផ្ដើមរឿង និងបញ្ចប់រឿងឱ្យបានត្រឹមត្រូវ ។

**សំណួរ**

១. អ្នកនិពន្ធ និងកាលកំណត់តែងរបស់រឿងផ្កាស្រពោន :

-អ្នកនិពន្ធ : នូ ហាច

-កាលកំណត់តែង : ១៩៤៩

២. ស្ថានភាពសង្គមខ្មែរ តាមរយៈអត្ថបទដកស្រង់នេះ ៖ ប្រជាជនខ្មែរមានទស្សនៈអន់ថយ វិទ្យាសាស្ត្រមិនទាន់រីកចម្រើនប៉ុន្មានទេ គឺគេជឿលើអបិយជំនឿហួសហេតុ( មន្តអាគម ស្រោចទឹក បញ្ជាន់អារក្ស...) ។ ផ្នត់គំនិតខ្មែរសម័យនោះ គឺ កូនស្រីត្រូវស្តាប់បង្គាប់ឪពុកម្តាយគ្រប់បែបយ៉ាង មិនត្រូវហ៊ានជំទាស់តវ៉ាទេ ពិសេសរឿងគូស្រករ ។

៣. កាលអាកាសនៃអត្ថបទដកស្រង់ ៖

+កាល : នៅយប់នោះ លុះដល់ព្រហាម នៅពេលរសៀល នៅពេលល្ងាចនោះ ថ្ងៃនេះ នៅអំឡុងកន្លះម៉ោង...

+អាកាស : ផ្ទះនាងវិធាវី

៤. ចំណុចដែលបញ្ជាក់ពីបញ្ហាជំនឿ សាសនា ប្រពៃណី ទំនៀមទម្លាប់ខ្មែរ ដែលជាអត្តសញ្ញាណជាតិខ្មែរ ក្នុងវគ្គដកស្រង់នេះ គឺការជឿលើការទស្សន៍ទាយ ការបញ្ជាន់អារក្ស ការស្រោចទឹក សែនព្រេន ពិធីស្តីដណ្តឹង...។

៥. តម្លៃអប់រំក្នុងវគ្គដកស្រង់ :

-កុំឱ្យជឿលើអបិយជំនឿហួសហេតុ

-ត្រូវជឿលើវិទ្យាសាស្ត្រជឿនលឿន ពិសេសផ្នែកវេជ្ជសាស្ត្រ

-មិនត្រូវបង្ខំកូនឱ្យរៀបការជាមួយអ្នកដែលកូនមិនស្រឡាញ់

-កុំឱ្យតម្លៃតែលើទ្រព្យសម្បត្តិតែមួយមុខ ត្រូវគិតអំពីសុភមង្គល

-ត្រូវហ៊ានតវ៉ាជាមួយម្តាយឪពុកក្នុងការរើសគូស្រករ (សិទ្ធិក្នុងការរើសគូស្រករ)

-ត្រូវចេះលើកបញ្ហាមកពិភាក្សា កុំលាក់ទុកតែក្នុងចិត្តម្នាក់ឯង...។

៦. វិធីផ្តើមរឿង និងបញ្ចប់រឿង ក្នុងរឿងផ្កាស្រពោន( រឿងទាំង-មូល) ៖

ក) វិធីផ្តើមរឿង: អ្នកនិពន្ធរៀបរាប់ពីធម្មជាតិនៅតាមព្រៃភ្នំនៃប្រទេសកម្ពុជា (រទេះភ្លើងបោលលឿនដូចព្យុះ កាត់ព្រៃខ្លុង និងព្រិច រត់ឆ្លងអូរ ហើយជ្រែកពុះជើងភ្នំ........)។

ខ) បញ្ចប់រឿង: អ្នកនិពន្ធបញ្ចប់រឿងដោយអស់សង្ឃឹម គឺតួអង្គឯកស្រីនាងវិធាវីស្លាប់ដោយរងទុក្ខក្រៀមក្រំចិត្ត ទាំងមិនបានជួបមុខគូសង្សារបណ្តូរចិត្ត។

## សព្វនាម

១– *សព្វនាម* ***គឺជាពាក្យដែលគេប្រើជំនួសនាម ឬកន្សោមនាម ដែលគេនិយាយរួចហើយ ដែលគេពុំទាន់និយាយ ឬសម្រាប់ចង្អុលបុគ្គលណាម្នាក់ ដែលគេប្រាស្រ័យទាក់ទងគ្នា ឬរបស់ណាមួយ... ដែលគេចង់បង្ហាញ...នៅក្នុងល្បះ ។*** សព្វនាមមានច្រើនប្រភេទ គឺ:

១. សព្វនាមបុរិស: : ខ្ញុំ គេ យើង ឯង វា អ្នក លោក...

២. សព្វនាមចង្អុល : នេះ នោះ អ្នកនេះ អ្នកនោះ...

៣. សព្វនាមសំណួរ : អ្នកណា អ្វី ណា ស្អី...

៤. សព្វនាមឈ្នាប់ : ដែល

៥. សព្វនាមមិនច្បាស់ : នរណាមួយ ណាមួយ អ្វីមួយ...

**លំហាត់**

១. **ចូររកពាក្យបង្ហាញសព្វនាមក្នុងល្បះខាងក្រោម ៖**

ក. តាសុខាលេងភ្លេងពិណពាទ្យ ។ គាត់លេងបានល្អ ហើយពិរោះថែមទៀត ។

ខ. បុប្ផាជាអ្នករបាំរីយកេង ។ វាពូកែរាំជាងគេ ។

គ. អ្នកណាមិនបានទៅលេងអង្គរវត្ត អ្នកនោះនឹងស្ដាយក្រោយ ។

ឃ. មីងចាន់កំពុងត្បាញក្រមា ។ គាត់ត្បាញបានលឿន ហើយល្អទៀតផង ។

២. **ចូរកំណត់ពីប្រភេទសព្វនាមនីមួយៗក្នុងល្បះខាងក្រោមឱ្យបានត្រឹមត្រូវ ៖**

ក. សំដាសិស្សដែលគេស្រលាញ់ចូលចិត្តជាងគេ ។

ខ. តើអ្នកត្រូវការសៀវភៅណាមួយ?

គ. តើលោកគ្រូត្រូវការសៀវភៅណាមួយ? សៀវភៅមួយនោះហើយដែលខ្ញុំត្រូវការ ។

ឃ. ពូមឿនជាជាងចម្លាក់ដ៏ល្បីម្នាក់ ។ គាត់មានទេពកោសល្យតាំងពីកំណើត ។

៣. **ចូរតែងល្បះទាក់ទងប្រភេទសព្វនាមទាំង៥ប្រភេទឱ្យបានមួយប្រភេទចំនួនមួយល្បះ ។**

**ចម្លើយ**

១. **សព្វនាមក្នុងល្បះ**

ក. គាត់

ខ. វា

គ. អ្នកណា. អ្នកនោះ

ឃ. គាត់

**២. ប្រភេទសព្វនាម**

ក. សំដាសិស្សដែលគេស្រលាញ់ចូលចិត្តជាងគេ ។

**"ដែល" សព្វនាមឈ្នាប់**

**"គេ" សព្វនាមបុរិសៈ**

ខ. តើអ្នកត្រូវការសៀវភៅណាមួយ?

**"អ្នក" សព្វនាមបុរិសៈ**

គ. តើលោកគ្រូត្រូវការសៀវភៅណាមួយ? សៀវភៅមួយនោះហើយដែលខ្ញុំត្រូវការ ។

**"នោះ" សព្វនាមចង្អុល**

ឃ. ពូមឿនជាជាងចម្លាក់ដ៏ល្បីម្នាក់ ។ គាត់មានទេពកោសល្យតាំងពីកំណើត ។

**"គាត់" សព្វនាមបុរិសៈ**

**៣. តែងល្បះទាក់ទងប្រភេទសព្វនាមទាំង៥ប្រភេទ**

ឧ-តារាជាកីឡាករឆ្នើម ។វាលេងបាល់បានល្អណាស់ ។ (សព្វ.បុរិស)

-**នេះ** ជាសៀវភៅរបស់ខ្ញុំ ។ (សព្វ. ចង្អុល)

-**អ្នកណា** រត់កាត់មុខផ្ទះ? (សព្វ. សំណួរ)

-សុខាជាសិស្ស **ដែល** រៀនពូកែជាងគេ។ (សព្វ. ឈ្នាប់)

-ខ្ញុំចង់អានសៀវភៅ ណា ដែលមានប្រយោជន៏។ (សព្វ. មិនច្បាស់)



# អក្សរខ្មែរ

## សំណួរ

១ តើអត្ថបទកាព្យខាងលើនេះ និពន្ធដោយនរណា?

២. តើអត្ថបទកាព្យនេះនិយាយពីអ្វី? គាត់តែងជាបទអ្វី?

៣. ចូរបង្ហាញចំណោប់ចួនក្នុងវគ្គទី១ និងទី២ ដោយគំនូសតាងបញ្ជាក់។

៤. ចូររកគំនិតសំខាន់នៃអត្ថបទកាព្យខាងលើ និងគំនិតអប់រំរបស់អ្នកនិពន្ធ។

## ចម្លើយ

១. អត្ថបទកាព្យខាងលើនេះ និពន្ធដោយសម្តេចព្រះសង្ឃរាជជួនណាត។

២. អត្ថបទកាព្យនេះនិយាយពីសារៈសំខាន់នៃអក្សរខ្មែរ។
គាត់តែងជាបទពាក្យ៧។

៣. ចំណាប់ចួនក្នុងវគ្គទី១ និងទី២

-វគ្គទី១: ព្យ.៧ ឃ.១ ├──┤ ព្យ.៤ ឃ.២
ព្យ.៧ ឃ.៣ ├──┤ ព្យ.២ ឃ.៤ ├──┤ ព្យ.៧ ឃ.៣

-វគ្គទី២: ព្យ.៧ ឃ.១ ├──┤ ព្យ.៤ ឃ.២
ព្យ.៧ ឃ.៣ ├──┤ ព្យ.៤ ឃ.៤ ├──┤ ព្យ.៧ ឃ.៣

-ចួនឆ្លងវគ្គ: ព្យ.៧ ឃ.៤ វ.១ ├──┤ ព្យ.៧ ឃ.៤ វ.២



៤. •គំនិតសំខាន់នៃអត្ថបទកាព្យនេះនិយាយអំពី ៖

-និយាយពីចំណេះកើតឡើងដោយការខិតខំ ប្រឹងប្រែងរៀនសូត្រ និងត្រូវរៀនឱ្យបានច្បាស់លាស់ ដើម្បីទទួលបានចំណេះដឹងពិតប្រាកដ ។

-សារៈសំខាន់នៃភាសាខ្មែរ ក្នុងការចាប់យកភាសាបរទេស

•គំនិតអប់រំរបស់អ្នកនិពន្ធ :

-ត្រូវខិតខំរៀនសូត្រ

-កុំខ្ជិលច្រអូស

-ត្រូវចេះពិចារណា ឱ្យបានគ្រប់ជ្រុងជ្រោយ

-រៀនភាសាគេ កុំភ្លេចភាសាជាតិខ្លួន (លើកកម្ពស់ភាសាជាតិ)

-ត្រូវចេះសួរនាំនូវចំណុចដែលមិនយល់

-ត្រូវរៀនអ្វីឱ្យប្រាកដ និងត្រឹមត្រូវតាមក្បួនខ្នាត



# រឿងទំនៀមចោះត្រចៀកកូនស្រី

**សំណួរ**

១. តើរឿងនេះដកស្រង់ពីណា? និយាយពីអ្វី?

២. ចូរបង្ហាញពីចំណោទបញ្ហា និងកាលអាកាសរបស់រឿងនេះ ។

៣. តើរឿងនេះកើតឡើងក្នុងសម័យកាលណា?

៤. ហេតុអ្វីបានជាស្រីៗនាំគ្នាចោះត្រចៀកតាមនាងប្រពន្ធចុង? តើអ្នកយល់ដូចម្ដេច?

៥. តើចំណុចត្រង់ណាខ្លះបញ្ជាក់អត្តសញ្ញាណជាតិខ្មែរ?

**ចម្លើយ**

១. រឿងនេះដកស្រង់ពីសៀវភៅប្រជុំរឿងព្រេងខ្មែរភាគ៩ ។ រឿងនេះ និយាយពីមូលហេតុ និងទំនៀមចោះត្រចៀកកូនស្រី ។

២. **+ចំណោទបញ្ហានៅក្នុងរឿងនេះ** ស្ថិតនៅត្រង់ចំណុចដែលនាងប្រពន្ធដើមបានដឹងរឿងរ៉ាវសាហាយស្មន់នឹងប្ដីរបស់ខ្លួន ក៏ចាប់វាយធ្វើបាបនាងប្រពន្ធចុងនិងយកដែកគោលមកចោះត្រង់ចុងស្លឹកត្រចៀកទាំងពីររបស់នាងប្រពន្ធចុងទុកជាការព្រមាន ។

**+កាលអាកាសរបស់រឿង**

-កាល : កាលកន្លងទៅយូរយារ លុះយូរទៅ ថ្ងៃមួយ

លុះវេលាល្ងាច ចាប់តាំងពីថ្ងៃនោះមក នៅយប់មួយ លុះថ្ងៃក្រោយមក ចាប់តាំងពីសម័យនោះ សព្វថ្ងៃនេះ...

-អាកាស : ផ្ទះកុដុម្ពីក៏ ស្រុកក្រៅ...

៣. រឿងនេះកើតឡើងតាំងពីសម័យបុរាណមកម្ល៉េះ ។ *តាមទំនៀមពីបុរាណកាលមក ក្មេងស្រីៗសុទ្ធតែចោះត្រចៀកគ្រប់គ្នាទាំងអស់ ។*

៤. បានជាស្រីៗនាំគ្នាចោះត្រចៀកតាមនាងប្រពន្ធចុង ព្រោះឃើញនាងប្រពន្ធចុងពាក់ពេជ្រមានពន្លឺភ្លឺផ្លេកៗ គួរឱ្យស្រឡាញ់ ។

ខ្ញុំយល់ថា ការចោះត្រចៀកកូនស្រីនេះ ជាទំនៀមទម្លាប់របស់ខ្មែរយើងដែលមានតាំងពីសម័យកំណាកំណើតរឿងព្រេងនេះមកម្ល៉េះ ។ គេធ្វើបែបនេះដើម្បីដាក់ទណ្ឌកម្មដល់ស្ត្រីដែលលួចសាហាយស្មន់ជាមួយនឹងប្ដីគេឱ្យរាងចាល ។ ប៉ុន្តែបុព្វបុរសខ្មែរក៏ប្រែក្លាយទណ្ឌកម្មដ៏អាក្រក់នោះឱ្យទៅជារឿងល្អវិញដោយអ្នកនិពន្ធរឿងធ្វើឱ្យភាពតានតឹងក្នុងគ្រួសារក្លាយជាធូរស្រាលវិញ ដោយនាងប្រពន្ធដើមនិងស្រីៗដទៃទៀតឈប់ខឹងសម្បារនឹងឈប់ចងពៀរនឹងនាងប្រពន្ធចុង ហើយបែរជានាំគ្នាចោះត្រចៀកតាមនាងនោះវិញ ។ តាមពិតទៅការធ្វើបែបនេះជាការឆោតល្ងង់ តែទោះជាយ៉ាងក៏ដោយ ក៏អ្នកនិពន្ធចេះយកភាពឆោតល្ងង់នេះមកដោះស្រាយបញ្ហារឿងឱ្យចប់ទៅតាមសន្តិវិធី ។

៥. ចំណុចដែលបញ្ជាក់ពីអត្តសញ្ញាណជាតិខ្មែរ គ្រង់ចូលចិត្តយកគ្រឿងអលង្ការមកតុបតែងលំអខ្លួន ដូចជាខ្សែដៃ ចិញ្ចៀន ក្រវិល ខ្សែក. ។ គេឃើញទម្លាប់ចោះត្រចៀកនេះនៅរូបចម្លាក់នៅតាមប្រាសាទនានានៅស្រុកខ្មែរ ។

## ការនិយាយបញ្ចេញមតិផ្ទាល់ខ្លួន

*ចំ— ការបញ្ចេញមតិ គឺជាការនិយាយ សំដែង ឬបង្ហាញឱ្យឃើញនូវ គំនិត យោបល់ ឬទស្សនៈរបស់មនុស្សម្នាក់ៗចំពោះទង្វើ សកម្មភាព រឿងរ៉ាវ មតិយោបល់...របស់អ្នកដទៃ តាមរយៈពាក្យសំដី ឬ សំណេរ ។*

**លំហាត់**

ចូរអ្នកបញ្ចេញមតិផ្ទាល់ខ្លួនចំពោះ ៖

១. ការចោះត្រចៀកពាក់ក្រវិលរបស់បុរសខ្មែរនាសម័យបច្ចុប្បន្ន ។

២. ការខិតខំរកគ្រូ និងថ្នាំព្យាបាលជំងឺនាងវិធាវីពីសំណាក់ក្រុមគ្រួសាររបស់នាង ។

ចម្លើយ

១. ចំពោះការចោះត្រចៀកពាក់ក្រវិលរបស់បុរសខ្មែរសម័យបច្ចុប្បន្ននេះ ខ្ញុំយល់ថា វាមិនមែនជាការល្អទេ ។ ទង្វើនេះធ្វើឱ្យខូចដល់ប្រពៃណីសីលធម៌ដ៏ល្អរបស់ខ្មែរតាំងពីយូរលង់ណាស់មកហើយ ។ តាំងពីដើមឡើយគឺមានតែកូនស្រីទេដែលចោះត្រចៀក ពាក់ក្រវិលដើម្បីពាក់គ្រឿងអលង្ការលំអ និងបង្ហាញពីអត្តសញ្ញាណខ្មែរ ។ ដូច្នេះទង្វើរបស់ពួកប្រុសៗសម័យនេះជាការខុសឆ្គងធ្ងន់ណាស់ ត្រូវតែផ្លាស់ប្តូរ គោរពប្រពៃណីខ្មែរយើងវិញដើម្បីលើកស្ទួយមោទនភាពជាតិ ។

២. ចំពោះការខិតខំរកគ្រូ និងថ្នាំព្យាបាលជំងឺនាងវិធាវីពីសំណាកក្រុមគ្រួសាររបស់នាង ខ្ញុំយល់ថាជាសកម្មភាពចាស់គំរិលមួយ និងហួសសម័យទៅហើយ ព្រោះមានតែគ្រូពេទ្យទេដែលអាចដឹងពីប្រភេទជំងឺបាន ។ ម្យ៉ាងទៀត ដំណើររឿងក៏បានបញ្ជាក់ហើយថាជំងឺនាងវិធាវីបណ្តាលមកពីផ្លូវចិត្ត ដែលនាងត្រូវព្រាត់ពីសង្សារបណ្តូរចិត្ត ដូច្នេះបើម្តាយនាងយល់ពីទឹកចិត្តនាងនោះ ជំងឺនាងប្រាកដជាឆាប់ជាវិញមិនខាន ។

មេរៀនទី ៣

# ការគោរពបូជា

## លក្ខណៈសំគាល់របស់រឿងបែបព្រាហ្មណ៍និយម

*១– អក្សរសិល្ប៍ព្រាហ្មណ៍និយម គឺជាអត្ថបទអក្សរសិល្ប៍ណាដែលមានទំនាក់ទំនងទៅនឹងលទ្ធិសាសនាព្រាហ្មណ៍ ដោយការផ្ដើមរឿងច្រើនលើកសរសើរពីឫទ្ធិអំណាចរបស់ព្រះឥសី ព្រះឥសូរ ទេវៈ អាទិទេពជាដើម ។ ឯតួរឿង ឬដំណើររឿងមានភាពអច្ឆរិយៈហួសហេតុ ហើយតួអង្គប្រុស ជាអវតារនៃព្រះនារាយណ៍ ស្ត្រីជាកំពូលនារីល្អឯក និងបញ្ចប់រឿង អ្នកនិពន្ធបញ្ចប់ដោយឱ្យសភាវៈល្អសភាវៈអាក្រក់ ។*

**លំហាត់**

តើអត្ថបទដកស្រង់ខាងក្រោមនេះ ចំណុចណាខ្លះ ដែលបញ្ជាក់ថា រឿងនេះជាអក្សរសិល្ប៍បែបព្រាហ្មណ៍និយម?

(អត្ថបទដកស្រង់រឿងរាមាយណៈ)

**ចម្លើយ**

ចំណុចដែលបញ្ជាក់ថារឿងខាងលើជាអ.សិ.បែបព្រាហ្មណ៍និយម ព្រោះ ៖

-តួអង្គ : ស្វា (ហនុមាន) យក្ស (រាវណៈ) ទេវតា អាទិទេព (ព្រះរាមៈ) ព្រះឥន្ទ្រ ឥសី...

-ដំណើររឿង : ច្បាំងគ្នាយ៉ាងសាហាវ ប្រកបដោយសិល្ប៍ វេទមន្ត ចេះហោះហើរ...។ ពេលព្រះរាមច្បាំងឈ្នះរាវណៈ មានទេវតាអបអរសាទរ ។

-ទីកន្លែង : លើអាកាស ឋានកណ្ដាល នគរយក្ស...

-បញ្ចប់រឿង : ព្រះរាម (តំណាងអាទិទេព) ឈ្នះរាវណៈ (តំណាងសភាវៈអាក្រក់)

# ព្រះរាមលើកធ្នូ

## សំណួរ

១ តើអត្ថបទកាព្យនេះ មានចំណងជើងដូចម្ដេច? ដកស្រង់ចេញពីរឿងណា? ក្នុងខ្សែទីប៉ុន្មាន? បោះពុម្ពផ្សាយក្នុងឆ្នាំណា?

២. ចូរបង្ហាញកាលកំណត់តែង និងសង្គមបរិយាកាសក្នុងរឿង ។

៣. តើក្នុងអត្ថបទដកស្រង់នេះ អ្នកនិពន្ធប្រើវិធីតែងនិពន្ធអ្វីខ្លះ?

៤ តើអត្ថបទដកស្រង់រឿងរាមកេរ្តិ៍ស្ថិតក្នុងអក្សរសិល្ប៍ប្រភេទណា? ចូរបង្ហាញលក្ខណៈសំគាល់របស់រឿងនេះ ។

៥. ចូរបង្ហាញពីគំនិតសំខាន់ៗនៅក្នុងអត្ថបទ ។

## ចម្លើយ

១. អត្ថបទកាព្យនេះមានចំណងជើងថា ព្រះរាមលើកធ្នូ ដកស្រង់ចេញពីរឿងរាមកេរ្តិ៍ ក្នុងខ្សែទី១ បោះពុម្ពផ្សាយក្នុងគ.ស. ១៩៩៥ ។

២. បង្ហាញកាលកំណត់តែង និងសង្គមបរិយាកាសក្នុងរឿង ៖

+ **កាលកំណត់តែង**

-ខែទី១-១០ នៅស.វ.ទី១៧-១៨

-ខែទី៧៥-៨០ នៅស.វ.ទី១៨-១៩

( ទស្សនៈរបស់លោកញ៉ុក ថែម )

ឯកសារដែលយកមកសិក្សាគឺរៀបរៀងឡើងដោយអ្នកអង្គម្ចាស់ **វឌ្ឍឆាយាវង្ស** ដែលត្រូវបានបោះពុម្ពផ្សាយវិជ្ជាស្ថានពុទ្ធសាសនបណ្ឌិតនៃក្រសួងធម្មការ បោះពុម្ពលើកទី១ នៅ ព.ស. **២៤៨០ គ.ស.១៩៣៧**។

+ **សង្ខេបវិយាកាស :** អត្ថបទខាងលើនេះឆ្លុះបញ្ចាំងពីប្រពៃណីទំនៀមទម្លាប់ពិធីច្រត់ព្រះនង្គ័ល ការល្បងសមត្ថភាពកូនប្រុស និងពិធីរៀបការ ដែលប្រារព្ធឡើងនៅគេហដ្ឋានខាងស្រី ។

៣. ក្នុងអត្ថបទដកស្រង់នេះ អ្នកនិពន្ធប្រើវិធីតែងនិពន្ធ

-ពណ៌នាវិធី : "ដងនោះនគរមិថិលា ស្តេចធ្វើចរិយា..." ។

-**រចនាវិធី : អ្នកនិពន្ធរៀបរៀងជាពាក្យកាព្យបទពំនោល ។**

-**វចនវិធី : អ្នកនិពន្ធប្រើពាក្យពេចន៍ពិបាកអាន ពិបាកយល់ដូចជាពាក្យខ្មែរបុរាណ ពាក្យបាលី សំស្ក្រឹត**

-បដិវិធី : គ្មាននរណាលើកធ្នូសរព្រះបាទជនករួចទេ តែព្រះរាមអាចលើករួច។

៤. អត្ថបទដកស្រង់រឿងរាមកេរ្តិ៍ស្ថិតក្នុងអក្សរសិល្ប៍ព្រាហ្មណ៍និយម លក្ខណៈសំគាល់របស់រឿងនេះមាន ៖

**-ផ្តើមរឿង :** មានរៀបរាប់ពីឈ្មោះអាទិទេពធំៗទាំងបី គឺព្រះព្រហ្ម ព្រះនារាយណ៍ ព្រះឥសូរ និងមានពិធីបូជាយញ្ញ ឬពិធីផ្សេងៗ។

**-តួរឿង :**

- តួអង្គ : អាទិទេព ទេវតា យក្ស ស្វា គ្រុឌ ឥសី អវតារព្រះវិស្ណុ ស្រីស្អាតជាច់គេ...។
- ដំណើររឿង : មានភាពអស្ចារ្យ ចម្បាំងរាំងជល់ ប្រើយុទ្ធសិល្ប៍ មន្តអាគម ចេះហោះ ចេះហើរលើអាកាស ជប ថ្លែងសរ...។
- ទីកន្លែងនៃរឿង : ព្រៃហេមពាន្ត ឋានសួគ៌ ឋានបាតាល ក្រុងពួយុធ្យា ឋានសិម្ពលី...។
- ដំណោះស្រាយ : ប្រើមន្តអាគម ឫទ្ធិអំណាច សងសឹក ច្បាំងគ្នា...។
- ស្នេហា : អ្នកឈ្នះ ឬអ្នកខ្លាំង ទទួលបានស្នេហា...។

- ទំនាស់ : កើតឡើងដោយវិបត្តិទំនាស់រវាងសភាវៈល្អ និងសភាវៈអាក្រក់ ។
- ឧត្តមគតិរឿង : អប់រំឱ្យជឿលើអាទិទេព អ្វីៗអាទិទេពជាអ្នកកំណត់ ។

**-បញ្ចប់រឿង** : សភាវៈល្អ ឈ្នះសភាវៈអាក្រក់ ។

៥. គំនិតសំខាន់ៗនៅក្នុងអត្ថបទ គឺៈ

- ប្រារព្ធពិធីច្រត់ព្រះនង្គ័ល
- មានការបួងសួងសុំសេចក្តីសុខ
- ការជ្រើសរើសគូស្រករឱ្យកូនស្រី
- ការគោរពពាក្យសន្យា
- មង្គលការប្រព្រឹត្តទៅនៅគេហដ្ឋានខាងស្រី
- ការជឿលើអាទិទេព

## ខ្លឹមសារអត្ថបទ

*១- ខ្លឹមសារអត្ថបទ គឺជាគំនិតសំខាន់ៗទាំងអស់ដែលរៀបរាប់នៅក្នុងអត្ថបទ ។*

**ចម្លើយលំហាត់**

បង្ហាញខ្លឹមសារនៃអត្ថបទ

ក. ( អត្ថបទដកស្រង់ពីសៀវភៅអ្នកនិពន្ធខ្មែរ ភិរម្យ ង៉ុយ)

-ឱ្យចេះស្ដាយកេរ្ដិ៍ឈ្មោះរបស់ឪពុកម្ដាយ

-កុំប្រព្រឹត្តអំពើខុសច្បាប់

-ត្រូវចេះស្ដាប់ពាក្យទូន្មានរបស់ឪពុកម្ដាយ

-កុំថ្កោលទោសអ្នកមានគុណ ទោះបីឃើញគាត់ខុសក៏ដោយ

-កុំចចេស មាត់រឹងតវ៉ាជាមួយឪពុកម្ដាយ

-ត្រូវចេះប្រើពាក្យសំដី ពិរោះ ផ្អែមល្ហែម ។

ខ. ( អត្ថបទដកស្រង់ពីសៀវភៅ ធ្វើម្ដេចទើបប្រទេសជាតិរីកចំរើន)

-ភាពអសកម្មដែលរាំងស្ទះដល់ការរីកចម្រើន ។

## ចលនាអក្សរសិល្ប៍

*១- ចលនាអក្សរសិល្ប៍ គឺជាដំណើរប្រែប្រួលនៃអក្សរសិល្ប៍តាមការនិយមនៃវណ្ណៈ ឬស្រទាប់សង្គមលើទ្រឹស្តី ទស្សនៈ គោលគំនិតណាមួយក្នុងដំណាក់កាលនៃប្រវត្តិសាស្ត្រ ។* គេអាចចែកចលនាអក្សរសិល្ប៍ជាបួន ប្រភេទ គឺ ៖

-ចលនាអ.សិ. ព្រាហ្មណ៍និយម

-ចលនាអ.សិ. ពុទ្ធនិយម

-ចលនាអ.សិ. ខេមរនិយម

-ចលនាអ.សិ. បរទេសនិយម

**លំហាត់**

១. តើគេអាចចែកចលនាអ.សិ. ជាប៉ុន្មានប្រភេទ? អ្វីខ្លះ?

២. ដូចម្ដេចដែលហៅថាចលនាអ.សិ. ព្រាហ្មណ៍និយម ? ពុទ្ធនិយម ? ខេមរនិយម? បរទេសនិយម?

៣. ក្នុងបណ្ដារឿងខាងក្រោមនេះ រឿងណាដែលស្ថិតនៅក្នុងចលនាអ.សិ. ព្រាហ្មណ៍និយម ពុទ្ធនិយម និងខេមរនិយម ដូចជារឿង មរណមាតា កុលាបប៉ៃលិន. អ្នកតាទឹកអ្នកតាភ្នំ. មាយាស្ត្រី. មាយើង. ពុទ្ធិសែននាងកង្រី. ក្រុងសុភមិត្រ. ស៊ុមអ្នកបរឡាន. រាមកេរ្តិ៍.

រាមាយណៈ, វេស្សន្តរ, ទុំទាវ ។

**ចម្លើយ**

១. គេអាចចែកចលនាអ.សិ. ជា៤ប្រភេទ គឺ :

-ចលនាអ.សិ. ព្រាហ្មណ៍និយម

-ចលនាអ.សិ. ពុទ្ធនិយម

-ចលនាអ.សិ. ខេមរនិយម

-ចលនាអ.សិ. បរទេសនិយម

២. ដែលហៅថាចលនា **អ.សិ. ព្រាហ្មណ៍និយម** គឺជាស្នាដៃអ.សិ. ទាំងឡាយណាដែលមានទំនាក់ទំនងទៅនឹងលទ្ធិសាសនាព្រាហ្មណ៍ ។ អ.សិ.បែបនេះគេតែងជឿលើអាទិទេពមានព្រះព្រហ្ម ព្រះឥសូរ ព្រះនារាយណ៍ ។

**អ.សិ. ពុទ្ធនិយម** គឺជាអត្ថបទរឿងរ៉ាវផ្សេងៗដែលទាក់ទងនឹងការលើកយកទ្រឹស្តីពុទ្ធសាសនាធ្វើជាគោល ហើយទ្រឹស្តីទាំងនោះស្ថិតនៅក្នុងគម្ពីរព្រះត្រៃបិដក ដែលអ្នកនិពន្ធលើកយកបញ្ហាបុណ្យ បាប ផលល្អ អាក្រក់របស់តួអង្គមកចោទ និងដោះស្រាយ ។

**អ.សិ. ខេមរនិយម** គឺជាស្នាដៃទាំងឡាយណាដែលពុំបានយកគោលពីលទ្ធិ ឬសាសនាណាឡើយ គឺជាការប្រឌិតតាម

ការណ៍ដែល គេធ្លាប់ឃើញពិតជាក់ស្តែងក្នុងសង្គមជាតិខ្មែរតែម្តង ។

**អ.សិ. បរទេសនិយម** គឺជាអ.សិ.ដែលអ្នកនិពន្ធលើកយករឿងបរទេសផ្សេងៗមកបកប្រែជាភាសាជាតិ ឬក៏និពន្ធដោយចម្លងតាម ដោយរក្សាទុកទំនៀមទម្លាប់ ប្រពៃណី លក្ខណៈរបស់បរទេសសុទ្ធសាធ ។

៣. +រឿងដែលស្ថិតនៅក្នុងចលនាអ.សិ.ព្រាហ្មណ៍និយម មានរឿង : រាមកេរ្តិ៍ រាមាយណៈ

+រឿងដែលស្ថិតនៅក្នុងចលនាអ.សិ.ពុទ្ធនិយម មានរឿង: វេស្សន្តរ មរណមាតា ក្រុងសុភមិត្រ ពុទ្ធិសែននាងកង្រី

+រឿងដែលស្ថិតនៅក្នុងចលនាអ.សិ.ខេមរនិយមមានរឿង : ទុំទាវ កុលាបប៉ៃលិន ស៊ឹមអ្នកបរឡាន មាយាស្ត្រី មាយើង អ្នកតាទឹកអ្នកតាភ្នំ ។



# លក្ខណៈនៃភាសាខ្មែរ

## សំណួរ

១. តាមអត្ថបទ តើភាសាជាអ្វី? ភាសាមានអំបូរធំៗប៉ុន្មាន?

២. តើក្នុងអំបូរខ្មែរ-មន មានជនជាតិអ្វីខ្លះ? នៅណាខ្លះ?

៣. តើភាសាខ្មែរមានអភិវឌ្ឍន៍ធំៗប៉ុន្មានលើកហើយ?

៤. តើល្បាយភាសាបរទេសនៅក្នុងភាសាខ្មែរកើតឡើងតាមរយៈអ្វីខ្លះ?

៥. តើភាសាខ្មែរយើងមានលក្ខណៈពិសេសធំៗអ្វីខ្លះដែលខុសប្លែកពីភាសាបរទេស?

៦. ចូររកតម្លៃអប់រំនៅក្នុងអត្ថបទ ។

## ចម្លើយ

១. តាមអត្ថបទ ភាសាគឺជាពាក្យសំដីដែលយើងនិយាយប្រាស្រ័យទាក់ទងគ្នាទៅវិញទៅមក ដើម្បីសំដែងនូវឆន្ទៈ សញ្ចេតនា ចិត្តគំនិតអ្វីមួយ ។ ភាសាមានអំបូរធំៗចំនួន២០ ។

២. ក្នុងអំបូរខ្មែរ-មន ក្រៅពីជាតិខ្មែរ និងជាតិមន នៅមានជនជាតិផ្សេងទៀតដូចជា :

-សេណូយសេម៉ាង...នៅសហព័ន្ធម៉ាឡេស៊ីយ៉ា

-ប៉ាឡោវ៉ា...នៅប្រទេសភូមា

-ខ្មុ អាឡាក់ល្មិត...នៅប្រទេសលាវ

-ស្មៀង ក្អយ ព័រ ស្ទួច ជង ព្នង...នៅប្រទេសខ្មែរ

-ម្នង បាហ្នារ សេដង់ព្រុ... នៅប្រទេសវៀតណាម ។

៣. ភាសាខ្មែរមានអភិវឌ្ឍន៍ធំៗ៣លើកហើយ ។

-ភាសាខ្មែរបុរាណ ( តាំងពីកំណកំណើត មកដល់ស.វ.ទី១៥)

-ភាសាខ្មែរកណ្ដាល ( ស.វ.ទី១៦ ដល់១៩)

-ភាសារខ្មែរបច្ចុប្បន្ន ( ស.វ.ទី២០ ដល់បច្ចុប្បន្ន)

៤. ល្បាយភាសាបរទេសនៅក្នុងភាសាខ្មែរកើតឡើងតាមរយៈទំនាក់ទំនងជាមួយបរទេសដូចជាទាក់ទងក្នុងកិច្ចការទូត ទេសចរណ៍ ពាណិជ្ជកម្ម សិក្សាអប់រំ ជំនឿសាសនា ។ល ។

៥. ភាសាខ្មែរយើងមានលក្ខណៈពិសេសធំៗដែលខុសប្លែកពីភាសាបរទេស គឺ ៖

-ការបន្លឺសំឡេង : ពុំមានឡើងចុះ ឬលើកដាក់ខ្ពស់ ទាបឡើយ

-ចំនួនព្យាង្គ : តិច ( មួយឬពីរព្យាង្គ)

-ការបង្កើតពាក្យ : មាន

+វិធីកំលាយ

+វិធីកំចី

+វិធីបន្សំ

-មូលភេទ អ-អ៊ី ៖ ទាំងស្រៈ ទាំងព្យញ្ជនៈ

-មានពាក្យគន្លាស់កាត់

-ស្រៈមានសូរច្រើន តែមានសញ្ញាស្រៈតិច

-ព្យញ្ជនៈមានសូរតិច តែមានសញ្ញាព្យញ្ជនៈច្រើន

-គ្មានទម្រង់ពាក្យ គ្មានភេទ គ្មានវចនៈ...

៦. តម្លៃអប់រំនៅក្នុងអត្ថបទ ៖

- ឱ្យកូនខ្មែរបានស្គាល់ច្បាស់លាស់ និងយល់ត្រឹមត្រូវនូវភាសារបស់ខ្លួន
- ស្រលាញ់និងអភិវឌ្ឍភាសាជាតិឱ្យមានជីវិត និងវិវត្តន៍ត្រឹមត្រូវតាមក្បួនខ្នាត
- ឱ្យស្គាល់ពីដើមកំណើតនៃភាសាខ្មែរ.............

# គុណនាម

១– *គុណនាម គឺជាសព្ទដែលប្រើសម្រាប់ថែងសភាពលក្ខណៈរបស់នាម ។*

ប្រភេទគុណនាម មាន ៖

**-គុណនាមប្រក្រតី** (បកតិគុណនាម): ស ខ្មៅ ល្អ អាក្រក់ ខ្ពស់...

**-គុណនាមកំណត់**

- គុ. កម្មសិទ្ធិ : ខ្ញុំ យើង អញ អ្នក លោក វា នាង...
- គុ. សំណួរ : ណា ប៉ុន្មាន ស្អី អ្វី អ្វីខ្លះ...
- គុ. ចំនួន :
  - ចំនួនរាប់ : មួយ ពីរ បី...
  - ចំនួនរៀប : ទីមួយ ទីពីរ ទីបី...
- គុ. ចង្អុល : នេះ នោះ ទីនេះ ទីនោះ ...
- គុ. មិនច្បាស់ : ណា ណាមួយ  ខ្លះ ដទៃ ទាំងអស់...

**ចម្លើយលំហាត់**

១. ចូរស្រង់គុណនាមក្នុងល្បះខាងក្រោមដោយប្រាប់ប្រភេទរបស់វា ៖

-ការជក់បារីនាំឱ្យរាងកាយចុះស្គម និងខ្សោយកម្លាំង ។

-នៅក្នុងក្រោលនេះមានគោឈ្មោលប្រាំនឹម ។ គោញីបីក្បាល និងកូនគោម្ភៃក្បាល ។

-ប្អូនសុខឈរទីមួយ ។ ប្អូនសៅឈរទីពីរ ។ បូផាឯងឈរគម្រប់បី ។ ឯកុមារនោះឈរគម្រប់បួន ។

-តើប្អូនទៅសាលាណា?

-សៀវភៅនេះជារបស់ឯង ឯសៀវភៅនោះជារបស់ខ្ញុំ ។

-ក្មួយៗពុំចូលចិត្តអានសៀវភៅណាដែលនាំទៅរកផ្លូវខុសទេ តែចូលចិត្តសៀវភៅណាដែលនាំឱ្យចម្រើន ។

+គុ. ប្រក្រតី : ស្គម ខ្សោយ

+គុ. កម្មសិទ្ធិ : ខ្ញុំ ឯង

+គុ. សំណួរ : ណា

+គុ. ចង្អុល : នេះ នោះ

+ គុ. ចំនួន

-ចំនួនរាប់ : ប្រាំ បី ម្ភៃ

-ចំនួនរៀប : ទីមួយ ទីពីរ គម្រប់បី គម្រប់បួន

+គុ. មិនច្បាស់ : ណា

២. គុណនាមក្នុងអត្ថបទ

+គុ. ប្រក្រតី : ខ្ពី ច្រើន តិច

+គុ. ចង្អុល : នេះ ទាំងអស់នេះ

+ គុ. ចំនួន : ១៥ឆ្នាំ



# រឿងសិរិធរ

**សំណួរ**

១. តើសេដ្ឋីសិរិធរជាមនុស្សដូចម្ដេច?

២. តើគាត់បានប្រគេនអ្វីដល់ព្រះបច្ចេកពុទ្ធ? តើគាត់ទទួលផលល្អអ្វីខ្លះ?

៣. ចូរបង្ហាញកាលអាកាសនៅក្នុងអត្ថបទ ។

៤. តើរឿងសិរិធរស្ថិតនៅក្នុងចលនាអក្សរសិល្ប៍ណា?

៥. តើអត្ថបទនេះបង្ហាញខ្លឹមសារអ្វីខ្លះ?

**ចម្លើយ**

១. សេដ្ឋីសិរិធរជាមនុស្សមានចិត្តសប្បុរស ធ្វើទានរក្សាសីលជាប្រចាំ ព្រមទាំងមានចិត្តជ្រះថ្លាក្នុងការដាក់ទាន ។

២. គាត់បានប្រគេនអាហារដល់ព្រះបច្ចេកពុទ្ធ ហើយគាត់ក៏ទទួលបានទិព្វភោជនពេញភាជន៍ភត្តរបស់សេដ្ឋីយ៉ាងអស្ចារ្យ មានក្លិនក្រអូបផ្សាយផ្សព្វទូទៅ ។

៣. កាលអាកាសនៅក្នុងអត្ថបទ ៖

+កាល : កាលពីព្រេងនាយ តម្រប់៧ថ្ងៃ នៅពេលបាយព្រឹក...

+អាកាស : ក្រុងពារាណសី ផ្ទះសិរិធរសេដ្ឋី ឋានទេវលោក...

៤. រឿងសិរិធរស្ថិតនៅក្នុងចលនាអក្សរសិល្ប៍ពុទ្ធនិយម ។

៥. ខ្លឹមសារអត្ថបទនេះ "ការបំពេញកុសលដោយសប្បុរសក្នុងផ្លូវព្រះពុទ្ធសាសនាដើម្បីបានសេចក្តីសុខក្នុងបច្ចុប្បន្នជាតិ និងអនាគតជាតិ ។



# ការបញ្ចេញមតិគាំទ្រ

## សំណួរ

១. តើប្រធានបទនៃអត្ថបទនេះនិយាយពីអ្វី?

២. តើទស្សនៈអប់រំនៅក្នុងពុទ្ធសាសនាមានលក្ខណៈដូចម្ដេចខ្លះ?

៣. គោលដៅនៃការប្រៀនប្រដៅតាមព្រះពុទ្ធសាសនា បើគេធ្វើការសង្ខេប តើមានប៉ុន្មានចំណុច? អ្វីខ្លះ?

៤. ក្នុងចំណោមដំបូន្មានទាំងបី តើដំបូន្មានណាមួយដែលមានទស្សនៈអប់រំល្អជាងគេ?

## ចម្លើយ

១. ប្រធានបទនៃអត្ថបទនេះ និយាយពីតួនាទីព្រះពុទ្ធសាសនាដើម្បីសន្តិភាព" ។

២. ទស្សនៈអប់រំនៅក្នុងពុទ្ធសាសនាមានលក្ខណៈដូចតទៅ៖

- អហិង្សា គឺការមិនចងកំហឹង មិនត្រូវយកកំហឹងទៅដោះស្រាយបញ្ហា
- បណ្ដុះគំនិតស្រឡាញ់សន្តិភាព ទាំងកាយទាំងចិត្ត
- ចេះកសាងអំពើល្អ
- មិនបៀតបៀនគ្នា មិនចងគំនុំគ្នា
- ចេះបំពេញកុសលសង្គ្រោះគ្នាទៅវិញទៅមក

- យល់ថាសុខទុក្ខកើតឡើងដោយសារខ្លួនឯង....

៣. គោលដៅនៃការប្រៀនប្រដៅតាមព្រះពុទ្ធសាសនា បើគេធ្វើការសង្ខេប មានចំណុចសំខាន់១បី គឺ :

-ហាមធ្វើអ្វីដែលបានបាប ជាអំពើអាក្រក់ដល់គ្នានឹងគ្នា ជាហេតុនាំឱ្យមនុស្សដូចគ្នាមានទុក្ខ ទារុណកម្ម វេទនា ខ្លោចផ្សាគ្រប់បែបយ៉ាង ។

-ឱ្យបំពេញតែអំពើណាដែលជាកុសល ជាសេចក្ដីល្អដល់គ្នានឹងគ្នា ដោយសាងអំណោយទាន ។

-ឱ្យធ្វើចិត្តឱ្យស្អាតស្អំ ប្រាសចាកអំពើសៅហ្មង ឱ្យកុំឱ្យមានគំនិតគុំកួន ឬព្យាបាទចងកំហឹងនឹងគ្នា ។

៤. ក្នុងចំណោមដំបូន្មានទាំងបី ដំបូន្មានដែលមានទស្សនៈអប់រំល្អជាងគេគឺដំបូន្មានទីបី ព្រោះជាគំនិតខ្ពស់ចៀសផុតពីអំពើសៅហ្មង ។

# ប្រធានរឿង ឬមូលន័យ និងមូលបញ្ហា

*១– ប្រធានរឿង ឬមូលន័យ គឺជាគំនិតសំខាន់ៗរបស់រឿង ឬជាបញ្ហាធំរបស់រឿង ដែលអ្នកនិពន្ធចង់បង្ហាញដល់អ្នកអាន ។*

*មូលបញ្ហារឿង ជាគំនិតៗ បញ្ហាចំបងៗ ដែលទាក់ទងនឹងប្រធានបទរបស់រឿង ឬអត្ថបទ ។ មូលបញ្ហារឿងមានតិច ឬច្រើនអាស្រ័យលើដំណើររឿង ។*

**លំហាត់**

ចូរអ្នករកប្រធានរឿង និងមូលបញ្ហារបស់រឿងខាងក្រោម ៖

១. រឿងកំណើតទីក្រុងភ្នំពេញ ( ប្រជុំរឿងព្រេងខ្មែរ ភាគ៥)

២. រឿងភ្នំបាយ៉ង់កោរ នៅខេត្តតាកែវ ( មេរៀនទី១)

៣. រឿងប្រាសាទអង្គរវត្ត ( មេរៀនទី១)

៤. អត្ថបទដកស្រង់រឿងផ្កាស្រពោន (អំណានទី១ មេរៀនទី២)

**ចម្លើយ**

១. រឿងកំណើតទីក្រុងភ្នំពេញ ( ប្រជុំរឿងព្រេងខ្មែរ ភាគ៥)

+ប្រធានរឿង : រឿងនេះនិយាយពីដើមកំណើតនៃទីក្រុងភ្នំពេញ

+មូលបញ្ហា :

-ទឹកជំនន់ជន់លិច ហើយនាំដើមគគីរមកវិលវល់ក្បែរមាត់ច្រាំង ក្បែរផ្ទះដូនពេញ

-ដូនពេញប្រទះឃើញព្រះពុទ្ធរូប៤អង្គ និងទេវរូបមួយអង្គ

-ដូនពេញអំពាវនាវឱ្យអ្នកស្រុកជួយលើកដីពូនភ្នំ ដើម្បីធ្វើព្រះវិហារតម្កល់ព្រះពុទ្ធរូប

២. រឿងភ្នំបាយ៉ង់កោរ នៅខេត្តតាកែវ (មេរៀនទី១)

+ប្រធានរឿង : ប្រវត្តិឈ្មោះភ្នំបាយ៉ង់កោរ

+មូលបញ្ហា :

-ព្រះបាទបាយ៉ង់កោរមានមហេសីស្អាត

-ព្រះចៅសៀមតាមចាប់ព្រះនាងសក់ក្រអូប

-ព្រះបាទបាយ៉ង់នាំមហេសីរត់ភៀសខ្លួន

-ព្រះបាទបាយ៉ង់បន់ស្រន់សុំសេចក្តីសុខ

-ព្រះបាទបាយ៉ង់កោរសក់លាបំណន់

៣. រឿងប្រាសាទអង្គរវត្ត (មេរៀនទី១)

•**ប្រធានរឿង** : រឿងនេះនិយាយពីប្រភពកំណើតនៃប្រាសាទអង្គរវត្ត ។

•**មូលបញ្ហារឿង** : បញ្ហាសំខាន់ៗនៅក្នុងរឿងនេះមាន ៖

-កំណើតព្រះពិស្ណុការ

-ព្រះពិស្ណុការទៅរៀនវិជ្ជាបច្ចេកទេសខាងសិល្បៈ និងសំណង់នៅឋានព្រះឥន្ទ្រ

-ព្រះកេតុមាលាជាអតីតបុត្រព្រះឥន្ទ្រដើរទស្សនាសព្វទីកន្លែងនៅឋានព្រះឥន្ទ្រ

-ព្រះឥន្ទ្របញ្ជាឱ្យព្រះពិស្ណុការមកសាងប្រាសាទមួយរាងដូចក្រោលគោព្រះឥន្ទ្រថ្វាយព្រះកេតុមាលា គឺប្រាសាទអង្គរវត្ត ។

៤. អត្ថបទដកស្រង់រឿងផ្កាស្រពោន (អំណានទី១ មេរៀនទី២)

•**ប្រធានរឿង** : ការឱ្យតម្លៃលើទ្រព្យសម្បត្តិធំជាងកិត្តិយស ។

•**មូលបញ្ហារឿង** : ទឹកចិត្តលោភលន់ទ្រព្យសម្បត្តិរបស់យាយទ្នន ។

## លក្ខណៈសម្គាល់របស់រឿង បែបពុទ្ធនិយម

*១– អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមសម្គាល់អត្ថបទអក្សរសិល្ប៍ដែលមានទំនាក់ទំនងទៅនឹងលទ្ធិពុទ្ធសាសនា ដោយការផ្ដើមរឿង គឺធ្វើបទនមស្ការរំលឹកគុណព្រះរតនត្រ័យ មានព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ។ ឯក្នុង ដំណើររឿង តួអង្គឯកបុរសជាពោធិសត្វ នារីជាកន្សៃសារពេជ្រ និងការបញ្ចប់រឿងដោយមានការសរជាតិរបស់តួអង្គពោធិសត្វទៅជាព្រះពុទ្ធ ឯកន្សៃសារពេជ្រទៅជានាងពិម្ពា ។ ចំពោះតួអង្គអាក្រក់វិញ បើតួអង្គនោះ ប្រុសនឹងទៅជាទេវទត្ត ឯតួអង្គស្រីទៅជានាងចិញ្ចា ។*

**ចម្លើយលំហាត់**

វិធីផ្ដើមរឿងក្នុងអត្ថបទ ៖

ក. អ្នកនិពន្ធផ្ដើមរឿងដោយរៀបរាប់តំណាលពីព្រះពុទ្ធគង់នៅក្នុងវត្តវេឡុវ័ន ព្រមទាំងការសំដែងធម្មទេសនារបស់ព្រះពុទ្ធ ដែលទាក់ទងនឹងដំណើររឿងតទៅ...។

ខ. អ្នកនិពន្ធផ្ដើមរឿងដោយដំណាលពីព្រះពុទ្ធគង់នៅវត្តជេតពន និងភ្ជាប់ជាមួយនឹងធម្មទេសនារបស់ព្រះពុទ្ធតែម្ដង ។



## បំណងប្រាថ្នារបស់ព្រះបាទវេស្សន្តរ

**សំណួរ**

១. តើអត្ថបទសម្រង់នេះដកស្រង់ពីរឿងណា? អ្នកនិពន្ធឈ្មោះអ្វី?

២. តើព្រះបាទវេស្សន្តរជាតួអង្គដូចម្ដេច? ចំណែកឯនាងមទ្រីជាតួអង្គដូម្ដេចដែរ?

៣. ចូរបង្ហាញកាលអាកាសនៅក្នុងអត្ថបទនេះ ។

៤. ចូរបង្ហាញពីបញ្ហាទំនាស់នៅក្នុងអត្ថបទនេះ ។

៥. ចូររកតម្លៃអប់រំក្នុងអត្ថបទនេះតាមរយៈសកម្មភាពតួអង្គព្រះវេស្សន្តរ?

៦. ចូរអ្នកអានរឿងព្រះវេស្សន្តរ រួចប្រាប់ពីវិធីតែងនិពន្ធរបស់រឿង គឺការផ្ដើមរឿង ដំណើររឿង និងបញ្ចប់រឿង។

**ចម្លើយ**

១. អត្ថបទសម្រង់នេះដកស្រង់ពីសៀវភៅសង្ខេបទសជាតក។ អ្នកនិពន្ធឈ្មោះ ឈឹម ស៊ុម (សុមន៍)។

២. ព្រះបាទវេស្សន្តរជាតួអង្គពោធិសត្វ ដែលមានសទ្ធាជ្រះថ្លាក្នុងការបំពេញទានបារមី ដើម្បីរំដោះសត្វលោកឱ្យរួចផុតពីសេចក្ដីទុក្ខសោក។ ព្រះអង្គសុខចិត្តលះបង់សេចក្ដីសុខផ្ទាល់ខ្លួនដើម្បីសេចក្ដីសុខរបស់មនុស្សទូទៅ។ ចំណែកឯនាងមទ្រីជាតួអង្គកន្សែសារពេជ្ឈ ដែលបានរួមចំណែកជួយបំពេញទានឱ្យស្វាមី។

៣. កាលអាកាសនៅក្នុងអត្ថបទនេះ ៖

+កាល : លុះរាត្រីកាលកន្លងទៅ, គ្រានោះ, នៅពេលព្រឹក, ខណៈនោះ....ដំណើររឿងប្រព្រឹត្តទៅនៅក្នុងរជ្ជកាលព្រះបាទស្រីសញ្ជ័យ។

+អាកាស : ជេត្តុតរនគរ ស្រុកស្រីពិរាស្ត្រ ភ្នំគីរីវង្គត ស្រះមុច្ចលិន្ទ សាលាឆទាន...។

៤. បញ្ហាទំនាស់នៅក្នុងអត្ថបទនេះគឺទំនាស់រវាងព្រះបាទស្រីសញ្ជ័យ ព្រះវេស្សន្តរជាមួយនឹងអ្នកស្រុកស្រីពិរាស្ត្រ ដែលបណ្តាលមកពីព្រះបាទវេស្សន្តរបានដាក់ទានដំរីបច្ច័យនាគេន្ទ្រទៅឱ្យពួកអ្នកស្រុកកលិង្គរាស្ត្រ ដែលពួកអ្នកស្រុកស្រីពិរាស្ត្រមានជំនឿថា ជាដំរីតំណាងឱ្យសិរីសួស្តីប្រចាំនគរ ។

៥. តម្លៃអប់រំក្នុងអត្ថបទនេះតាមរយៈសកម្មភាពតួអង្គព្រះវេស្សន្តរគឺ៖

- អប់រំមនុស្សឱ្យចេះបរិច្ចាគទានដល់អ្នកក្រីក្រ អ្នកដែលកំពុងជួបការលំបាក ។
- ចេះលះបង់សេចក្តីសុខផ្ទាល់ខ្លួនដើម្បីប្រយោជន៍រួម ។
- គោរពលទ្ធិប្រជាធិបតេយ្យ
- កុំឱ្យមានចិត្តលោភលន់
- ត្រូវសាងតែអំពើល្អ...

៦. វិធីតែងនិពន្ធ រឿងព្រះវេស្សន្តរ ( រឿងទាំងមូល) ៖

+ការផ្តើមរឿង : អ្នកនិពន្ធផ្តើមរឿងដោយប្រើបទនមស្ការព្រះរតនត្រៃ "នមោ តស្ស ភគវតោ អរហតោ សម្មា

**សម្ពុទ្ធស្ស...**" រួចលើកឡើងពីគុណសម្បត្តិរបស់ព្រះពុទ្ធ និងភ្ជាប់ទៅនឹងធម្មទេសនារបស់ព្រះពុទ្ធដែលទាក់ទងនឹងដំណើររឿងព្រះវេស្សន្តរ ។

**+ដំណើររឿង** : បង្ហាញពីកសាងទានបារមីរបស់ព្រះពោធិសត្វវេស្សន្តរ ដើម្បីត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ដោយអ្នកនិពន្ធបានប្រើវិធីជាច្រើនដូចជា ៖

ក_វចនវិធី : អ្នកនិពន្ធប្រើពាក្យពេចន៍លាយចម្រុះគ្នា :

-ពាក្យបាលី : **អតីតេ ភិក្ខវេ** ម្នាលភិក្ខុទាំងឡាយ... **ចេតបុត្តោ** រឺឯចេតបុត្រ...

-ពាក្យកម្ពីបាលី សំស្ក្រឹត : រាជទូត អធិដ្ឋាន ប្រឹថពី....

-ពាក្យសាមញ្ញ : ដោះសណ្ដាយ សក់ស្កូវ....

-ពាក្យរាជសព្ទ : អនគ្គោ អនគ្គា អគ្គ មហេសី បុត្រ មាតា បិតា....

ខ_វចនាវិធី : អត្ថបទតែងជាពាក្យរាយបែបកម្រងកែវ

ឧ. ដីរប្រាំពីររយ សឹងប្រដាប់នីទៅនូវខ្នង កញ្ចោងមាត់ខ្សង ចងជង្គន់ខ្សែក្រពាត់ ខ្សែងឹង ខ្សែបោង សំអាងមុខ ស្រោមភ្លុក ជាវិការៈនៃមាស មានក្បាច់ចំលាក់ព្រមទាំងទ្រមាក់ពាក់នីទៅនូវម្លូក ផ្កាយមាស ខោស្នាប់ភ្លៅ អាវក្រោះក្រាយរាយ ផ្កាយមាស....។

គ-និទានវិធី ៖ អ្នកនិពន្ធប្រើវិធីនិទានបែបបុរសទី៣

ឧ. ព្រះបរមសាស្ដាចារ្យគង់នៅក្នុងវត្ត និគ្រោធារាម ......ឯកោព្រាហ្មណោ មានព្រាហ្មណ៍ម្នាក់..........

ឃ-សំវាទវិធី ៖ ការសន្ទនារវាងព្រះវេស្សន្តរជាមួយនាងមទ្រី ជាមួយជូជក ជាមួយជាលីក្រស្នា ជាមួយព្រះបាទស្រីសញ្ជ័យ .....។

ង-ឯកវាទវិធី ៖ ព្រះមហាឥសីទ្រង់គិតថានឹងចាប់ធ្នូសរ ព្រះខ័នថ្លា ប្រហារយកព្រះរាជបុត្រទាំងពីរមកវិញ តែទ្រង់ទប់បានដោយមានព្រះតម្រិះថាៈ ប្រពៃណីនៃពោធិសត្វអំពីបុរាណមិនដែលខានធ្វើនូវបញ្ចមហាបរិច្ចាគ គឺ....។

ច-ឧបមានវិធី ៖ អ្នកនិពន្ធប្រៀបធៀបសម្ដីរបស់នាងមទ្រី ទៅនឹងធម្មជាតិអាក្រាតបីយ៉ាងដែលធ្វើឱ្យនាងសម្រេចព្រះទ័យយាងតាមព្រះវេស្សន្តរគឺ ៖

-ទន្លេគ្មានទឹក ហៅថា ទន្លេអាក្រាត

-ដែនគ្មានស្ដេច ហៅថា ដែនអាក្រាត

-ស្រីមេម៉ាយ ហៅថា ស្រីអាក្រាត

ឆ-អនុលោមវិធី

-ព្រះវេស្សន្តរស្តាប់តាមរាស្ត្រសុខចិត្តនិរទេសខ្លួនទៅនៅក្នុងព្រៃ

-ជាលីក្រស្នាស្ដាប់តាមការអង្វររបស់បិតា

-នាងមទ្រីព្រមប្រគល់ខ្លួនទៅឥន្ទ្រព្រាហ្មណ៍ ដើម្បីជួយបំពេញទានបារមីស្វាមី

ជ_បដិវិធី

-តាជូជកជាមនុស្សចាស់ មានរូបរាងអាក្រក់ តែបានប្រពន្ធក្មេងខ្ចី មានរូបស្អាត

-ព្រះវេស្សន្តរដាក់ទានជាអំពើល្អសោះ តែត្រឡប់ជាបានឈ្មោះថាជាការបៀតបៀនអ្នកនគរស្រីពិរាស្ត្រទៅវិញ។

ឈ_ពណ៌នាវិធី : អ្នកនិពន្ធរៀបរាប់ដំណើររឿង : ....ព្រះបាទស្រីវេស្សន្តរបវរពុទ្ធវង្ស ទ្រង់យាងយាត្រាតាមមាគ៌ាក្នុងពនាល័យក្សត្រថ្ងៃទ្រង់យាងបណ្ដើរ សំណេះសំណាលបណ្ដើរ។....

ញ_ទារុណវិធី : តាជូជកចងបណ្តើររាជកុមារទាំងពីរ ដោយវាយនឹងរំពាត់...........កុមារទាំងពីរដែលជូជកនាំទៅត្រូវទុក្ខវេទនាគ្របសង្កត់អត់ទ្រាំពុំបាន ទ្រង់ព្រះសំណោកសោកាថា៖ ឱ! ជើងយើងខ្ញុំពុរពងអស់ហើយ ព្រះមាតាអើយ !.........។

•**បញ្ចប់រឿង** : អ្នកនិពន្ធបញ្ចប់រឿងដោយបង្ហាញពីការសរជាតិរបស់តួអង្គ ថាតួអង្គណាបានទៅកើតជាតួអង្គណា ។

ឧ. ព្រះវេស្សន្តរ បានទៅជា ព្រះពុទ្ធ ( ព្រះសទ្ធត្ថ ឬ សទ្ធាថិ)

នាងមទ្រី   បានទៅជា នាងពិម្ពាយសោធរា   ។ល។

## កិរិយាសព្ទ

*៦– កិរិយាសព្ទ គឺជាពាក្យ ឬសព្ទសម្រាប់សំដែងនូវអំពើរបស់ប្រធាន ។*

កិរិយាសព្ទមាន ៖

១. កិរិយាសុទ្ធ : ជាកិ. សំដែងនូវអំពើរបស់ប្រធានដែលធ្វើឡើងដោយខ្លួនឯងផ្ទាល់ ។ ឧ. ហូប ផឹក ស៊ី ប្រយុទ្ធ ប្រឆាំង ដុត ភ្ជួររាស់...

២. កិរិយាហេតុ : ជាកិ. សំដែងនូវអំពើរបស់ប្រធានដែលធ្វើឡើងគ្រាន់តែជាហេតុដើមចម ។ ឧ. ពន្យល់ បង្រៀន ពន្យឺត បន្សាប

ពន្លូត ពន្យារ បន្ថយ...

៣. កិរិយាសកម្ម : ជាកិ. ដែលត្រូវការកម្មបទ។ ឧ. ស៊ី លេង...

៤. កិរិយាអកម្ម : ជាកិ. ដែលមិនត្រូវការកម្មបទ។ ឧ. យំ សើច...

**ចម្លើយលំហាត់**

១. តែងល្បះពីកិរិយាសព្ទ និងប្រាប់ប្រភេទរបស់វា៖

-កសិករ **ភ្ជួរ** ដី។ (កិ. សុទ្ធ)

-ម្ដាយខ្ញុំ **បន្ទុំ** ចេក។ (កិ. ហេតុ)

-ម្ដាយ **បំពេរ** កូន។ (កិ. សកម្ម)

-មាន់ **រងាវ** ។ (កិ. អកម្ម)

២. ស្រង់កិរិយាសព្ទក្នុងអត្ថបទ :

-មាន ស្គាល់ គិតគូរ ធ្វើ កើន ជក់ ប្រឆាំង...



# វប្បធម៌ អរិយធម៌ខ្មែរ

## សំណួរ

១. តើអត្ថបទនេះដកស្រង់ពីណា ?

២. តាមអត្ថបទនេះ តើវប្បធម៌មានន័យដូចម្ដេច ?

៣. តាមអត្ថបទនេះ តើវប្បធម៌មានតួនាទីដូចម្ដេចខ្លះ ?

៤. តើអរិយធម៌មានមែកធាងអ្វីខ្លះ ?

៥. ចូររកតម្លៃអប់រំនៅក្នុងអត្ថបទនេះ ។

៦. ចូររកគំនិតសំខាន់បង្កប់នៅក្នុងអត្ថបទនេះ ។

## ចម្លើយ

១. អត្ថបទនេះដកស្រង់ពីទស្សនាវដ្ដីសម្រាប់គ្រូស្ដីពីសិទ្ធិ-មនុស្ស ប្រជាធិបតេយ្យ និងអហិង្សាលេខ០៧-០៨ ទំព័រទី៩ ។

២. តាមអត្ថបទនេះ វប្បធម៌គឺជាសមិទ្ធផលនៃជ័យជំនះដោយបញ្ញា ពលកម្ម ហត្ថពលកម្មរបស់មនុស្សលើធម្មជាតិ លើអវិជ្ជា លើភាពអន្ធការ ។

៣. តាមអត្ថបទនេះ វប្បធម៌មានតួនាទីចង្អុលទិស បណ្ដុះបណ្ដាល អប់រំចំណេះដឹង និងបញ្ញា ដើម្បីសេចក្ដីចម្រើនខាងផ្លូវចិត្តគំនិត និងឧត្ដមគតិប្រសើរខ្ពង់ខ្ពស់របស់មនុស្ស ។

វប្បធម៌ជួយកែច្នៃមនុស្សឱ្យមានកិរិយាមារយាទល្អប្រសើរ មានរបៀបរបបរស់នៅថ្លៃថ្នូរ មានច្បាប់ទម្លាប់ត្រឹមត្រូវ មានសច្ចៈ យុត្តិធម៌ និងមានសេចក្តីសុខសន្តិភាព ។

## ៤. មែកធាងអរិយធម៌

- អរិយធម៌
  - វប្បធម៌
    - ពុទ្ធិ (ចំណេះដឹង)
      - -ជំនឿ
      - -សាសនា
      - -សីលធម៌
      - -វិទ្យាសាស្ត្រ
    - ការផ្សព្វផ្សាយ
      - -អក្សរសាស្ត្រ-អក្សរសិល្ប៍
      - -ភាសា-អក្សរ-សញ្ញា
      - -សិល្បៈ-ព័ត៌មាន
    - ការអនុវត្ត
      - -ទំនៀមទំលាប់-ប្រពៃណី
      - -ការសិក្សា-អប់រំ
      - -កីឡា-ល្បែងកំសាន្ត-ច្បាប់
  - សង្គមធម៌
    - សង្គមសំភារៈ (គ្រឿងសង្គម)
      - -ឧបករណ៍សង្គម (គ្រឿងសង្គម)
      - -វិជ្ជាជីវៈសង្គម
      - -វិធីបច្ចេកទេស (តិចនិច)
    - សង្គមវិធី (របបសង្គម)
      - -សេដ្ឋកិច្ច (កសិកម្ម-ពាណិជ្ជកម្ម......)
      - -សង្គមកិច្ច (សន្តិសុខ-សុខភាព.......)
      - -នយោបាយ (ក្នុង និងក្រៅប្រទេស)
    - សង្គមប្រភេទ (ទំរង់សង្គម)
      - -វណ្ណៈសង្គម
      - -អង្គការសង្គម (ស្ថាប័នផ្សេងៗ)
      - -អង្គការរដ្ឋ-ប្រជារាស្ត្រ

៥. តម្លៃអប់រំនៅក្នុងអត្ថបទនេះ ៖

- ឱ្យស្គាល់ច្បាស់ពីតម្លៃវប្បធម៌ អរិយធម៌ខ្មែរ

-ឱ្យស្រឡាញ់ និងលើកស្ទួយវប្បធម៌-អរិយធម៌ជាតិខ្លួនឱ្យបានគង់វង្ស ។

-មានមោទនភាពចំពោះជាតិ

-លើកតម្កើងនិងឱ្យតម្លៃលើអរិយធម៌វប្បធម៌របស់ខ្មែរយើង

៦. គំនិតសំខាន់បង្កប់នៅក្នុងអត្ថបទនេះ គឺ ខ្មែរគ្រប់រូបត្រូវស្គាល់ ស្រឡាញ់ និងឱ្យតម្លៃលើអរិយធម៌ វប្បធម៌ជាតិរបស់ខ្លួន ហើយប្រែក្លាយទៅជាស្មារតីថែរក្សា ការពារអរិយធម៌ វប្បធម៌ជាតិ និងទឹកដីឱ្យបានស្ថិតស្ថេរគង់វង្សតរៀងទៅ ។



# ព្រះតេមិយ

**សំណួរ**

១. តើហេតុអ្វីបានជាព្រះតេមិយធ្វើជាគថ្លង់ ខ្វិនខ្វង់ ? ចូរញ្ជាក់ ។

២. ចូរបង្ហាញប្រធានរឿងនៅក្នុងអត្ថបទនេះ ។

៣. ចូរប្រាប់មូលបញ្ហានៃរឿងព្រះតេមិយ ។

៤. ចូរបង្ហាញខ្លឹមសាររបស់អត្ថបទ ។

**ចម្លើយ**

១. បានជាព្រះតេមិយធ្វើជាគ ថ្លង់ ខ្វិនខ្វង់ ព្រោះស្តាប់តាមពាក្យណែនាំរបស់ទេវតារក្សាស្វេតឆត្រដែលធ្លាប់ជាព្រះមាតាក្នុងជាតិមុន។ ទ្រង់ប្រើល្បិចកលបែបនេះដើម្បីឱ្យគេចផុតពីការសោយរាជ្យសម្បត្តិ (ស្តេចគ្រងរាជ្យមិនត្រូវការពិការភាពអ្វីមួយឡើយ) ។

២. ប្រធានរឿងនៅក្នុងអត្ថបទនេះគឺសន្សំនេក្ខម្មបារមី (សាងផ្នួស) របស់ព្រះតេមិយពោធិសត្វ ដើម្បីបានត្រាស់ជាព្រះពុទ្ធ ។

៣. មូលបញ្ហានៃរឿងព្រះតេមិយ ៖ បញ្ហាសំខាន់នៅក្នុងរឿងគឺ៖

- ព្រះបាទកាសិករាជជាព្រះបិតារបស់ព្រះតេមិយទ្រង់បាន

វិនិច្ឆ័យទោសធ្វើទារុណកម្មពួកចោរដោយប្រការផ្សេងៗ ។

- ព្រះតេមិយឃើញដូចនេះក៏ពិចារណាអំពីបាបកម្មនៃព្រះបិតាជាស្តេចសោយរាជ្យ ក៏ធ្វើពុតជាគ ថ្លង់ ខ្វិនខ្វង់ តាមពាក្យទេវតាជាម្តាយក្នុងជាតិមុន ដើម្បីគេចពីការឡើងសោយរាជ្យ ។
- ការពិសោធទាំង១៦យ៉ាងចំពោះព្រះតេមិយ
- ការយកតេមិយទៅសម្លាប់
- ការសាងផ្នួសរបស់ព្រះតេមិយ

៤. ខ្លឹមសាររបស់អត្ថបទគឺ : រឿងព្រះតេមិយជារឿងបែបពុទ្ធនិយម ។ រឿងនេះបង្ហាញពីប្រវត្តិអតីតជាតិរបស់ព្រះពុទ្ធ កាលដែលព្រះពោធិសត្វយោនយកកំណើតជាព្រះតេមិយ ។ ការធ្វើកិច្ចកលជាគ ថ្លង់ ខ្វិនខ្វង់ គឺដើម្បីចៀសវាងបាបកម្មនិងកិលេសទាំងឡាយក្នុងលោក ។ ការតាំងចិត្តយ៉ាងមុតមាំក្នុងផ្លូវធម៌របស់ព្រះតេមិយ ទីបំផុតឈានសម្រេចជាព្រះសម្មាសម្ពុទ្ធ ។ ចំណែកឯព្រះញាតិវង្សនិងអ្នកជ្រះថ្លាដទៃទៀតក៏សម្រេចបានផលានិសង្ស ហើយទៅកើតនៅឋានឧបរមសុខគ្រប់ៗគ្នា ។

# ការនិយាយ បញ្ចេញមតិចំពោះ
# សកម្មភាពតួអង្គ

**លំហាត់**

ចូរអ្នកអានរឿង រួចបញ្ចេញមតិចំពោះគំនិត និងសកម្មភាពតួអង្គ មួយចំនួនក្នុងរឿងទុំទាវ ៖

***១. សេចក្តីស្នេហារបស់ទុំនិងទាវមិនត្រឹមត្រូវទេ ព្រោះទុំជាសង្ឃ ។***

ចំពោះទស្សនៈខាងលើនេះ ខ្ញុំគិតថាជាទស្សនៈដ៏ត្រឹមត្រូវ ពិតប្រាកដណាស់ ព្រោះអីវ៉ានៅជាសង្ឃនៅឡើយ បែរជាលបលួច ស្រឡាញ់ទាវ ប្រាសចាកវិន័យសង្ឃ នាំឱ្យអាប់អួរដល់ព្រះពុទ្ធ សាសនា និងជាគម្រូអាក្រក់ដល់សង្ឃដទៃទៀត ។ ចំណែកនាងទាវក៏ អីចឹងដែរ ខ្លួនជាស្រីក្រមុំ ហើយកំពុងស្ថិតនៅក្នុងការចូលម្លប់នៅ ឡើយ បែរជាហ៊ានបញ្ចេញកិរិយាមារយាទ ក្នុងន័យស្នេហាដាក់ទុំ ដែលជាព្រះសង្ឃ ធ្វើឱ្យខុសប្រពៃណីខ្មែរ ។ តាមយោបល់ខ្ញុំ អ្នកទាំងពីរ សុទ្ធតែមានកំហុសដូចគ្នា ។

***២. មរណភាពដ៏សោកសៅរបស់ទុំ និងទាវ គឺបណ្តាលមកពី ម្តាយទាវតែម្នាក់គត់ ។***

ទស្សនៈខាងលើ វាត្រឹមត្រូវម្យ៉ាងដែរ តែខ្ញុំមិនយល់ស្រប ទាំងស្រុងឡើយ ព្រោះបើកុំតែមានអរជូន និងម៉ឺនងួន ចូលមកពាក់ព័ន្ធ

ក្នុងជីវិតអ្នកទាំងពីរ ក៏អ្នកទាំងពីរមិនស្លាប់ដែរ ហើយប្រហែលជារស់នៅយ៉ាងសុខសាន្តទៀតផង។ ម្យ៉ាងទៀតប្រសិនបើសម័យនោះមានច្បាប់ទម្លាប់ត្រឹមត្រូវ កុំអាងអំណាចផ្តាច់ការ ក៏អ្នកទាំងពីរមិនស្លាប់ដែរ។ ដូច្នេះជាទស្សនៈរបស់ខ្ញុំ ការស្លាប់របស់អ្នកទាំងពីរគឺបណ្តាលមកពីរបបសក្តិភូមិទៅវិញទេ។



មេរៀនទី ៥

# វេយ្យាករណ៍ភាសា

## គុណកិរិយា

*— គុណកិរិយា គឺជាពាក្យសម្រាប់សំដែងលក្ខណៈរបស់កិរិយាសព្ទ គុណនាម ឬគុណកិរិយា ។*

ប្រភេទគុណកិរិយាមាន ៖

-គុ.កិ. កាល

-គុ.កិ. កន្លែង

-គុ.កិ. បំណែប

-គុ.កិ. បរិមាណ

-គុ.កិ. សំណួរ

**លំហាត់**

១. ចូរបង្ហាញពាក្យដែលជាគុណកិរិយា និងបញ្ជាក់ពីប្រភេទនៃ គុ.កិ. ក្នុងល្បះនីមួយៗដូចខាងក្រោម ៖

-សុភីនិយាយភាសាអង់គ្លេសបានល្អ ។

-ប្រាសាទនេះធំណាស់ ។

-គាត់មកយឺតពេក ។

-ហេតុដូចម្ដេចបានជាគាត់តែងរៀងបានល្អម្ល៉េះ?

-គាត់ចេញពីផ្ទះអំបាញ់មិញ ។

២. ចូរតែងល្បះដោយប្រើគុ.កិ.បំណែប គុ.កិ.សំណួរ គុ.កិ.បរិមាណ គុ.កិ.កាល និងគុ.កិ.កន្លែង ឱ្យបានមួយប្រភេទមួយល្បះ ។

**ចម្លើយ**

១. គុណកិរិយា ក្នុងល្បះខាងក្រោម

-សុភីនិយាយភាសាអង់គ្លេសបានល្អ ។

"ល្អ" ជាគុ.កិ. បំណាប

-ប្រាសាទនេះធំ ណាស់ ។

"ណាស់" គុ.កិ. បរិមាណ

-គាត់មកយឺតពេក ។

"យឺត" គុ.កិ. បំណែប

"ពេក" គុ.កិ.បរិមាណ

-ហេតុដូចម្ដេចបានជាគាត់តែងរៀងបានល្អម្ល៉េះ?

"ហេតុដូចម្ដេច" គុ.កិ.សំណួរ

-គាត់ចេញពីផ្ទះអំបាញ់មិញ ។

"អំបាញ់មិញ" គុ.កិ.កាល

២. តែងល្បះ

-គុ.កិ.បំណែប : សុភីអង្គុយរៀនយ៉ាងស្ងៀមស្ងាត់ ។

-គុ.កិ.សំណួរ : តើឯងមកដល់ពីអង្កាល់ ?

-គុ.កិ. បរិមាណ : សុខាញ៉ាំបាយច្រើនណាស់ ។

-គុ.កិ.កាល : ព្រឹកមិញ ម្ដាយខ្ញុំយកបាយសម្លទៅវត្ត ។

-គុ.កិ.កន្លែង : មានអណ្ដូងទឹកមួយនៅមុខផ្ទះ ។

# កាព្យរូបារម្មណ៍

១— *កាព្យរូបារម្មណ៍ គឺជារូបារម្មណ៍ដែលមាននៅក្នុងអត្ថបទកាព្យ ។*

កាព្យរូបារម្មណ៍មានច្រើនយ៉ាង ៖

**១. បំរៀបន័យរូបារម្មណ៍** : វិធីធ្វើសមាទកម្មវត្ថុ ឬត់និតទៅនឹងវត្ថុ ហើយនឹងបាតុភូតនៅក្នុងឥន្ទ្រិយភាព ឬសិល្បឧបមានទៅលើវត្ថុពីរដែលមានលក្ខណៈក្រៅដូចគ្នា ដើម្បីបំភ្លឺសារៈខាងក្នុងនៃបាតុភូតមួយតាមតាមរយៈបាតុភូតមួយទៀត ។

ឧ-ភ្នំភ្លើង ស្ទឹងឈាម សមុទ្រមេឃា នាវាតណ្ហា គុកបេតី អន្លង់ស្នេហ៍ មាត់ស្ទឹង ជើងភ្នំ...។

**២. ឧបមានរូបារម្មណ៍** : ជាអារម្មណ៍ដែលកវីប្រើពាក្យបច្ច័យសម្រាប់ប្រៀបធៀប ដូចជាៈ រូ រូហាន រូពិន ប្រៀបបាននឹង ដូច ដូចជា ប្រហែល ឬមួយជា ប្រហែលជា...។

**៣. រូបារូប្បារម្មណ៍ (រូបារូបិយារម្មណ៍)**: ជាអារម្មណ៍ដែលបង្កើតឡើងដោយកវីចេះប្រើពាក្យពេចន៍ទាក់ទងនឹងការបង្ហាញពីប្រព័ន្ធនៃជីវរូបារម្មណ៍ ដូចជា ៖

ក) ចក្ខុរូបារម្មណ៍ : ការប្រើពាក្យពេចន៍ទាក់ទាញហាក់ឃើញដោយផ្ទាល់ភ្នែក ។

ខ) **សោតរូបារម្មណ៍** : កវីប្រើពាក្យពេចន៍ទាក់ទងការបង្ហាញពីសូរសំឡេងរណ្ដំ ស្រៈ រណ្ដំព្យញ្ជនៈ ទាក់ទងនឹងសូរសំឡេងធម្មជាតិដែលធ្វើឱ្យយើងស្ដាប់ឮមានអារម្មណ៍រំភើប...។

គ) **ឃានជីវ្ហារូបារម្មណ៍** : គឺជារូបារម្មណ៍ដែលកើតឡើងដោយការប៉ះទង្គិច រវាងក្លិនក្រអូប ស្អុយ ឆ្អេះឆ្អាប រសផ្អែម ជូរចត់...ទៅនឹងឃានច្រមុះ និងជីវ្ហា (ការដឹងដោយអណ្ដាត) ។

ឃ) **កាយរូបារម្មណ៍** : ជាអារម្មណ៍ដែលកើតឡើងដោយ-សារកវីប្រើពាក្យសំដី ឃ្លា ល្បះ ដើម្បីបង្កើតការរំភើបតាមរយៈសម្ផស្ស ។

**៣. និមិត្តរូបារម្មណ៍** : ជាអារម្មណ៍ដែលអ្នកនិពន្ធរៀបរាប់អធិប្បាយ អំពីគោលបំណងអ្វីមួយ ដើម្បីសំដែង ឬសំគាល់នូវមតិយោបល់ ឬទស្សនៈណាមួយ ។

## ចម្លើយលំហាត់

ប្រភេទរូបារម្មណ៍ក្នុងអត្ថបទកាព្យដកស្រង់ខាងក្រោម ៖

១. មៀងមើលទឹកជ្រៅស្មៅត្រកៀត ចិត្តបងចង្អៀតរីតរិវេត
ត្រកួនដូចខ្លួនបងឈប់ដេក ឈប់ដោយម្លប់មែកត្របែកព្រៃ ។
យាប្លងដូចបងភ្ញាក់ឃ្លាតឆ្ងាយ ព្រៃព្រួយមកឱ្យយូរឃ្លាតឃ្លៃ
ស្រងេះស្រងោចរបូតដៃ ម្លេះសមប្អូនភ័យមមៃគិត ។

*(ទុំទាវ ភិក្ខុសោម)*

*អត្ថបទកាព្យខាងលើនេះកវីប្រើចក្ខុរូបារម្មណ៍ ។*

២. អ្នកមួយចែចូវ　　　　　រអែរអូវ
វៀចវេរឫស្យា .
បញ្ចើចបញ្ចើ　　　　ពាក្យពីមាយា　　ដូចកលផ្លែល្វា
ល្អល្អះតែក្រៅ ។
មួយដូចខ្ទុរណាំង　　សំបកស្តោគស្គាំង　បន្លាច្រូងនៅ
ឯក្នុងសឹងក្លែប　　ក្រអែបផ្អែមទៅ　ទាល់ក្នុងឥតសៅ
រសសឹងពិសា ។

*(ច្បាប់កូនចៅ បណ្ឌិត មៃ)*

***អត្ថបទកាព្យខាងលើនេះកវីប្រើឃានជិវ្ហារូបារម្មណ៍ ។***

៣. ភ្លៀងធ្លាក់ស្រិប១មិនឈប់ឈរ　ភ្លៀងហូរតាមទស្សរតក់១
កង្កែបកប១តាមជើងកក់　ខ្យល់បក់ហ៊ូ១តាមបង្ហួច ។
បក់លើមែកឈើឮសូរប្រាវ　រត់វ៉ាវទៅឆ្ងាយសូរគ្រលួច
រត់តាមប្រហោងហាក់ដូចហួច　រត់កួចសក់នាងញ៉ូររញ្ជួយ ។

*(ចិត្តក្រមុំ លោកកេងវ៉ាន់សាក់)*

***អត្ថបទកាព្យនេះកវីប្រើសោតរូបារម្មណ៍ ។***

៤. ទាវអើយទាវស្រីសេចក្តីនេះ　មាននេននោះចេះមើលសាស្ត្រា
សំឡេងស្រួយស្រាប់ស្តាប់ភាសា　ដូចសត្វសារិកាពិសាចេក ។

*(ទុំទាវ ភិក្ខុសោម)*

*អត្ថបទកាព្យនេះកវីប្រើសោតរូបារម្មណ៍ ។*

៥. កបកាយក្រអូប ទោះទាំងរាងរូប ប្រហើរពុំបាច់
រកផ្កាគ្រឿងអប់ ឈ្ងុយឈ្ងុំសព្វសាច់ ពិដោរបណ្ដាច់
បណ្ដូលអស់ស្រី ។

*(កាកី ព្រះបាទអង្គឌួង)*

*អត្ថបទកាព្យនេះ កវីប្រើឃានជីវ្ហារូបារម្មណ៍ ។*

# អំណាន

## សំណួរ

១. តើអត្ថបទកាព្យខាងលើនេះមានប្រភពមកពីណា? អ្នកណាជាអ្នកនិពន្ធ?

២. តើអត្ថបទកាព្យខាងលើនេះនិយាយពីអ្វី?

៣. ចូរបង្ហាញខ្លឹមសារអត្ថបទជាពាក្យសំរាយ ។

៤. ចូរបង្ហាញ និងគូសគំនូសតាងចំណាប់ចួន វគ្គទី១ និងទី២ ឱ្យបានត្រឹមត្រូវ ។

៥. ចូរបង្ហាញអំពីកាព្យរូបារម្មណ៍វគ្គទី៣ និងទី៤ ។

៦. តើសោភ័ណភាសា ឬសិល្បៈភាសានៅក្នុងអត្ថបទកាព្យខាងលើស្ថិតនៅត្រង់ណា?

## ចម្លើយ

១. អត្ថបទកាព្យខាងលើនេះមានប្រភពមករឿងទុំទាវ របស់ភិក្ខុសោម ។

២. អត្ថបទកាព្យខាងលើនេះនិយាយពីសម្រស់ធម្មជាតិដែលគួរឱ្យត្រេកត្រអាលក្រៃលែងក្នុងខណៈដែលទុំនិងពេជ្រកំពុងធ្វើដំណើរទៅរាជវាំងឯក្រុងលង្វែក ហើយច្រៀងរៀបរាប់ធម្មជាតិ ព្រៃ

ព្រឹក្សា លគាវល្លិ បក្សាបក្សីក្នុងព្រៃគួរឱ្យស្រណោះស្រណោ អាឡោះអាល័យក្រៃពេកដល់ពេល ហើយបានឆ្មៀងទៅជួប ម្ដាយទាវ និងលោកគ្រូចៅអធិការវត្តដើម្បីប្រាប់ដំណឹងនិងថ្វាយ បង្គំលាទៅរាជវាំង ។ ។

៣. ខ្លឹមសារអត្ថបទជាពាក្យសំរាយ : ទុំ និងពេជ្រត្រូវព្រះរាជាពេញ ចិត្ត ឱ្យទៅធ្វើជាអ្នកចម្រៀងថ្វាយព្រះអង្គ ។ ទុំចាកចេញទាំង អាល័យពីនាងទាវ ហើយនៅតាមផ្លូវទុំបានរៀបរាប់ពីធម្មជាតិ ដែលធ្វើឱ្យទុំកាន់តែនឹងអាឡោះអាល័យទាវទ្វេឡើង ។ មុននឹង ទៅរាជវាំង ទុំនិងពេជ្របានចូលទៅសំពះលាម្ដាយ និងថ្វាយបង្គំ លាលោកគ្រូសង្ឃរាជ ជាមុនសិនទើបធ្វើដំណើរបន្ត ។

៤. គំនូសតាងចំណាប់ចួន វគ្គទី១ និងទី២

-វគ្គទី១: ព្យ.៧ ឃ.១ ⊢⊣ ព្យ.៤ ឃ.២

ព្យ.៧ ឃ.៣ ⊢⊣ ព្យ.៤ ឃ.៤ ⊢⊣ ព្យ.៧ ឃ.៣

-វគ្គទី២: ព្យ.៧ ឃ.១ ⊢⊣ ព្យ.២ ឃ.២

ព្យ.៧ ឃ.៣ ⊢⊣ ព្យ.៤ ឃ.៤ ⊢⊣ ព្យ.៧ ឃ.៣

-ចួនឆ្លងវគ្គ: ព្យ.៧ ឃ.៤ វ.១ ⊢⊣ ព្យ.៧ ឃ.៤ វ.២



៥. កាព្យរូបារម្មណ៍វគ្គទី៣ និងទី៤

ក្នុងវគ្គទាំងពីរនេះកវីបង្ហាញពីចក្ខុរូបារម្មណ៍ដែលកវីប្រើ-ប្រាស់ពាក្យពេចន៍និងភាសាហាក់មើលឃើញនឹងភ្នែកទៅនឹងការរៀបរាប់ឈ្មោះដើមឈើគ្រប់ប្រភេទនៅក្នុងព្រៃធ្វើឱ្យយើងស្រមៃហាក់នៅនឹងភ្នែកពិតៗដូចជាការរៀបរាប់នោះដែរ ។

៦. សោភ័ណភាសា ឬសិល្បៈភាសានៅក្នុងអត្ថបទកាព្យខាងលើស្ថិតនៅត្រង់កវីតែងអត្ថបទជាពាក្យកាព្យ ដោយមានពាក្យពេចន៍ច្នូន រណ្ដំ ណៃងណងតាមក្បួនខ្នាតត្រឹមត្រូវ ហើយការរៀបរាប់របស់កវីមានភាពប្រទាក់ក្រឡាធ្វើឱ្យចង់អានជក់ចិត្ត លន្លង់-លន្លោចទៅតាមការពណ៌នារបស់កវី ។

# ប្រភពនៃអក្សរខ្មែរ

**សំណួរ**

១. តើអត្ថបទខាងលើនេះនិយាយពីអ្វី ?

២. តើអក្សរខ្មែរមានប្រភពមកពីណា ?

៣. តើអក្សរខ្មែរមានការវិវត្តប៉ុន្មានលើកមកហើយ? ហើយមានលក្ខណៈពិសេសដូចម្ដេចខ្លះ ?

៤. តើអក្សរខ្មែរមានលក្ខណៈខុសពីអក្សរលាវ និងសៀមត្រង់ណាខ្លះ ?

៥. ចូរបង្ហាញខ្លឹមសារនៃអត្ថបទ ។

៦. ចូររកគំនិតសំខាន់បង្កប់នៅក្នុងអត្ថបទ ។

**ចម្លើយ**

១. អត្ថបទខាងលើនេះនិយាយពីប្រភព ការវិវត្ត និងលក្ខណៈនៃអក្សរខ្មែរ ។

២. ផ្អែកតាមអត្ថបទ អក្សរខ្មែរមានប្រភពមកពីអក្សរព្រាហ្មី នៅប្រទេសឥណ្ឌា ។

៣. អក្សរខ្មែរមានការវិវត្ត១០លើកមកហើយ ។

+លក្ខណៈពិសេសនៃអក្សរខ្មែរ :

- ព្យញ្ជនៈសម័យមុនអង្គរ ៖ មានរាងគ្រោតគ្រាត មិនស្មើ មិនសម សក់ខ្លី ជើងខ្លី ហើយមានចំនួនតិច ។
- ព្យញ្ជនៈសម័យអង្គរ ៖ មានរាងសង្ហា មានសក់ជាក្បាច់រចនា ជើងមានស្មើរតែគ្រប់តួ ។
- ព្យញ្ជនៈសម័យក្រោយអង្គរ ៖ មានរាងទ្រេត សក់ និងជើងវែងៗ មានរូបរាងកាន់តែច្បាស់ ។

៤. អក្សរខ្មែរមានលក្ខណៈខុសពីអក្សរលាវ និងសៀមត្រង់ ៖

•ភាសាខ្មែរយើង តួព្យញ្ជនៈមានសក់ មានជើង គឺជាក្បាច់ដែលបុព្វបុរសយើងបានរចនាឡើងដើម្បីលំអព្យញ្ជនៈនីមួយៗឱ្យមានសភាពសមសួនឡើង ។

•ចំណែកភាសាសៀម និងលាវដែលយកលំនាំតាមអក្សរខ្មែរយើង ហើយយកទៅកែប្រែលុបសក់ចេញ មើលទៅហាក់ដូចជាមនុស្សដែលមានក្បាល ប៉ុន្តែអត់សក់ដូចនោះដែរ ។

៥. ខ្លឹមសារនៃអត្ថបទគឺនិយាយពីប្រភពនៃអក្សរខ្មែរ ការវិវត្តនៃអក្សរខ្មែរ ទ្រង់ទ្រាយនៃអក្សរខ្មែរ និងលក្ខណៈពិសេសនៃអក្សរខ្មែរ ។

៦. គំនិតសំខាន់បង្កប់នៅក្នុងអត្ថបទគឺការបង្ហាញពីប្រភពអក្សរខ្មែរ ការវិវត្ត ការបង្កើតក្បួនខ្នាត និងលក្ខណៈពិសេសរបស់អក្សរខ្មែរដែលមានសារៈសំខាន់សម្រាប់ជាតិខ្មែរ ។

# ការនិយាយប្រៀបធៀប

*១– ការប្រៀបធៀប គឺជាការប្រដូច ឬប្រៀបផ្ទឹមគ្នានូវរបស់ពីរ វត្ថុពីរ ទស្សនៈ យោបល់ ឬគំនិតពីរ ។ល។ ដើម្បីបង្ហាញពីលក្ខណៈដូចគ្នា និងខុសគ្នា ។*

**លំហាត់**

ចូរអ្នកប្រៀបធៀបការវិវត្តនៃតួព្យញ្ជនៈខ្មែរទាំងបីដំណាក់កាលធំៗ ដែលអ្នកបានសិក្សារួចហើយនោះគឺ សម័យមុនអង្គរ សម័យអង្គរ និងសម័យក្រោយអង្គរ ។ បន្ទាប់មកចូរអ្នកប្រៀបធៀបមើលថាព្យញ្ជនៈសម័យកាលណាមួយដែលមានលក្ខណៈដូចគ្នាច្រើនជាងគេទៅនឹងព្យញ្ជនៈខ្មែរយើងបច្ចុប្បន្ននេះ ។ ការប្រៀបធៀបនេះត្រូវផ្ដោតទៅលើចំណុចសំខាន់ៗខាងក្រោម ៖

- ចំនួនតួព្យញ្ជនៈសរុប
- ចំនួនតួព្យញ្ជនៈតាមវគ្គ
- ទម្រង់តួព្យញ្ជនៈតាមវគ្គនីមួយៗ
- ជើងព្យញ្ជនៈមួយចំនួន ។

មេរៀនទី ៦

# ការទទួលស្គាល់ការពិត

## មាគ៌ាជីវិតរបស់មាលា

**សំណួរ**

១. តើអត្ថបទនេះជាប្រភេទអត្ថបទអ្វី? សំអាងលើអ្វី?

២. ចូរបង្ហាញពីទំនាស់ក្រៅខ្លួនតាមរយៈអត្ថបទនេះ ។

៣. តើការសម្រេចចិត្តរបស់មាលាក្នុងការជ្រើសរើសយកភូរិន្ទ ជាស្វាមីនេះជាកំហុសដែរឬទេ?. ព្រោះអ្វី?

៤. តើមាលាត្រូវគេបណ្ដេញចុះចេញពីផ្ទះចំនួនប៉ុន្មានលើក? អ្វីខ្លះ?

៥. មាលានិយាយថា "អតីតកាលជាស្រមោល បច្ចុប្បន្នជាការពិត អនាគតជារឿងត្រូវដោះស្រាយ" ។ តើវាមានអត្ថន័យដូចម្ដេច?

៦. តើចំរុងព្រមទទួលស្គាល់ការពិតដែរឬទេ? ចូរស្រង់ឃ្លាបញ្ជាក់នូវចម្លើយរបស់អ្នក? ចំពោះអ្នក តើអ្នកគួរធ្វើដូចម្ដេច?

## សំណួរ

១. អត្ថបទនេះជាប្រភេទអត្ថបទល្ខោន (យីកេ) ព្រោះ ៖

-មានបង្ហាញឈ្មោះតួអង្គ នៅខាងមុខពាក្យសន្ទនា

-មានពាក្យសន្ទនារបស់តួអង្គនៅបន្ទាប់ពីឈ្មោះរបស់តួអង្គ ។

២. ទំនាស់ក្រៅខ្លួនតាមរយៈអត្ថបទនេះគឺ ទំនាស់រវាងចំរុងនិងភូរិន្ទ ហើយនិងចំរុងនិងមាលា ។ ទំនាស់នេះកើតឡើងមកពីការយល់ច្រឡំនិងនឹកស្មានមិនដល់ ។ នៅពេលដែលសំពៅត្រូវលិច ភូរិន្ទបានរួចជីវិត ។ ដោយបាត់ចំរុងរយៈពេលយូរពេកនឹកស្មានថាចំរុងជាប្ដីមាលាស្លាប់បាត់ទៅហើយ ភូរិន្ទក៏បានសម្រេចចិត្តរៀបការជាមួយមាលា ។ មាលាក៏យល់ព្រម ព្រោះគ្មានទីពឹង ។

៣. ការសម្រេចចិត្តរបស់មាលាក្នុងការជ្រើសរើសយកភូរិន្ទជាស្វាមីនេះមិនមែនជាកំហុសឆ្គងនោះទេ ព្រោះក្រោយពីនាងអស់សង្ឃឹមនឹងចំរុងជាប្ដី គ្មានទីពឹង គឺមានតែភូរិន្ទនេះហើយដែលជាទីពំនាក់ទើបនាងសម្រេចចិត្តរៀបការជាមួយភូរិន្ទ ថែមទាំងមានផ្ទៃពោះជាមួយនឹងភូរិន្ទទៅហើយ ។ ដូច្នេះការជ្រើសរើសយកភូរិន្ទជាស្វាមីនៅពេលដែលចំរុងមកដល់ផ្ទះវិញមិនមានកំហុសឡើយ ។ ការសម្រេចចិត្តនេះមកពីនាងគិតដល់អនាគតរបស់កូន ។

៤. មាលាត្រូវគេបណ្ដេញចុះចេញពីផ្ទះចំនួន៤លើកមកហើយ ព្រមទាំងតិះដៀលថាជាស្រីថោកទាបផង ។

៥. មាលានិយាយថា "អតីតកាលជាស្រមោល បច្ចុប្បន្នជាការពិត អនាគតជារឿងត្រូវដោះស្រាយ" ។

ពន្យល់ ៖

- អតីតកាលជាស្រមោលមានន័យថា រឿងរ៉ាវដែលកើតឡើងចំពោះមាលាក្នុងអតីតកាល នាងមិនអាចទទួលយកមកបន្តបានទេ តែនាងក៏មិនអាចបំភ្លេចវាបានដែរ ។ ដូច្នេះហើយទើបរឿងរ៉ាវទាំងនោះនៅតែជិតដាមក្នុងអារម្មណ៍ក្លាយជាស្រមោលអន្ទោលតាមប្រាណនាងចានិច្ច ។
- បច្ចុប្បន្នគឺជាពិតមានន័យថារឿងរ៉ាវដែលកើតឡើងរវាងមាលានិងភ្នូរិន្ទគឺជាការពិតដែលត្រូវទទួលយកមិនអាចគេចវេះបានឡើយ ។
- អនាគតជារឿងដែលត្រូវដោះស្រាយមានន័យថា មាលានិងភ្នូរិន្ទត្រូវតែទទួលខុសត្រូវដោះស្រាយចំពោះកូននៅពេលអនាគត ។

៦. ចំរុងទទួលស្គាល់ការពិត ដូចត្រង់សំដីថា :

-"ព្រះអើយ គេដឹកដៃគ្នាទៅហើយ គេជាប្ដីប្រពន្ធនឹងគ្នា..."។ តាមរយៈសំដីនេះបញ្ជាក់ថា ចំរុងសែនស្ដាយស្រណោះមាលាជាពន់ពេក ប៉ុន្តែធ្វើដូចម្ដេចបើមាលាសម្រេចចិត្តដូចនេះទៅហើយ។ ចំរុងមិនអាចបដិសេធឬគេចវេះពីការពិតនេះបានទេ។

## ចំណាងធ្នាក់ និង ចំណាងឈ្នាប់

១. ចំណាងធ្នាក់ឬធ្នាក់

ធ្នាក់ គឺជាពាក្យចំណងសម្រាប់ប្រើក្នុងកន្សោមពាក្យ ឬឃ្លា ដើម្បីបង្កើតកន្សោមមានធ្នាក់នៅក្នុងល្បះ។

ចំណងធ្នាក់មាន ៖ ក្នុង ក្រៅ លើ ក្រោម ចំពោះ ជាមួយ ដើម្បី ដោយ ត្រង់ នូវ នៃ របស់ ពីព្រោះ អំពី ខាង ជិត ក្បែរ មុខ...។

២. ចំណងឈ្នាប់ឬឈ្នាប់

**ក. ឈ្នាប់ចង :** ឈ្នាប់ចង គឺជាពាក្យចំណងសម្រាប់សម្គាល់ទំនាក់ទំនងរវាងល្បះ និងល្បះ ឬរវាងធាតុផ្សេងៗនៅក្នុងល្បះ។

ឈ្នាប់ចងមាន: និង ហើយ ឬ តែ ប៉ុន្តែ ឬក៏ ពុំនោះសោត...

**ខ. ឈ្នាប់ឃ្លា :** គឺជាពាក្យចំណងសម្រាប់សម្គាល់ទំនាក់ទំនងរវាងឃ្លា និងឃ្លាផង ហើយនិងសម្រាប់បង្កើតឃ្លារណបថែមទៀតផង។

ឈ្នាប់ឃ្លាមាន : ព្រោះ ពីព្រោះ ដើម្បី ដើម្បីនឹង បើ ប្រសិន បើ កាលណា ទោះបី ថ្វីត្បិត...។

**ចម្លើយលំហាត់**

១. តែងល្បះដោយប្រើធ្នាក់: ក្នុង ចំពោះ ជាមួយ ពីព្រោះ អំពី ដោយ :

-យើងត្រូវចោលសំរាម **ក្នុង** ធុងសំរាម ។

-សិស្សានុសិស្សឡើងថ្លែងអំណរគុណ **ចំពោះ** លោកគ្រូអ្នកគ្រូ ។

-លោកគ្រូនិយាយ **ជាមួយ** សិស្ស ។

-ខ្ញុំរៀនពុំកើត **ពីព្រោះ** ឈឺ ។

-ក្រុមរបស់យើងពិភាក្សា **អំពី** ដោះស្រាយលំហាត់ ។

-ខ្ញុំទៅសាលារៀនដោយកង់ ។

២. តែងល្បះដោយប្រើឈ្នាប់ : និង ប៉ុន្តែ ថា ពីព្រោះ ទោះបី កាលណា ប្រសិនបើ :

-ផ្ទះខ្ញុំមានគោមួយនឹម **និង** រទេះគោមួយ ។

-ធីតាចង់រៀនបន្តនៅភ្នំពេញណាស់ **ប៉ុន្តែ** គ្មានអ្នកណាជួយមើលថែម្តាយនាង ។

-ខ្ញុំគិត **ថា** យើងមិនត្រូវផ្តេកផ្តួលលើព្រហ្មលិខិតទេ ។

-នាងយំ **ពីព្រោះ** ម្តាយវាឈឺពោះ ។

-សុភីរៀនពូកែណាស់ **ទោះបី** វាធ្វើកិច្ចការជាច្រើនក៏ដោយ ។

-**កាលណា** ខ្ញុំធំឡើង ខ្ញុំនឹងខិតខំធ្វើកិច្ចការបម្រើប្រទេសជាតិ

ឱ្យអស់ពីចិត្តពីថ្លើម ។

-ប្រសិនបើ ខ្ញុំមានពេល ខ្ញុំនឹងឧស្សាហ៍ទៅសួរសុខទុក្ខគាត់ ។

៣. ពាក្យដែលជាធ្លាក់ និងជាឈ្នាប់ នៅក្នុងអត្ថបទ :

-ធ្លាក់ : នៃ ចំពោះ

-ឈ្នាប់ : ថែមទាំង

# បុរេនិច្ឆ័យ

*១- បុរេនិច្ឆ័យ គឺជាការសន្និដ្ឋាន ការវិនិច្ឆ័យ ឬការវាយតម្លៃទុកជាមុនដោយមិនទាន់ស្វែងយល់រកការពិតឱ្យបានច្បាស់លាស់នៅឡើយ ។ ការសន្និដ្ឋាន ឬការវាយតម្លៃទាំងនោះមិនទាន់ត្រឹមត្រូវល្អិតល្អន់គ្រប់ជ្រុងជ្រោយនោះទេ គឺមានភាពលំអៀង ។*

**លំហាត់**

ចូរអានពំនោលខាងក្រោម រួចបង្ហាញបុរេនិច្ឆ័យ ។

១. ឈើកោងវល្លិព័ទ្ធ មនុស្សខ្វាត់ព្រាត់កុំយកខ្លួនបៀត ។

២. ដឹងឆ្មើយត្បិតដង កូនប្រុសរឹងឆ្អឹង ត្បិតតែឪពុក
ទ្រព្យគង់ត្បិតស្រី ចេះរៀបដាក់ទុក ផ្ទះធំស្រណុក
ត្បិតភរិយាជា ។

៣. សឹកឈើជ្រុះមិនឆ្ងាយពីគល់ឡើយ ។

៤. អនិច្ចាតោថ្មលោកកសាង
មើលថាថាងយ៉ាងរស់ស្មុះប្រៃប្រាយ
ឥឡូវមកធ្លាយធ្លាក់បាក់បែកខ្ទាត់ខ្ទាយ
ស្តាយអើយស្តាយមិនគួរមកពិការ ។
មានអ្នកព្រៃចង្រៃឥតគំនិត

មកសំលៀងកាំបិតគ្រឿងប្រហារ
មិនស្គាយការស្នាដៃបុរាណសោះ ។

**ចម្លើយ**

បុរេនិច្ឆ័យក្នុងឃ្លាខាងលើគឺ ៖

១. មិនត្រូវរាប់រកមនុស្សដែលមិនពីឆ្ងាយ មិនស្គាល់ប្រវត្តិច្បាស់លាស់ទេ ខ្លាចមានអន្តរាយដោយប្រការផ្សេងៗ ។

២. -មានតែឪពុកទេដែលអាចប្រដៅណែនាំកូនប្រុសបានល្អ បើសិនជាកូនប្រុសខុសឆ្គងម្តេចម្តា គឺបណ្តាលមកពីឪពុកពុំបានណែនាំដិតដល់ ។

-មានតែស្ត្រីទេជាអ្នកធ្វើឱ្យគ្រួសារមានសុភមង្គល មានភាពរុងរឿង ចេះរៀបចំទុកដាក់របស់របរមានសណ្តាប់ល្អ មានទ្រព្យសម្បត្តិបរិបូរណ៍ ។

៣. បើឪពុកម្តាយបែបណា កូនច្បាស់ជាបែបហ្នឹងដែរហើយ ។

ឱ-បើឪពុកម្តាយលេងល្បែង កូនច្បាស់ជាចេះលេងល្បែងដូចឪពុកម្តាយដែរ ។

៤. ការបាក់បែកនៃរូបចម្លាក់តោថ្ម គឺបណ្តាលមកពីពួកអ្នកដើរព្រៃយកកាំបិតទៅសំលៀងលើខ្នងតោនោះ ។



# ជីវិតខ្មែរក្នុងរបបអាថិ

**សំណួរ**

១. តើអត្ថបទនេះឆ្លុះបញ្ចាំងពីទិដ្ឋភាពនាសម័យកាលណា? សម័យកាលនោះចាប់ពីថ្ងៃខែឆ្នាំណា ដល់ ថ្ងៃខែឆ្នាំណា?

២. ចូរបង្ហាញពីបុរេនិច្ច័យក្នុងអត្ថបទនេះ ។

៣. តើអង្គការរបស់ខ្មែរក្រហម ប្រើពាក្យដូចម្តេចខ្លះក្នុងការយកប្រជាជនទៅសម្លាប់ចោល?

៤. តើអង្គការរបស់ខ្មែរក្រហម មានមនុស្សធម៌ និងយុត្តិធម៌ដែរឬទេ? ព្រោះអ្វី?

៥. តើជីវិតមនុស្សរាល់រូបក្នុងសម័យខ្មែរក្រហមមានតម្លៃដែរឬទេ? ដើម្បីជីវិតរស់នៅ តើប្រជារាស្ត្រខ្មែរអ្នកថ្មី បានប្រព្រឹត្តអំពើមិនគប្បីដូចសត្វធាតុយ៉ាងដូចម្តេច?

៦. តាមយោបល់អ្នក តើសម័យខ្មែរក្រហម មានការរើសអើងដែរឬទេ? ចូរបង្ហាញអំណះអំណាងបញ្ជាក់ ។

សំណួរ

១. អត្ថបទនេះឆ្លុះបញ្ចាំងពីទិដ្ឋភាពនាសម័យប៉ុលពត។ សម័យកាលនោះ ចាប់ពីថ្ងៃ១៧ មេសា ១៩៧៥ ដល់ ថ្ងៃ៧ មករា ១៩៧៩។

២. បុរេនិច្ច័យក្នុងអត្ថបទនេះគឺ គេចាត់ទុកពួកអ្នកថ្មីជាសត្រូវ ព្រោះគេ គិតថាពួកអ្នកថ្មីមិនអាចធ្វើការបាន ហើយពួកនេះទុកមិនចំណេញ ដកចេញក៏មិនខាត។

៣. ដើម្បីយកប្រជាជនទៅសម្លាប់ចោល អង្គការរបស់ខ្មែរក្រហមប្រើពាក្យថា :

-យកទៅសាលាកាលេស

-យកទៅកសាងឡើងវិញ

-ឱ្យទៅដាំដំឡូង

៤. អង្គការរបស់ខ្មែរក្រហមមិនមានមនុស្សធម៌ និងយុត្តិធម៌ទេ ព្រោះ៖

- គេប្រើមនុស្សឱ្យធ្វើការបាក់កម្លាំង
- គ្មានពេលសម្រាកគ្រប់គ្រាន់
- បង្អត់អាហារ ហុកចុកមិនឆ្អែត
- បើនរណាហ៊ានតវ៉ា ត្រូវគេចាត់ទុកជាខ្មាំង រួចយកទៅ

សម្លាប់ចោលភ្លាម

- បំបិទសិទ្ធិសេរីភាព
- បំផ្លាញហេដ្ឋារចនាសម្ព័ន្ធ
- ជំលៀសមនុស្សចេញពីកន្លែងធ្លាប់រស់នៅ
- ..........................................។

៥. ជីវិតមនុស្សរាល់រូបក្នុងសម័យខ្មែរក្រហមមានគ្មានតម្លៃទេ។ ដើម្បីជីវិតរស់នៅ ប្រជារាស្ត្រខ្មែរអ្នកថ្មី បានប្រព្រឹត្តអំពើមិនគប្បីដូចសត្វធាតុ គឺពួកគេប្រជែងគ្នាដេញចាប់សត្វល្អនដូចជា ពស់ បង្កួយ និងសត្វល្អិត ដូចជាចង្រិត កណ្តូប រហូតដល់ទៅសត្វពិសដូចជា ក្អែប ខ្ទួយ ជាដើមយកមកចម្អែតក្រពះ។

៦. តាមយោបល់ខ្ញុំ សម័យខ្មែរក្រហម ពោរពេញដោយការរើសអើង ព្រោះមានការបែងចែករវាងប្រជាជនម្ចាស់ស្រុក និងពួកអ្នកចំណូលថ្មី ហើយពួកអ្នកចំណូលថ្មីត្រូវគេប្រមាថមើលងាយជាច្រើនប្រការ...ជាសម័យដែលប្រជាជនគ្មានសិទ្ធិសេរីភាពអ្វីទាំងអស់។

# ការនិយាយបកស្រាយសុភាសិត

*១– សុភាសិត គឺជាពាក្យពេចន៍ល្អ ពាក្យពេចន៍ត្រឹមត្រូវ ឬជាប្រស្នាដែលមាន ខ្លឹមសារ និងសម្ផស្សបរិបូរទៀតផង ។*

សុភាសិតអាចមានន័យពីរយ៉ាង ៖

**១.ន័យចំ (អត្ថានុរូប)** ៖ ជាពាក្យដែលមានន័យត្រង់ មិនបញ្ឆិតបញ្ឆៀង ឬជាន័យដែលមិនឃ្លាតចាកពីន័យដើម ។

**២.ន័យធៀប (អត្ថាប្បដិរូប)** ៖ ជាន័យបញ្ឆិតបញ្ឆៀង ឬន័យប្រដូច ឬន័យដែលបង្វិលបញ្ឆៀសពីន័យដើម ។

ឧ. "**ងើយស្កកឱនដាក់គ្រាប់**"

- ន័យចំៈ សំដៅទៅលើដើមស្រូវទុំ ។ កួរស្រូវណាដែលត្រង់ទៅលើ គឺគ្មានគ្រាប់ ឬស្កក ។ ចំណែកឯកួរស្រូវណាដែលឱនចុះក្រោម មានគ្រាប់អង្ករ ។
- ន័យធៀបៈ សំដៅលើមនុស្ស ។ "ងើយស្កក" ប្រើសម្រាប់មនុស្សដែលគ្មានសុជីវធម៌ ។ "ឱនដាក់គ្រាប់" ប្រើសម្រាប់មនុស្សមានសុជីវធម៌ ។

*កំណត់សម្គាល់ ៖ សុភាសិតខ្លះពុំមានន័យធៀបទេ គឺមានតែន័យចំតែម្ដង ។*

## លំហាត់

ចូរអ្នកបកស្រាយសុភាសិតខាងក្រោមនេះ ៖

១. តក់ៗពេញបំពង់

២. ចេះពីរៀន មានពីរក

៣. ត្រីមួយត្រក ស្អុយមួយស្អុយទាំងអស់

៤. សន្សំមកុំបំបោល ក្រែងពុំដល់ដូចប្រាថ្នា

## ចម្លើយ

***១. តក់ៗពេញបំពង់***

**ក)ន័យចំ :** សំដៅលើ ទឹកត្នោតដែលហូរមួយតំណក់ម្ដងៗ រហូតដល់ពេញបំពង់បាន ។

**ខ)ន័យធៀប :** សំដៅលើសេចក្ដីព្យាយាមរបស់មនុស្ស គឺបើធ្វើការងារអ្វីៗត្រូវធ្វើដោយសន្សំៗ បន្តិចម្ដងៗ យូរៗទៅតង់តែបាន សម្រេច ។

***២. ចេះពីរៀន មានពីរក***

+ចេះពីរៀន : មានន័យថាចំណេះអ្វីក៏ដោយគឺសុទ្ធតែ កើតមកពីការរៀនទាំងអស់ ដូច្នេះត្រូវខិតខំស្រវាស្រទេញ រៀនសូត្រ គ្រប់មុខវិជ្ជាទាំងអស់ ។

+មានពីរក : មានន័យដើម្បីឱ្យមានទ្រព្យសម្បត្តិ ឬ

របស់របរអ្វីៗត្រូវខិតខំធ្វើការងារឱ្យអស់ពីកម្លាំងកាយចិត្ត មិនត្រូវខ្ជិលច្រអូសទេ។

*៣. ត្រីមួយត្រក ស្អុយមួយស្អុយទាំងអស់*

**ក)ន័យចំ** : មានន័យថានៅក្នុងត្រកមួយ បើមានត្រីណាមួយស្អុយហើយ បើគេមិនយកត្រីស្អុយនោះចេញទេ វានឹងនាំឱ្យជះក្លិនស្អុយដល់ត្រីដទៃទៀតដែលនៅក្នុងត្រកជាមួយ។

**ខ)ន័យធៀប** : មានន័យថានៅក្នុងគ្រួសារ អង្គភាព សហគមន៍ សមាគម ឬក្នុងស្ថាប័នណាមួយ បើមានសមាជិកអ្នកណាម្នាក់ប្រព្រឹត្តអំពើអាក្រក់ ឬអំពើណាមួយដែលឆ្គាំឆ្គងមិនសមរម្យ អំពើទាំងនោះវាជះឥទ្ធិពលដល់សមាជិកដទៃទៀត គឺធ្វើឱ្យអ្នកដទៃគិតថាសមាជិកទាំងអស់នោះសុទ្ធតែអាក្រក់។

*៤. សីមៗកុំបំបោល*

**ក)ន័យចំ** : ការធ្វើដំណើរតាមរថសេះ ឬរទេះគោ គេត្រូវបររទេះដោយសន្សឹមៗ ត្រឹកៗជាការចាំបាច់ ព្រោះគេធ្វើដូច្នេះគោក្របីដែលយើងទឹមវានឹងបានធូរកម្លាំងផង រទេះក៏មិនបែកបាក់ឬអុកឡុកខ្លាំងផង។

**ខ)ន័យធៀប** : មានន័យថាត្រូវធ្វើការអ្វីៗតាមដំណើរ ត្រូវធ្វើតាមកម្លាំង ឬតាមធនធានដែលមាន មិនត្រូវបង្ខំពេកទេ ខ្លាចក្រែងវាពុំបានសម្រេច នាំឱ្យអសារឥតការ។

មេរៀនទី ៧

# ភាពជាពលរដ្ឋ

## ប្រផ្នូលនិងការរំលឹករឿងដើម

*១– ប្រផ្នូល គឺជាហេតុភេទដែលគេដឹងមុនថានឹងកើតមានព្រឹត្តិការណ៍អ្វីមួយ ។*

*ការរំលឹករឿងដើម គឺជាការផ្អាកដំណើររឿង ហើយត្រលប់ទៅលើកយកការសន្ទនា ឬព្រឹត្តិការណ៍ដែលកើតឡើងពីមុនមកបរិយាយ ។*

**លំហាត់**

ចូរអ្នកបង្ហាញពីប្រផ្នូល និងការរំលឹករឿងដើម តាមរយៈរឿងមួយចំនួនដែលអ្នកបានអាន ឬសិក្សាកន្លងមក ។

**ចម្លើយ**

**រឿងរាមាយណៈឥណ្ឌា**

+**ប្រផ្នូល** : ហនុមានទះកំភ្លៀងអ្នកតាចាស់ស្រុកដ៏ធំស្កឹមស្កៃ ដែលផុសនៅពីមុខរាំងផ្លូវ ។ នៅពេលដែលដួលនៅនឹងដីនោះ អ្នកតាបាននឹកឃើញទំនាយពីអតីតមួយដែលថា ទីក្រុងលង្កានឹងត្រូវរលាយ

ក្នុងពេលឆាប់ៗនេះ ។

**+ការរំលឹករឿងដើម :** គឺរមេនកៈនិទានរឿងរបស់ខ្លួនប្រាប់ហនុមាន ៖ "កាលពីព្រេងនាយ នៅសម័យដែលសត្វទាំងឡាយចេះនិយាយ ភ្នំទាំងអស់សុទ្ធតែមានស្លាបហោះហើរទៅនេះទៅនោះបានដូចជាមេអំបៅធំមួយ ។...."



# ពេជ្រនឹងត្រូវថ្ងៃ

## សំណួរ

១. តើអត្ថបទនេះមានចំណងជើងដូចម្ដេច? ដកស្រង់ចេញពីរឿងណា? ក្នុងឆ្នាំណា? អ្នកនិពន្ធឈ្មោះអ្វី?

២. ចូរបង្ហាញលក្ខណៈសម្បត្តិតួអង្គពូហាម ។

៣. ចូរបង្ហាញពីទស្សនៈសុទិដ្ឋិនិយមរបស់តួអង្គ ។

៤. តើនៅក្នុងអត្ថបទនេះអ្នកនិពន្ធប្រើវិធីតែងនិពន្ធដូចម្ដេចខ្លះ?

៥. តើនៅក្នុងអត្ថបទរឿងគ្រូបង្រៀនស្រុកស្រែ អ្នកនិពន្ធបានធ្វើការរំលឹករឿងដើមនៅត្រង់វគ្គណា?

៦. ចូររកតម្លៃអប់រំនៅក្នុងអត្ថបទនេះ ។

៧. តាមរយៈអត្ថបទ តើចំណុចត្រង់ណាខ្លះដែលបង្ហាញពីគំនិតពលរដ្ឋល្អ?

## ចម្លើយ

១. អត្ថបទនេះមានចំណងជើងថាពេជ្រនឹងត្រូវថ្ងៃ ។ ដកស្រង់ចេញពីរឿងគ្រូបង្រៀនស្រុកស្រែ ។ និពន្ធក្នុងឆ្នាំ១៩៥៧ ។ អ្នកនិពន្ធឈ្មោះ អ៊ុម ផុក ។

២. លក្ខណៈសម្បត្តិតួអង្គពូហាម : ហាមជាពលរដ្ឋមួយរូបដែលមានស្មារតីអភិវឌ្ឍភូមិឋានឱ្យមានភាពរីកចម្រើន។ រាល់សកម្មភាពរបស់គាត់ និងផែនការរបស់គាត់ គឺជាការបម្រើឱ្យតម្រូវការរបស់ប្រជារាស្ត្ររបស់សង្គមទាំងមូល។

៣. ទស្សនៈសុទិដ្ឋិនិយមរបស់តួអង្គ ត្រង់វគ្គដែលហាមនិយាយថា "កង់ប្រវត្តិសាស្ត្រសង្គមមនុស្សកំពុងតែវិលសំដៅទៅលទ្ធិប្រជាធិបតេយ្យ។ បើមិនឆ្នាំនេះ ឆ្នាំក្រោយ។ បើយើងមិនទាន់បាន កូនយើងធ្វើបាន។ បើកូនយើងធ្វើមិនសម្រេច ចៅយើងមុខជាសម្រេច។ បើភូមិឃុំយើងមិនទាន់កើត ក៏ភូមិឃុំផ្សេងទៀតធ្វើបាន"។ និងត្រង់ចំណុចដែលឡឹងនិយាយថា "សប្បាយហើយក្មេងជាន់ក្រោយ ខ្ញុំមុខតែទៅនិយាយប្រាប់អ្នកភូមិឫស្សីទាំងយប់នេះហើយ"។

៤. នៅក្នុងអត្ថបទនេះ អ្នកនិពន្ធប្រើវិធីតែងនិពន្ធដូចជា :

+**ពណ៌នាវិធី** : អ្នកនិពន្ធឱ្យតួអង្គហាមរៀបរាប់ពីគ្រោងការណ៍របស់ខ្លួន ប្រាប់អាចារ្យសម និងឡឹង....."។

+**និទានវិធី** : អ្នកនិពន្ធប្រើវិធីនិទានបែបបុរសទី៣។

+**សំវាទវិធី**

-ការសន្ទនារវាង ហាម អាចារ្យសម និងឡឹង

+**សន្ទេហវិធី** : អ្នកអានអាចឆ្ងល់ថា :

-តើគ្រោងការណ៍របស់ហាមបានសម្រេចដែរឬទេ?

**+វចនវិធី :** អ្នកនិពន្ធបានប្រើពាក្យពេចន៍ចម្រុះ។

- ពាក្យកម្ចីបាលីសំស្រ្កិត : អាចារ្យ ភូមិ សហគមន៍ ទុក្ខ...។
- ពាក្យសាមញ្ញ : តុះ អ្នកលេង ចិញ្ចឹមឆ្នាំង...។

៥. នៅក្នុងអត្ថបទរឿងគ្រូបង្រៀនស្រុកស្រែ អ្នកនិពន្ធបានធ្វើការរំលឹករឿងដើមនៅត្រង់វគ្គដែលហាមនិយាយរៀបរាប់ប្រាប់អាចារ្យសម "កាលពីខែមុន.............នៅខេត្តស្រុកស្រេច..."។

៦. តម្លៃអប់រំនៅក្នុងអត្ថបទនេះ ៖

-ឱ្យចេះរួមសាមគ្គីគ្នាការពារធនធានធម្មជាតិ

-ស្គាល់ពីសិទ្ធិនិងកាតព្វកិច្ចជាពលរដ្ឋក្នុងការចូលរួមអភិវឌ្ឍសង្គម

-ឱ្យមើលឃើញពីប្រយោជន៍រួមជាធំដែលជាអនាគតនៃជោគវាសនាជាតិខ្លួន

-ឱ្យមានការជឿជាក់លើសមត្ថភាពខ្លួន

-មានទស្សនៈវិជ្ជមានក្នុងជីវិត។

៧. តាមរយៈអត្ថបទ ចំណុចត្រង់ដែលបង្ហាញពីគំនិតពលរដ្ឋល្អគឺ ៖

-ចេះពិភាក្សារៀបចំផែនសម្រាប់អភិវឌ្ឍភូមិឃុំរបស់ខ្លួន

-មានគំនិតសុទិដ្ឋិនិយម -ចេះភ្ញាក់រលឹក

-ចេះសាមគ្គីគ្នា រួបរួមគ្នា -ស្គាល់កាតព្វកិច្ចខ្លួនជាពលរដ្ឋ....។

# ទម្រង់ល្បះគោល

*១– ល្បះគោល គឺជាល្បះដែលសំដែងគំនិតតែមួយច្បាស់លាស់ ពេញលេញ ហើយយ៉ាងហោចណាស់វាក៏មានប្រធានមួយ និងកិរិយាមួយដែរ ។*

ទម្រង់មូលដ្ឋាននៃល្បះគោលមាន ៖

ល → កន$_{១}$ + កកិ ។

ល → កន$_{១}$ + កិ + កន$_{២}$ ។

ល → កន$_{១}$ + កិ + កមធ់ ។

ល → កន$_{១}$ + កិ + កន$_{២}$ + កមធ ។

ល → កន$_{១}$ + កិ( ជា...) + កន$_{២}$ ។

ល → កន$_{១}$ + ∅ + កន$_{២}$ ។

ឬយើងអាចសរសេរម្យ៉ាងទៀត :

ល → កន + កកិ ( កកិ → កិ)

ល → កន + កកិ ( កកិ → កិ+កន)

ល → កន + កកិ ( កកិ→ កិ+កមធ)

ល → កន+កកិ ( កកិ → កិ + កន + កមធ)

លំហាត់

ចូរប្រាប់ពីទម្រង់ល្បះខាងក្រោម ហើយគូសគំនូសតាងល្បះទាំងនោះ ជាមែកធាង និងប្រអប់ ។

១. ហាមនិយាយពីភូមិឫស្សី ។

២. យើងត្រូវជួយអប់រំអ្នកភូមិអំពីការងារនេះ ។

៣. អាចារ្យហាមនិយាយកាត់ ។

៤. យើងជួយការពារផលប្រយោជន៍អ្នកភូមិ ។

ចម្លើយ

*+ទម្រង់នៃល្បះខាងលើ គឺ :*

១. ល → កន$_{១}$ + កិ + កមធ

២. ល → កន$_{១}$ + កិ + កន$_{២}$ + កមធ

៣. ល → កន$_{១}$ + កកិ

៤. ល → កន$_{១}$ + កិ + កន$_{២}$

*+តាងល្បះខាងលើជាមែកធាង :*

១)


ល
កន
កកិ
កិ
កមធ
ធ
កន
ហម
និយាយ
ពី
ភូមិឫស្សី ។

២)


ល
កន
កកិ
កិ
កន
កមធ
ធ
កន
យើង
ត្រូវជួយអប់រំ
អ្នកភូមិ
អំពី
ការងារនេះ ។

៣)




៤)



+តាងល្បះខាងលើជាប្រអប់ :

១)




២)



៣)

| អាចារ្យហាម | និយាយកាត់ |
|---|---|
| កន | កកិ |

៤)

| យើង | ជួយការពារ | ផលប្រយោជន៍អ្នកភូមិ |
|---|---|---|
| | កិ | កន |
| កន | កកិ | |

# សញ្ញាពិសេសរបស់កំណាព្យ

| ឈ្មោះ | គំនូសភ្ជាប់ព្យាង្គ បំណកស្រាយ |
|---|---|
| ចួន |  |
| ផ្ទួន |  |
| រណ្ដំ |  |

**១. ចួន** : ជាពាក្យទាំងឡាយដែលមានព្យាង្គកើតឡើងដោយស្វរស្រៈដូចគ្នា ឬព្យញ្ជនៈប្រកបដូចគ្នា ឬស្វរស្រៈ និងព្យញ្ជនៈប្រកបដូចគ្នា។

**២. ផ្ទួន** : គឺជាព្យាង្គតែមួយដែលកវីប្រើច្រើនដងក្នុងឃ្លា ឬវគ្គ។

**៣. រណ្ដំ** : គឺជាការប្រើព្យញ្ជនៈតែមួយ ឬស្រៈតែមួយដដែលៗ ច្រើនដងក្នុងឃ្លា ឬវគ្គ។



# ច្បាប់ក្រូនចៅ

**សំណួរ**

១. តើអត្ថបទកាព្យខាងលើជាបទអ្វី?

២. តើពាក្យ "អាពុក" ក្នុងអត្ថបទនេះសំដៅលើនរណា?

៣. ចូរបង្ហាញចំណាប់ចួន ផួន រណ្ដំ និងរង្វាស់កាព្យរបស់អត្ថបទកាព្យ ខាងលើនេះ។

៤. វគ្គទីមួយរបស់កំណាព្យនេះអ្នកនិពន្ធចង់អប់រំដូចម្ដេចខ្លះ?

៥. តើអត្ថបទនេះអប់រំដូចម្ដេចខ្លះ ដើម្បីឱ្យក្លាយជាពលរដ្ឋល្អ?

៦. តើអ្នកត្រូវធ្វើដូចម្ដេចខ្លះ ដើម្បីឱ្យក្លាយជាពលរដ្ឋល្អ?

**ចម្លើយ**

១. អត្ថបទកាព្យខាងលើជាបទកាកគតិ។

២. ពាក្យ "អាពុក" ក្នុងអត្ថបទនេះសំដៅលើអ្នកមានគុណ៖

- ឪពុកម្ដាយ
- ជីដូនជីតា
- ចាស់ព្រឹទ្ធាចារ្យ
- បុព្វបុរស

៣. ចំណាប់ចួន ផ្ទួន រណ្តំ និងរង្វាស់កាព្យរបស់អត្ថបទកាព្យខាងលើ

**+គំនូសតាង :**



**+ចំណាប់ចួន**

**+ចួនក្នុងវគ្គ**

ព៤ ឃ១ |═══| ព៤ ឃ២

ព៤ ឃ៣ |═══| ព៤ ឃ៥ |═══| ព៤ ឃ៦

**+ចួនឆ្លងវគ្គ**

ព៤ ឃ៧ វ១|═══| ព៤ ឃ៣ វ២

+**ផ្ទួន** : អាពុក កូនចៅ ...

+**វណ្ណ** : ចូរ |—| ចេះ. រាប់ |—| រក. គ្នី |—| គ្នា.
អត់ |—| ឱន. នឹង |—| នៅ. មួយ |—| ម៉ាត់.
ទោះ |—| ទូក. បែក |—| បាក់. ធ្លុះ |—| ធ្លាយ.
ផ្គត់ |—| ផ្គង់. លោភ |—| លន់. បំពារ |—| បំពាន.
បុណ្យ |—| បាប. យឺន |—| យូរ. បើ |—| បា.
ចាក់ |—| ចូល.....។

+**វង្វាស់កាព្យឬកាព្យមាត្រ**

-១វគ្គ មាន៧ឃ្លា

-១ឃ្លា មាន៤ព្យាង្គ

៤. វគ្គទីមួយរបស់កំណាព្យនេះអ្នកនិពន្ធចង់អប់រំឱ្យចេះស្រឡាញ់រាប់រកគ្នា ចេះអត់ឱនឱ្យគ្នា និងចេះរក្សាពូជពង្ស ។។

៥. តាមរយៈអត្ថបទនេះ ដើម្បីឱ្យក្លាយជាពលរដ្ឋត្រូវ ៖

-ចេះស្រលាញ់រាប់អានគ្នា

-កុំអាងបុណ្យាសក្តិធ្វើបាបគេ

-កុំមានចិត្តលោភលន់

-ប្រកាន់ខ្ជាប់នូវសីលធម៌ ( ស្គាល់ល្អអាក្រក់ បាបបុណ្យ)

-កុំដើរប៉ោឡៃ

-ត្រូវមានមារយាទល្អ ( ទាំងស្រី ទាំងប្រុស)

-ត្រូវចេះប្រើសម្ដីពិរោះ ពាក្យពិត

-ត្រូវចេះគោរពចាស់ទុំ គោរពគ្រូបាអាចារ្យ

-វៀរចាកអំពើអបាយមុខ ( ស្រី ស្រា ល្បែង អំពើពាល)

-..................................................

៦. ដើម្បីឱ្យក្លាយជាពលរដ្ឋល្អ ខ្ញុំត្រូវ :

-ខិតខំរៀនសូត្រឱ្យបានពូកែ

-ខិតខំធ្វើការងារដើម្បីរកប្រាក់ចិញ្ចឹមគ្រួសារ

-គោរពច្បាប់របស់ប្រទេស

-គោរពសិទ្ធិមនុស្ស

-ប្រកាន់ខ្ជាប់នូវសីលធម៌

-មិនសេពគ្រឿងញៀន

-មិនប្រើអំពើហិង្សា

មេរៀនទី ៨

# ការសម្រេចចិត្ត

## ការសម្រេចចិត្តរបស់អាគីរ៉ា

**សំណួរ**

១. តើអត្ថបទខាងលើនេះចាត់ទុកជាអត្ថបទល្ខោនបានដែរឬទេ? ព្រោះអ្វី?

២. ចូរវិភាគតួអង្គកូស្វ ព្រមទាំងបង្ហាញអំណះអំណាងតាមរយៈអត្ថបទ។

៣. តើអត្ថបទខាងលើផ្តល់តម្លៃអប់រំយ៉ាងដូចម្តេចខ្លះ?

៤. តើការសម្រេចចិត្តរបស់អាគីរ៉ា មិនឱ្យគេយកប្រពន្ធ (នាងយូរី) ទៅបូជាយញ្ញនេះត្រឹមត្រូវដែរឬទេ? ព្រោះអ្វី?

៥. តើអត្ថបទនេះបានបង្ហាញពីជំនឿ និងផ្នត់គំនិតរបស់ប្រជាជនជប៉ុនសម័យបុរាណយ៉ាងដូចម្តេចខ្លះ?

៦. តើការយកជីវិតមនុស្សម្នាក់ទៅបូជាយញ្ញបែបនេះចាត់ទុកជាអំពើរំលោភសិទ្ធិមនុស្សដែរឬទេ? ព្រោះអ្វី? ចូរបង្ហាញអំណះអំណាងតាមរយៈអត្ថបទ។

ចម្លើយ

១. អត្ថបទខាងលើនេះអាចចាត់ទុកជាអត្ថបទល្ខោនបាន ព្រោះរចនាបថនៃសំណេរមានវាយឈ្មោះតួអង្គ និងមានពាក្យសន្ទនារបស់តួអង្គផ្ទាល់ ។

២. វិភាគតួអង្គកូស្វ :

**+គុណសម្បត្តិ**

-ចង់ឱ្យប្រជាជនរស់នៅដោយសេចក្ដីសុខ

-គោរពជំនឿពីដូនតា ធ្វើពិធីបូជាយញ្ញថ្វាយអាទិទេពដើម្បីជួយជីវិតមនុស្សប្រាំបីពាន់នាក់ ។

-មានស្មារតីស្នេហាជាតិ ជួយមនុស្សទូទៅនិងលះបង់ខ្ពស់

**+គុណវិបត្តិ**

-កូស្វ ជាតួអង្គប្រើអំណាចផ្ដាច់ការ ឃោរឃៅ គ្មានចិត្តអាណិតអាសូរប្រជាជន ។

-មិនចេះពិចារណា ល្ងង់ខ្លៅ ជឿងុបងល់ទៅលើជំនឿអរូបីគ្មានគំនិតវិទ្យាសាស្ត្រ ។

៣. អត្ថបទខាងលើផ្ដល់តម្លៃអប់រំឱ្យចេះគោរពសិទ្ធិមនុស្ស និងបំបាត់ចោលនូវជំនឿអរូបីមិនសមហេតុផល ។

៤. ការសម្រេចចិត្តរបស់អាតីរ៉ា មិនឱ្យគេយកប្រពន្ធ (នាងយូរី) ទៅ

បូជាយញ្ញនេះជាការត្រឹមត្រូវ ព្រោះនាងយូរីក៏ជាមនុស្សដូចគេឯងដែរ ដូច្នេះនាងក៏មានសិទ្ធិរស់រានមានជីវិត និងមានសេចក្ដីថ្លៃថ្នូរព្រមទាំងរួមរស់ជាមួយប្ដីប្រពន្ធដោយភាពសុខសាន្ត។

៥. អត្ថបទនេះបានបង្ហាញពីជំនឿ និងផ្នត់គំនិតរបស់ប្រជាជនជប៉ុនសម័យបុរាណដូចជា :

-ជឿលើជំនឿអរូបី ដូចជាពិធីបូជាយញ្ញ...

-ជឿលើអាទិទេព ហ៊ានលះបង់ជីវិតថ្វាយអាទិទេព ដើម្បីឱ្យអាទិទេពជួយវិញ

-ភក្ដីភាពរវាងស្វាមីភរិយា

៦. ការយកជីវិតមនុស្សម្នាក់ទៅបូជាយញ្ញបែបនេះ យើងចាត់ទុកជាអំពើរំលោភសិទ្ធិមនុស្ស ព្រោះមនុស្សម្នាក់ៗមានសិទ្ធិរស់រានមានជីវិតដូចគ្នា។ គ្មានរណាមានសិទ្ធិមកបៀតបៀនជីវិតគេបានឡើយ។ ជីវិតរបស់យើងម្នាក់ៗត្រូវបានការពារដោយច្បាប់។

# ល្បះផ្សំ

*១— ល្បះផ្សំ គឺជាល្បះកើតឡើងពីការពង្រីកនៃល្បះគោល ដែលមានធាតុសំណង់ណាមួយនៃឃ្លា ឬល្បះសម្រាប់ពង្រីកល្បះដើម ។*

*ឃ្លារណប អាចជាឃ្លានាម ឃ្លាគុណនាម ឃ្លាទេសកាល... ។*

## លំហាត់

ចូរតែងខាងក្រោមជាមែកធាង និងប្រអប់ ៖

១. បុប្ផាសង្ឃឹមថា គេនឹងប្រលងជាប់នៅឆ្នាំនេះ ។

២. យើងត្រូវរៃក្សាប្រពៃណី ដែលជាកេរដំណែលរបស់ដូនតា ។

៣. យុទ្ធជនខិតខំការពារបូរណភាពទឹកដី ដើម្បីប្រជាជនរស់នៅសុខសាន្ត ។

## ចម្លើយ

១)




បុប្ផា
សង្ឃឹម
កន
កកិ
ឃ្លាច្បង
ថា
គេនឹងប្រឡងជាប់នៅឆ្នាំនេះ។
ឈ្នាប់ឃ្លា
ឃ្លា
ឃ្លារណប

២)


ល
កន
កកិ
កិ
កន
កន
ឃ្លារណប
សព្វ.ឈ្នាប់
កកិ
កិ
កន
ន
កមធ
ធ
កន
យើង ត្រូវថែរក្សា ប្រពៃណី ដែល ជា កេរដំណែល របស់ ដូនតា។


យើង
ថែ
រក្សា
ប្រពៃ
ណី
កិ
កន
កន
កកិ
ឃ្លាច្បង
ដែល៉
ជាកេរដំណែល
របស់ដូនតា។
សព្វ. ឈ្នាប់
ឃ្លា
ឃ្លារណប

៣)


ល
កន
កកិ
កិ
កន
កន
ឃ្លារណប
ឈ្នាប់ឃ្លា
កន
កកិ
កិ
គុណ
យុទ្ធជន ខិតខំការពារ បូរណភាពទឹកដី ដើម្បី ប្រជាជន រស់នៅ សុខសាន្ត។


យុទ្ធ
ជន
ខិតខំ
ការពារ
បូរណ
ភាពទឹកដី
កិ
កន
កន
កកិ
ឃ្លាច្បង
ដើម្បី
ប្រជាជនរស់
នៅសុខសាន្ត ។
ឈ្នាប់ឃ្លា
ឃ្លា
ឃ្លារណប



# ពិធីរៀបការរបស់ជនជាតិឥណ្ឌាបុរាណ

**សំណួរ**

១. តាមគម្ពីរមនុ តើស្ត្រីពេញវ័យមានលក្ខណៈសម្បត្តិបែបណាទើបអាចរៀបការបាន?

២. ដូចម្តេចហៅថា "សប្តបទិ" ? ហើយវាមានន័យដូចម្តេចខ្លះ?

៣. ចូរបង្ហាញអត្ថន័យ "វិវាហៈ" តាមគម្ពីរមនុ ។

៤. តាមទម្លាប់អាពាហ៍ពិពាហ៍របស់ជនជាតិហិណ្ឌូ គេយកអ្វីជាសាក្សី? ព្រោះអ្វី?

៥. ដូចម្តេចហៅថា "ពហុបតិភាព"?

៦. តាមរយៈអត្ថបទនេះ តើទំនៀមទម្លាប់ណាមួយដែលខ្មែរយើងប្រកាន់យកដូចឥណ្ឌាដែរ?

**ចម្លើយ**

១. តាមគម្ពីរមនុ ស្ត្រីពេញវ័យដែលអាចរៀបការបានគឺស្ត្រីមិនវិកលរាងកាយ មានឈ្មោះគួរសេពគប់ មានដំណើរល្ដាយល្ដងដូចដំរី រោមខ្លួន ឬសក់មានចំនួនតិច ធ្មេញល្អិតរីមពីរមាត់ល្អ ។

២. "សប្តបទិ" គឺជារបៀបមង្គលការដែលមានការប្រោះព្រំទឹក បាចម្សៅក្រហម ដើរប្រាំពីរជំហាន ។ វាមានន័យថា :

-ជំហានទី១ ទុកជា អំណាច

-ជំហានទី២ ទុកជា កម្លាំង

-ជំហានទី៣ ទុកជា សេចក្ដីសុខ

-ជំហានទី៤ ទុកជា សេចក្ដីចម្រើន

-ជំហានទី៥ ទុកជា កូនចៅ

-ជំហានទី៦ ទុកជា រដូវ

-ជំហានទី៧ ទុកជា មិត្រសម្លាញ់

៣. តាមគម្ពីរមនុ "វិវាហៈ" មានន័យថាការរៀបចំកូនប្រុសស្រីឱ្យជាស្វាមីភរិយា ។

៤. តាមទម្លាប់អាពាហ៍ពិពាហ៍របស់ជនជាតិហិណ្ឌូ គេយកអគ្គិជាសាក្សី ព្រោះអគ្គិជាទេវតាសក្តិសិទ្ធិពិតរបស់ជនហិណ្ឌូ ។

៥. "ពហុបតិភាព" មានន័យថា ភាពដែលភរិយាអាចមានប្ដីច្រើន ។

៦. តាមរយៈអត្ថបទនេះ ទំនៀមទម្លាប់ដែលខ្មែរយើងប្រកាន់យកដូចតណ្ហាត្រង់ ៖

-ឱ្យហោរាគន់គូរមើលឫក្សពេលា

-និងប្រុសមិនយកស្ត្រីជាញាតិធ្វើភរិយាទេ

-ការរៀបការជាភារៈរបស់មាតាបិតា

# ការឆ្លើយតបនឹងការបញ្ចុះបញ្ចូល

៙— *ការបញ្ចុះបញ្ចូល គឺជាការអូសទាញ បបោលអន្ទង ការទាក់ទាញទឹកចិត្ត... ដោយមធ្យោបាយផ្សេងៗ ដើម្បីឱ្យអ្នកដទៃទទួលយក ឬសម្រេចបំណងណាមួយ ។*

**លំហាត់**

ចូរអ្នកឆ្លើយតបទៅនឹងការបញ្ចុះបញ្ចូលរបស់អ្នកដទៃក្នុងបំណងឱ្យអ្នក ៖

១. ឈប់រៀនដើម្បីទៅដើររកការងារធ្វើ ។

២. ជក់បារី ។

៣. គេចវេះពីការសិក្សាដើម្បីទៅដើរលេង ។

៤. ប្រើប្រាស់គ្រឿងញៀន ។

# សោភ័ណសិល្បៈ

## ជំនួយកិរិយា និងប្រភេទនៃជំនួយកិរិយា

*ខ- ជំនួយកិរិយា គឺជាកិរិយាសម្រាប់ប្រើបង្រួបន័យសេចក្តីរបស់កិរិយាសព្ទណាមួយ ។*

*ជំនួយកិរិយា ជាធាតុវេយ្យាករណ៍សម្រាប់ប្រាប់លទ្ធផល ទិសដៅ កាល និងតម្លៃទិដ្ឋភាពរបស់កិរិយាសព្ទបង្គោល ។*

ជំនួយកិរិយា មាន ៖

១. **កិរិយាបំពេញ** : (ខាងស្តាំកិរិយាបង្គោល) ប្រើសម្រាប់បង្រួបន័យសេចក្តីរបស់កិរិយាបង្គោលលើចំណុចពីរ គឺលទ្ធផលនៃអំពើ និងលទ្ធផលសម្រេចនៃអំពើ មាន ដូចជា: ឃើញ ភាន់ លក់ ឮ ចេះ បាន កើត រួច ក៏មាន ក៏បាន..... ។

២. **កិរិយាទិសដៅ** : (ខាងស្តាំកិរិយាបង្គោល) ប្រើជាមួយកិរិយាសព្ទ សម្រាប់ប្រាប់ទិសដៅនៃអំពើរបស់កិរិយាបង្គោលនោះ ។ កិរិយាទិសដៅ មានដូចជា : ឡើង ចុះ មក ចេញ ចូល កាត់ តាម ... ។

**៣. កិរិយាខាងដើម :** (នៅខាងឆ្វេងកិរិយា) សម្រាប់ប្រាប់តម្លៃនៃភាព តម្លៃទិដ្ឋភាព ឬតម្លៃកាលនៃអំពើ។ កិរិយាខាងដើមមានដូចជា ចង់ ចូលចិត្ត ប៉ង ប្រាថ្នា អាច បាន មាន ត្រូវ ធ្លាប់ចេះ ក្រ....។

**លំហាត់**

១. តើពាក្យណាខ្លះក្នុងល្បះខាងក្រោម ដែលជាកិរិយាបំពេញ?

ក. ពូផាដើរខ្លួនឯងកើត ។

ខ. ខ្ញុំស្តាប់ពូវ៉ានិយាយ ។

គ. វិទ្ធីរៀនចេះ ។

២. តើពាក្យណាខ្លះក្នុងល្បះខាងក្រោម ដែលជាកិរិយាទិសដៅ?

ក. ខ្ញុំសុំសៀវភៅមួយមក ។

ខ. សូមក្រោកឡើង ។

គ. សុខាយកនង្គ័លចូលផ្ទះ ។

៣. តើពាក្យណាខ្លះក្នុងល្បះខាងក្រោម ដែលជាកិរិយាខាងដើម?

ក. តើបងមានស្គាល់បុរាណវត្ថុអ្វីខ្លះ?

ខ. គាត់ចង់ឆ្លាក់រូបអប្សរា ។

គ. ម្សិលមិញខ្ញុំបានទៅលេងអង្គរ ។

៤. ចូរតែងល្បះដោយប្រើ ៖

ក. កិរិយាបំពេញ : បាន ក៏បាន ចេះ កើត ។

ខ. កិរិយាទិសដៅ : ជូន ចេញ កាត់ តាម ។

គ. កិរិយាខាងដើម : បាន មាន ចូលចិត្ត អាច ។

**ចម្លើយ**

១. ពាក្យដែលជាកិរិយាបំពេញក្នុងល្បះខាងលើ :

ក. កើត

ខ. ឮ

គ. ចេះ

២. ពាក្យដែលជាកិរិយាទិសដៅក្នុងល្បះខាងលើ :

ក. មក

ខ. ឡើង

គ. ចូល

៣. ពាក្យដែលជាកិរិយាខាងដើមក្នុងល្បះខាងលើ :

ក. មាន

ខ. ចង់

គ. បាន

៤. ចូរតែងល្បះដោយប្រើ ៖

ក. កិរិយាបំពេញ : បាន ក៏បាន ចេះ កើត ។

-ខ្ញុំរើស *បាន* លុយ៥០០០រៀល ។

-វាអាចធ្វើនេះ *ក៏បាន* ធ្វើនោះ *ក៏បាន* ។

-សុខារៀនភាសាអង់គ្លេសមិន *ចេះ* សោះ ។

-ខ្ញុំធ្វើការងារនេះ *កើត* ។

ខ. កិរិយាទិសដៅ : ជូន ចេញ កាត់ តាម ។

-ខ្ញុំយកបាយសម្ល *ជូន* លោកយាយខ្ញុំនៅឯវត្ត ។

-ក្មេងៗ *រត់* ចេញតាមទ្វាររបង ។

-ហាមដើរ *កាត់* ទីធ្លាសាលា ។

-កុំដើរ *តាម* ខ្ញុំ ។

គ. កិរិយាខាងដើម : បាន មាន ចូលចិត្ត អាច ។

-លោក *បាន* និយាយរឿងនេះរួចហើយ ។

-តើវា *មាន* រករឿងឯងទេ?

-អ្នកនេះ *ចូលចិត្ត* និយាយច្រើនណាស់ ។

-ប្អូនខ្ញុំ *អាច* លេងព្យាណូបានយ៉ាងល្អ ។



# រឿងសុបិនកុមារ

## សំណួរ

១. ហេតុអ្វីបានជាឪពុករបស់សុបិនកុមារធ្លាក់ទៅរងទុក្ខទោសនៅឋាននរក?

២. ហេតុអ្វីបានជាយមបាលយកព្រលឹងម្ដាយសុបិនកុមារទៅឋាននរក?

៣. តើមានហេតុការណ៍កើតឡើងដូចម្ដេចខ្លះ នៅពេលយមបាលធ្វើទារុណកម្មព្រលឹងម្ដាយសុបិនកុមារ?

៤. តើអានិសង្សសាងផ្នួសរបស់សុបិនកុមារហុចផលដូចម្ដេចខ្លះ?

៥. ចូរបង្ហាញពីកាលអាកាសរបស់រឿង ។

៦. តើរឿងនេះអាចចាត់ទុកជាអក្សរសិល្ប៍បែបពុទ្ធនិយម ព្រាហ្មណ៍និយម ឬខេមរនិយម? ចូរបង្ហាញអំណះអំណាង ។

## ចម្លើយ

១. បានជាឪពុករបស់សុបិនកុមារធ្លាក់ទៅរងទុក្ខទោសនៅឋាននរកព្រោះគាត់មានបាបកម្មក្នុងការនេសាទ ។

២. បានជាយមបាលយកព្រលឹងម្ដាយសុបិនកុមារទៅឋាននរកព្រោះម្ដាយសុបិនកុមារមានកំហុសមិនព្រមឱ្យកូនទៅសាងផ្នួស ។

៣. នៅពេលយមបាលធ្វើទារុណកម្មព្រលឹងម្ដាយសុបិនកុមារក៏ស្រាប់

តែមានផ្កាឈូកផុសឡើងទ្រទ្រគាត់ឱ្យផុតពីភ្លើងកុំឱ្យក្តៅដល់ ។

៤. អានិសង្សសាងផ្នួសរបស់សុបិនកុមារ បានធ្វើឱ្យព្រលឹងនាយនេសាទជាឪពុកដែលបានធ្វើមរណកាលអស់ពេលដ៏យូរ ហើយរងទុក្ខក្នុងរណ្តៅនរក ក៏បានរួចរំដោះកម្មនោះ និងបានទៅសោយសុខក្នុងឋានសួគ៌វិញ ។

៥. កាលអាកាសរបស់រឿង :

+កាល : កាលពីដើម ចំណេរកាលក្រោយមក លុះថ្ងៃក្រោយ ខណៈនោះ ពេលនោះ ...

+អាកាស : ឋានកណ្តាល ឋាននរក ឋានសួគ៌

៦. រឿងនេះអាចចាត់ទុកជាអក្សរសិល្ប៍បែបពុទ្ធនិយម ព្រោះបង្ហាញពីបញ្ហាកម្មផល មានឋាននរក ឋានសួគ៌ និងមានការសាងផ្នួស ។

# ប្រាសាទបន្ទាយស្រី

**សំណួរ**

១. តើប្រាសាទបន្ទាយស្រីមានសោភ័ណភាពដូចម្ដេចខ្លះ?

២. តើនរណាជាអ្នកកសាងប្រាសាទនេះ?

៣. ហេតុអ្វីបានជាយើងចាត់ទុកប្រាសាទបន្ទាយស្រីជាវត្ថុមានតម្លៃ?

៤. តើចម្លាក់ប្រាសាទបន្ទាយស្រីមានតម្លៃអ្វីខ្លះ ចំពោះជាតិ និង អន្តរជាតិ?

៥. តើមានទស្សនៈបែបណាចំពោះទឹកដៃចម្លាក់ស្ថាបត្យកម្ម សំណង់ប្រាសាទខ្មែរ?

៦. តើអត្ថបទខាងលើនេះឆ្លុះបញ្ចាំងនូវសោភ័ណភាពសិល្បៈដូចម្ដេចខ្លះ?

**ចម្លើយ**

១. ប្រាសាទបន្ទាយស្រីមានសោភ័ណភាពល្អវិសេសជាងគេ មាន ក្បាច់ល្អិតឆ្មារ រស់រវើកជាងប្រាសាទនានា។

២. អ្នកកសាងប្រាសាទនេះគឺព្រះគ្រូជ្ញវរាជហៈ ។

៣. បានជាយើងចាត់ទុកប្រាសាទបន្ទាយស្រីជាវត្ថុមានតម្លៃ ព្រោះ ថាប្រាសាទនេះកសាងក្នុងសម័យបុរាណ ព្រោះប្រាសាទនេះមាន សោភណភាពសិល្បៈដែលពោរពេញដោយក្បាច់ រចនាល្អវិសេស

វិសាល ត្រចះត្រចង់ដែលមិនអាចរកអ្វីមកប្រៀបប្រដូចបាន។ ប្រាសាទនេះត្រូវបានគេចាត់ទុកជាសម្បត្តិវប្បធម៌របស់ជាតិ ជាដួងព្រលឹងជាតិ ជាតំណាងឱ្យនូវបញ្ញាញាណរបស់ជាតិដែលពុំអាចកាត់ថ្លៃបាន។

៤. ចម្លាក់ប្រាសាទបន្ទាយស្រីមានតម្លៃពុំអាចកាត់ថ្លៃបាន ចំពោះជាតិ និងអន្តរជាតិ ព្រោះវាបានបង្ហាញពីទឹកដៃដ៏ល្អឯកគ្មានពីរដែលអាចទាក់ទាញភ្ញៀវទេសចរឱ្យត្រេកត្រអាលនឹងសម្រស់ផ្ទាំងសិលានេះ ហើយវាគឺជាប្រភពប្រាក់ចំណូលដ៏សំខាន់ចំពោះសេដ្ឋកិច្ចជាតិ។

៥. ចំពោះទឹកដៃចម្លាក់ស្ថាបត្យកម្មសំណង់ប្រាសាទខ្មែរ ខ្ញុំយល់ថាបុព្វបុរសខ្មែរ ជាអ្នកមានទេពកោសល្យខ្ពស់ មានបញ្ញាញាណវាងវៃ មានការតស៊ូអំណត់ព្យាយាម និងមានការលះបង់ខ្ពស់ទើបអាចរចនាបាននូវប្រាសាទដ៏ល្អប្រណីតនេះបាន។

៦. អត្ថបទខាងលើនេះឆ្លុះបញ្ចាំងនូវសោភ័ណភាពសិល្បៈត្រង់ថា បានបង្ហាញនូវភាពរស់រវើកនៃក្បូរក្បាច់រចនានៅលើជញ្ជាំងប្រាសាទដែលបង្ហាញពីទេពកោសល្យដ៏ប៉ិនប្រសប់គ្មានពីរនៃបុព្វបុរសខ្មែរ បង្ហាញពីអរិយធម៌ដ៏ខ្ពង់ខ្ពស់នាសម័យអតីតកាល និងបង្កប់គំនិតឈ្លាសវៃ ច្នៃប្រឌិត និងបញ្ញាញាណនៃបុព្វបុរសខ្មែរ។

# របាំគោះអង្រែ

**សំណួរ**

១. តើរបាំគោះអង្រែ ជារបាំប្រភេទណា ?

២. តើរបាំនេះ មានប្រភពមកពីណា ?

៣. តើគេលេងរបាំនេះនៅពេលណា ?

៤. តើរបាំនេះមានតម្លៃអប់រំដូចម្តេចខ្លះ ចំពោះសិល្បៈវប្បធម៌ខ្មែរនាសម័យបច្ចុប្បន្ន ?

៥. តើរបាំនេះមានទំនុកច្រៀងដូចម្តេច? ចូរច្រៀងឡើងវិញម្តងទៀត ។

**ចម្លើយ**

១. របាំគោះអង្រែ ជារបាំប្រជាប្រិយខ្មែរ ។

២. របាំនេះមានប្រភពមកពីជនជាតិកួយ ដែលរស់នៅសំរោងចុងកាល់ ដាំក្បាន្តដែលគេចាត់ទុកជាអារ្យធម៌ខ្មែរដើម ពុំទាន់មានអារ្យ-ធម៌សាសន៍ផ្សេងៗហូរចូលដូចជាអារ្យធម៌ឥណ្ឌាជាដើម ។

៣. គេលេងរបាំនេះក្នុងពិធីបុណ្យទាន ឬពិធីអ្វីមួយដែលជាលក្ខណៈបុណ្យប្រពៃណីរបស់ខ្លួន ។ គេលេងនៅពេលសម្រាកពីការងារ

របស់ពួកគេដើម្បីបន្ថយនូវបរិយាកាសនឿយហត់។ របាំនេះគេនិយមសំដែងបំផុតក្នុងពិធីបុណ្យចូលឆ្នាំ និងរដូវច្រូតកាត់ ដូចជាបុណ្យដាលានជាដើម។

៤. តម្លៃអប់រំនៃរបាំនេះគឺ :

-ឱ្យចេះសាមគ្គីគ្នា រាប់អាន ស្និទ្ធស្នាល ស្វាហាប់

-ឱ្យមានភាពរហ័សរហួន

-បង្ហាញពីអត្តសញ្ញាណសិល្បៈរបស់ខ្មែរ

-បង្ហាញពីអរិយធម៌របស់ជាតិ

៥. ទំនុកច្រៀងនៃរបាំនេះមានគឺ ៖

១-សារិកាកែវអើយ　　សារិកាកែវកើច

បងលោមឱ្យសើច　　ចង់មើលធ្មេញខ្មៅ។

២-ស្រីស្រស់ប្រហើរ　　ស្រីស្រស់ប្រហើរ

ប្រយ័ត្នជើងដើរ　　ក្រែងអង្រែដជើង។

៣-ទន់អើយស្រីទន់　　ទន់អើយស្រីទន់

លើកដៃល្វាសល្វន់　　ស្រីរាំលោតអង្រែ។

(បន្ទរ) មែនហើយ អាដែងមែនហើយ!

**ទំនុកច្រៀងមួយបែបទៀត :**

១-របាំអើយវង់តូច　(បន្ទរ)　ហ្គាំវើយវង់តូច !

មិនដូចវង់ធំ　(បន្ទរ)　ហ្គាំវើយវង់ធំ !

របាំអើយកនខ្ញុំ ទើបតែរៀនថ្មី !

(បន្ទរ) ទើបតែហ៊ាំរៀនថ្មី !

២-អង្គួចអើយដេញដៀវ (បន្ទរ) ហ៊ាំរើយដេញដៀវ !

សាដៀវដេញផង (បន្ទរ) ហ៊ាំរើយដេញផង !

បើស្រីដោយបង ដឹងខ្លួនដោយស្លាថ្នាត់

(បន្ទរ) ហ៊ាំរើយស្លាថ្នាត់ ។

បញ្ជាក់ : ត្រង់ពាក្យថា "ហ៊ាំរើយ" គេស្រែកទទួលច្រើនគ្នាអ៊ូអរ ។

១៧

## រឿងបណ្ដែតប្រទីប សំពះព្រះខែ អកអំបុក

### សំណួរ

១. តើព្រះពុទ្ធទាំងប្រាំអង្គក្នុងរឿងនេះ ព្រះនាមអ្វីខ្លះ? ហេតុដូចម្ដេចបានជាមានព្រះនាមបែបនេះ?

២. តើប្រវត្តិនៃតួអង្គព្រះពុទ្ធទាំងប្រាំអង្គនេះ បានផ្ដល់តម្លៃអប់រំយ៉ាងណាខ្លះ? ចូរញ្ជាក់ ។

៣. ហេតុដូចម្ដេចបានជាប្រជារាស្ត្រខ្មែរនិយមពិធីអកអំបុក សំពះព្រះខែ ។

៤. តើកត្តាចំបងអ្វីខ្លះ ដែលនាំឱ្យទន្សាយពោធិសត្វសុខចិត្តលះបង់អាយុជីវិតឱ្យដល់ព្រាហ្មណ៍? តើការលះបង់បែបនេះ មាននៅក្នុងទ្រឹស្ដី ឬលទ្ធិណាមួយ?

៥. ចូរអ្នកឆ្លុះបញ្ចាំងតាមរយៈអត្ថបទនេះ អំពីជំនឿរបស់ជនជាតិខ្មែរ ។

ចម្លើយ

១. ព្រះពុទ្ធទាំងប្រាំអង្គក្នុងរឿងនេះ មានព្រះនាមថា :

-ព្រះកកុសន្ធោ ( មាន់)

-ព្រះកោនាគមនោ ( នាគ)

-ព្រះកស្សបោ ( អណ្តើក)

-ព្រះគោតមោ ( គោ)

-ព្រះសិរីអារ្យមេត្តេយ្យោ ( ខ្លា)

បានជាមានព្រះនាមបែបនេះ ព្រោះអ្នកទាំងប្រាំនាក់ធ្វើតាមបណ្តាំរបស់សត្វទាំងប្រាំ ដែលជាអ្នកចិញ្ចឹមបីបាច់ខ្លួនជាការតបស្នងសងគុណ ។

២. ប្រវត្តិនៃតួអង្គព្រះពុទ្ធទាំងប្រាំអង្គនេះ បានផ្តល់តម្លៃអប់រំដល់យើងដូចជា :

-ត្រូវមានព្រហ្មវិហារធម៌ចំពោះកូន

-ចេះកតញ្ញូចំពោះអ្នកមានគុណ

-ឱ្យចេះគោរពពាក្យសន្យា

-ចេះទំនុកបម្រុងអ្នកមានគុណ

-ឱ្យចេះស្មោះត្រង់ចំពោះគ្នា

-ត្រូវចេះធ្វើបុណ្យឧទ្ទិសមគ្គផលដល់បុព្វការីជនរបស់ខ្លួន

៣. បានជាប្រជារាស្ត្រខ្មែរនិយមពិធីអកអំបុក សំពះព្រះខែ ក្នុងគោលរំលឹកដល់កំណើតដល់ព្រះសម្មាសម្ពុទ្ធ កាលព្រះអង្គយោនយកកំណើតជាសត្វទន្សាយ ។

៤. កត្តាចំបងដែលនាំឱ្យទន្សាយពោធិសត្វសុខចិត្តលះបង់អាយុជីវិតឱ្យដល់ព្រាហ្មណ៍ គឺការប្រាថ្នាត្រាស់ដឹងជាព្រះសម្មាសម្ពុទ្ធ ។ ការលះបង់បែបនេះ មាននៅក្នុងទ្រឹស្តីព្រះពុទ្ធសាសនា ។

៥. ការឆ្លុះបញ្ចាំងអំពីជំនឿរបស់ជនជាតិខ្មែរ តាមរយៈអត្ថបទនេះ

-ពិធីសែនព្រេនរំលឹកដល់បុព្វការី

-ការគូសសញ្ញាជើងក្អែកលើវត្ថុសំណែន រួចបណ្តែតតាមខ្សែទឹក

# សញ្ញាកត់សូរអន្តរជាតិ

***សញ្ញាកត់សូរអន្តរជាតិ (API) មាននាទីសំខាន់ក្នុងការបញ្ជាក់ពីសូរខ្មែរភាសា ។***

(API : A = Alphabet, P = Phonetic, I = International)

<u>សូរព្យញ្ជនៈ និង API</u>

| | | | | | | |
|---|---|---|---|---|---|---|
| ក-គ | ខ-ឃ | ង៉-ង | ច-ជ | ឆ-ឈ | ញ៉-ញ | ដ-ឌ |
| [k] | [kh] | [ŋ] | [c] | [ch] | [ɲ] | [d] |
| ត-ទ | ថ-ធ | ណ-ន | ប-ប៊ | ប៉-ព | ផ-ភ | ម៉-ម |
| [t] | [th] | [n] | [b] | [p] | [ph] | [m] |
| យ៉-យ | រ៉-រ | ឡ-ល | វ៉-វ | ស-ស៊ | ហ-ហ៊ | អ-អ៊ |
| [j] | [r] | [l] | [v] | [s] | [h] | [?] |

<u>សូរស្រៈ និង API</u>

**ពួកស្រៈដែលមាន** ៖ អ[ɔɔ:] អា[a:] អឺ[oe:] អូ[o:] អើ[aə:]

អេ[e:] អែ[aɛ:] អៅ[ao:] អ៊[ə:] អ៊ា[i:ə] អ៊ី[i:] អ៊ឺ[ω:]

អ៊ូ[u:] អ៊ើ[δ:] អ៊េ[e:] អ៊ែ[ɛ:] អ៊ោ[υ:] អ៊័[oa:] អួ[u:ə]

អឿ [ɯːə]   អៀ [iːe] ។

ពួកស្រៈខ្លីមាន ៖ អ់[ɔɔ]  អាំ[a]  អិ[e]  អី[ɛi]  អឹ[oe]  អុ[o]

អៃ[ai]  អៅ[au]  អ៊ី [ə]  អ៊ាំ [iə]  អ៊ិ [i]  អ៊ឹ [ɯ]  អ៊ុ [u]

អ៊ែ [ɛ]  អ៊ៃ [ei]  អ៊ៅ [əu] ។

## ចម្លើយលំហាត់

១. ចូរអ្នកសរសេរជាសូរវិទ្យា (API) នូវពាក្យទាំងនេះ ៖

-ព្រះចន្ទ (priəh can)  ដែល (daɛːl)  យើង (jδːŋ) រំលឹក (rəmlɯk)  កំណើត (kɔɔmnaəːt)  ទន្សាយ (tənsaːj) ពោធិសត្វ (poːthisat)  បុណ្យ(bon)  អកអំបុក (?ɔːk ?ɔɔmbok) សំពះ(sɔɔmpiəh)  ព្រះខែ (Priəh khaɛː)  ព្រះឆាយាលក្ខណ៍ (priəh chajaliək)  តម្រូវ (dɔɔmro ːv)  ដំឡូង (dɔɔmlo ːŋ)  ដូង (do ːŋ) ត្រាវ (traːv)  ឧទ្ទិស (uttɯh) ។

# តថភាពនៃសម័យអាណានិគមនិយម

**សំណួរ**

១. តើអត្ថបទនេះ បានបង្ហាញពីសង្គមខ្មែរសម័យកាលណាមួយ?

២. ដោយផ្អែកលើសង្គមបរិយាកាសនៃរឿង តើកត្តាអ្វីដែលនាំឱ្យអាណានិគមបារាំង កេណ្ឌរាស្ត្រខ្មែរយកទៅធ្វើជាទាហាន? ទង្វើបែបនេះត្រឹមត្រូវឬទេ? ហេតុអ្វី?

៣. ដោយឆ្លុះតាមរយៈអត្ថបទដកស្រង់នេះ តើក្នុងសម័យកាលនោះ ប្រជារាស្ត្រមានជំនឿទៅលើអ្វីខ្លះ?

៤. ដូចម្ដេចដែលហៅថាទំនាស់? ចូរសិក្សាពីទំនាស់ និងវិភាគតួអង្គក្នុងអត្ថបទដកស្រង់នេះ។

៥. ចូរអ្នកសិក្សាពីវិធីតែងនិពន្ធសំខាន់ៗ ដែលអ្នកនិពន្ធបានប្រើក្នុងអត្ថបទដកស្រង់នេះ។

៦. ចូរជ្រើសរើសពាក្យមួយព្យាង្គ ដែលមានថ្នាក់ពាក្យជានាម ក្នុងអត្ថបទនេះ ដើម្បីសរសេរជាសញ្ញាកត់សូរអន្តរជាតិ (API) ចំនួន១០ ពាក្យ។

**ចម្លើយ**

១. អត្ថបទនេះបានបង្ហាញពីសង្គមខ្មែរសម័យអាណានិគមបារាំង។

២. ដោយផ្អែកលើសង្គមបរិយាកាសនៃរឿង កត្តាដែលនាំឱ្យអាណានិគមបារាំង កេណ្ឌរាស្ត្រខ្មែរយកទៅធ្វើជាទាហានគឺ៖

- ប្រទេសកម្ពុជាស្ថិតនៅក្រោមអាណានិគមបារាំង
- បារាំងកំពុងធ្វើសង្គ្រាមជាមួយអាឡឺម៉ង់ ដូច្នេះវាត្រូវការទាហានខ្មែរទៅជួយច្បាំងវា ។

ទង្វើបែបនេះមិនត្រឹមត្រូវទេ ព្រោះបារាំងកេណ្ឌទាហានខ្មែរទៅជួយច្បាំងវា ដើម្បីបំពេញមហិច្ឆតារបស់វាតែប៉ុណ្ណោះ វាយកទាហានទៅស្លាប់ជំនួសទាហានរបស់វា ។ វាមិនមែនធ្វើដើម្បីប្រយោជន៍របស់ប្រជាជនខ្មែរឡើយ ។ ទង្វើនេះគឺជាការរំលោភលើអធិបតេយ្យភាពរបស់ប្រទេសកម្ពុជា ។

៣. តាមរយៈអត្ថបទដកស្រង់នេះ ក្នុងសម័យកាលនោះ ប្រជារាស្ត្រមានជំនឿទៅលើ៖

- ការបន់ស្រន់វត្ថុសក្តិសិទ្ធិ ( អ្នកតា ទេវៈ...)
- បាតុភូមិធម្មជាតិ( ប្រផ្នូលផ្សេងៗដូចជារន្ទះបាញ់លើសក្ការប៉ាន ផ្កាយដុះកន្ទុយ ។ល ។)

៤. ទំនាស់គឺជាការប្រឈមគ្នារវាងកម្លាំងពីរ ឬច្រើនផ្សេងគ្នា ។

**+បញ្ហាទំនាស់ក្នុងអត្ថបទគឺ៖**

-ទំនាស់រវាងប្រជាជនខ្មែរ និងបញ្ហាពន្ធដារនាសម័យអាណានិគមបារាំង ធ្វើឱ្យប្រជារាស្ត្រក្ដៅក្រហាយ ។ ( ទំនាស់ក្រៅខ្លួន)

-ទំនាស់រវាងក្រុមទាហានខ្មែរ និងជំនឿលើវត្ថុសក្តិសិទ្ធិ គឺពួកទាហានមិនជឿលើវត្ថុសក្តិសិទ្ធិក៏បណ្ដាលឱ្យចុករាករូស គ្រុនញ័រញាក់គ្រប់ៗគ្នា ។ ( ទំនាស់ក្រៅខ្លួន)

-ទំនាស់រវាងពួកអ្នកស្រុកដែលភៀសខ្លួននៅលើភ្នំតាបាំង និងសតិអារម្មណ៍របស់ពួកគេ គឺអ្នកស្រុកភ័យខ្លាច នាំគ្នាបន់ស្រន់ទេវតាឱ្យជួយពួកគេ ។ ( ទំនាស់ក្នុងខ្លួន)

**+វិភាគតួអង្គ**

**ក) ពួកអាណានិគមបារាំង**

-ធ្វើបាបប្រជារាស្ត្រខ្មែរ

-ប្រមូលពន្ធដារពីខ្មែរទៅបម្រើមហិច្ឆតាផ្ទាល់ខ្លួន

-បង្ខំទាហានខ្មែរទៅស្លាប់ក្នុងសង្គ្រាម

**ខ) ទាហានខ្មែរ**

-ភ្លេចវប្បធម៌ជាតិខ្លួន

-មើលងាយវត្ថុសក្ដិសិទ្ធិ

-ប្រើអាកប្បកិរិយាមិនសមរម្យ

៥. វិធីតែងនិពន្ធសំខាន់ៗ ដែលអ្នកនិពន្ធបានប្រើក្នុងអត្ថបទដកស្រង់នេះមាន :

-ពណ៌នាវិធី : បន្ទាប់ពីកំណែន និងការទារពន្ធ.....។

-វចនវិធី : អ្នកនិពន្ធប្រើពាក្យពេចន៍ចំរុះ ៖

+ ពាក្យសាមញ្ញ : ចុះអាចម៍ ខ្សៀឡ ឈ្លើយ...

+ ពាក្យកម្ចីបាលីសំស្ក្រឹត : យុទ្ធសាស្ត្រ វត្ត...

-បដិវិធី : ទាហានខ្មែរ មានខ្លួនជាជាតិខ្មែរ តែមានឫកពាជាបារាំង...។

-ឯកវាទវិធី : ចំណែកនារីមានសង្សារត្រូវ.....លួចនិយាយនិងអ្នកតាផងកើ ៖ "សូមលោកតាជួយមើលសង្សារខ្ញុំកុំឱ្យបាត់មរតកនៅស្រុកបារាំង" ។

-ឧបមានវិធី : ...លាតសន្ធឹងតាមបណ្តោយព្រំប្រទល់ឃុំពង្រនិងឃុំក្រាំងលាវហាក់ដូចជាផ្ទះមួយខ្នងដ៏បួលប្រក់មេឃ ដែលចាំទទួលពួកអ្នកភៀសខ្លួនមកស្នាក់នៅ...។

៦. សរសេរពាក្យមួយព្យាង្គជានាម ជា API ចំនួន១០ ពាក្យ ៖

-ខ្មែរ : khmaɛ:

-ទ្រូង : tru:ŋ

-ចិត្ត : cet

-គ្រុន : krun

-ចៅ : cau

-ទឹក : tωk

-ស្នូរ : sno̤:r

-កូន : ko̤:n

-ស្រុក : sro̤k

-ភ្នំ : pnəm



# រឿងពិធីសុំទឹកភ្លៀង

**សំណួរ**

១. បើតាមចំណងជើងខាងលើនេះ តើរឿងនេះនិយាយពីអ្វី?

២. តើមានព្រឹត្តិការណ៍អ្វីខ្លះដែលនាំឱ្យមានពិធីនេះកើតឡើង?

៣. តើព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ទ្រង់យោនយកកំណើតជាសត្វអ្វី? នៅកន្លែងណា?

៤. ឆ្លៀតឱកាសនៃការរីងស្ងួតបឹងត្រពាំង តើសត្វកុក ក្អាត និងក្រសារ មានឥរិយាបថយ៉ាងណាខ្លះ?

៥. ដើម្បីទប់ស្កាត់នឹងអំពើរបស់សត្វកុក ក្អាត និងក្រសារ តើស្តេចត្រីរ៉ស់ មានវិធានការយ៉ាងដូចម្តេចខ្លះ? ចូរបង្ហាញ។

៦. បើតាមអត្ថបទនេះ តើប្រជារាស្ត្រខ្មែរមានជំនឿយ៉ាងណាខ្លះ? ចូរគូសបញ្ជាក់។

**ចម្លើយ**

១. តាមចំណងជើងខាងលើនេះ រឿងនេះនិយាយពីការរៀបចំពិធីដើម្បីសុំទឹកភ្លៀង។

២. ព្រឹត្តិការណ៍ដែលនាំឱ្យមានពិធីនេះកើតឡើងព្រោះ៖

- ព្រះសម្មាសម្ពុទ្ធបរមគ្រូទ្រង់យោនយកកំណើតជាត្រីរស់ស្ថិតនៅក្នុងស្រះមួយ ។
- នៅវស្សបុរីពុំមានបង្អុរភ្លៀងរាំងរឹស ទឹកបឹង ទឹកត្រពាំងកករីងស្ងួតអស់ ។ ចំណែកស្រះដែលត្រីរស់នៅនោះក៏រីងនៅសល់តែភក់ខាប់ ។
- ពួកក្អាត កុក និងក្រសារ នាំគ្នាចុះចឹកត្រីនៅក្នុងស្រះនោះជារៀងរាល់ថ្ងៃ
- ស្តេចត្រីរស់ក៏បង្គាប់ពួកត្រីទាំងឡាយឱ្យមុជចូលជ្រលក់ខ្លួនជ្រៅក្នុងភក់
- ដោយការលំបាកយ៉ាងនេះទើបស្តេចត្រីរស់តាំងអធិដ្ឋានបួងសួងនឹកដល់គុណព្រះរតនត្រៃ សូមព្រះអង្គជួយស្រោចស្រង់ស្រង់ជីវិត ។
- ព្រះឥន្ទ្រាធិរាជទ្រង់ត្រាស់ប្រើទេវបុត្រមួយអង្គឱ្យបង្អុរភ្លៀងចុះមកសព្វទិសទីលិចទីទាបគ្មានសល់ ។

៣. ព្រះសម្មាសម្ពុទ្ធបរមគ្រូនៃយើង ទ្រង់យោនយកកំណើតជាត្រីរស់ នៅក្នុងស្រះមួយនាវស្សបុរី ។

៤. ឆ្លៀតឱកាសនៃការរីងស្ងួតបឹងត្រពាំង តើសត្វកុក ក្អាត និងក្រសារនាំគ្នាចុះចឹកត្រីនៅក្នុងស្រះនោះស៊ីយ៉ាងរីករាយ ។

៥. ដើម្បីទប់ស្កាត់នឹងអំពើរបស់សត្វកុក ត្មាត និងក្រសារ ស្តេចត្រីរស់បានបង្គាប់ឱ្យពួកត្រីទាំងឡាយមុជចូលជ្រកលាក់ខ្លួនក្នុងភក់យ៉ាងវេទនា បន្ទាប់មកស្តេចត្រីរស់ក៏តាំងអធិដ្ឋានបួងសួងនឹកដល់គុណព្រះរតនត្រៃថា "សូមរតនគុណកែវទាំងបី ជាទីពឹងរបស់សត្វលោក សូមព្រះអង្គជួយស្រោចស្រង់យើងទាំងឡាយផង"។

៦. បើតាមអត្ថបទនេះ ប្រជារាស្ត្រខ្មែរមានជំនឿទៅលើការបន់ស្រន់ដល់វត្ថុសក្តិសិទ្ធិ និងគុណព្រះរតនត្រៃ។